ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន ភាសាអង់គ្លេស នៅមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តតាកែវ

"Student-Centered Approach Implementation in English Teaching at Upper Secondary School in Takeo Province"

ដោយ/By

**ឌិន ដួង/DIN DOUNG**

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៨ - ២០២០

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន ភាសាអង់គ្លេស នៅមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តតាកែវ

## Student-Centered Approach Implementation in English Teaching at Upper Secondary School in Takeo Province

ដោយ/By

**ឌិន ដួង/DIN DOUNG**

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៨ - ២០២០

គ្រូដឹកនាំបង្គោល៖ បណ្ឌិត នូវ វីរ៉ា

គ្រូដឹកនាំរង៖ លោក ចាប រតនា

# សេចក្ដីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទឈ្មោះ **ឌិន ដួង** សូមបញ្ជាក់ថាសារណាស្រាវជ្រាវដែលមានចំណងជើង «**ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនភាសាអង់គ្លេស នៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តតាកែវ**» សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានអប់រំ គឺជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះមិនទាន់ត្រូវបានគេយកមកប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬនៅសាកលវិទ្យាល័យណាមួយឡើយ ហើយក៏ពុំមានសេចក្ដីដកស្រង់ ឬខ្លឹមសារ ណាមួយត្រូវបានយកមកប្រើប្រាស់ក្នុងការស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារឡើយ។

សារណាស្រាវជ្រាវខាងលើនេះ ពិតជាស្រាវជ្រាវដោយខ្ញុំបាទផ្ទាល់ប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០២០

**ហត្ថលេខាបេក្ខជន**

**ឌិន ដួង**

# **សេចក្តីបញ្ជាក់ពីសាស្ត្រាចារ្យដឹកនាំ**

**បណ្ឌិត នួន វីរ៉ា** ជាគ្រូដឹកនាំបង្គោល

**លោក ចាប រតនា** ជាគ្រូដឹកនាំរង

## **សូមបញ្ជាក់ និងទទួលស្គាល់ថា**

លោក **ឱន ដួង** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវលើប្រធានបទ៖ «**ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនភាសាអង់គ្លេស នៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តតាកែវ**» ពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំ ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

**បណ្ឌិត នួន វីរ៉ា**

នាយករងវិទ្យាស្ថានជាតិអប់រំ

**លោក ចាប រតនា**

អនុប្រធានដេប៉ាតឺម៉ង់ គ្រប់គ្រង និងផែនការ

នៃវិទ្យាស្ថានជាតិអប់រំ

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទឈ្មោះ **ឌិន ដួខ** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៃវិទ្យាស្ថានជាតិអប់រំ ជំនាន់ទី៧ ឯកទេសគ្រប់គ្រងអប់រំ។

*<u>សូមថ្លែងអំណរគុណជាអនេកប្បការជូនចំពោះ៖</u>*

-លោកឪពុក **ឆេខ ឌិន** និងអ្នកម្តាយ **ឃិន តឿ** ដែលបានផ្តល់កំណើតចិញ្ចឹមបីបាច់រូបខ្ញុំបាទ ព្រមទាំងផ្តល់នូវការជំបូន្មានល្អៗ និងបានបញ្ជូនខ្ញុំឱ្យចូលរៀនតាំងពីថ្នាក់បឋមសិក្សា រហូតដល់ថ្នាក់ ឧត្តមសិក្សាដោយមិនគិតពីការនឿយហត់ និងតស៊ូគ្រប់ឧបសគ្គដើម្បីកូនទទួលបាននូវអនាគតរុងរឿង។

-ថ្លែងអំណរគុណចំពោះឯកឧត្តម លោក លោកស្រី តំណាងអង្គការ CIESF ដែលបានឧបត្ថម្ភ គាំទ្រទាំងផ្នែកសម្ភារ និងស្មារតីក្នុងការបង្កើតឱ្យមានថ្នាក់បណ្តុះបណ្តាលវគ្គពិសេសនេះឡើងដោយមានគោលបំណងក្នុងការរួមចំណែកដ៏សំខាន់មួយ សម្រាប់លើកកម្ពស់គុណភាពអប់រំនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

-ថ្លែងអំណរគុណចំពោះឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** ជានាយកវិទ្យាស្ថានជាតិអប់រំ ដែល ជានិច្ចកាលឯកឧត្តមបណ្ឌិតលោកតែងតែឆ្លៀតពេលដ៏មានតម្លៃរបស់លោកក្នុងការផ្តល់គំនិតការណែនាំ និងផ្តល់ទាំងកម្លាំងចិត្ត កម្លាំងកាយ បញ្ញាស្មារតី សម្ភារ បច្ចេកទេសវិធីសាស្ត្រផ្សេងៗ មិនតែប៉ុណ្ណោះ លោកបានជួយផ្តល់ជាឯកសារផ្សេងៗទាក់ទងនឹងប្រធានបទ ព្រមទាំងជួយបង្ហាញទិសដៅនៃការស្រាវជ្រាវប្រកបដោយគតិបណ្ឌិតដល់រូបខ្ញុំរហូតដល់ការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យជាស្ថាពរ។

-ថ្លែងអំណរគុណចំពោះលោកបណ្ឌិត **នួន ទីរ៉ា** ជាសាស្ត្រាចារ្យដឹកនាំ ដែលជានិច្ចកាលលោកតែងតែឆ្លៀតពេលដ៏មានតម្លៃរបស់លោកក្នុងការផ្តល់គំនិតការណែនាំ និងផ្តល់ទាំងកម្លាំងចិត្ត កម្លាំងកាយ បញ្ញាស្មារតី សម្ភារ បច្ចេកទេស វិធីសាស្ត្រផ្សេងៗ មិនតែប៉ុណ្ណោះលោកបានជួយផ្តល់ជាឯកសារផ្សេងៗទាក់ទងនឹងប្រធានបទព្រមទាំងជួយបង្ហាញទិសដៅនៃការស្រាវជ្រាវប្រកបដោយគតិបណ្ឌិតដល់រូបខ្ញុំ រហូតដល់ការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យជាស្ថាពរ។

-ថ្លែងអំណរគុណចំពោះលោក **ចាប រតនា** ជាសាស្ត្រាចារ្យដឹកនាំរង ដែលលោកតែងតែឆ្លៀតពេលដ៏មានតម្លៃរបស់លោកក្នុងការផ្តល់គំនិតការណែនាំ និងផ្តល់វិធីសាស្ត្រផ្សេងៗ មិនតែប៉ុណ្ណោះ លោកបានជួយប្រាប់ពីប្រភពដើម្បីស្វែងរកឯកសារផ្សេងៗទាក់ទងនឹងប្រធានបទ ព្រមទាំងជួយបង្ហាញទិសដៅនៃការស្រាវជ្រាវប្រកបដោយគតិបណ្ឌិតដល់រូបខ្ញុំរហូតដល់ការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យជាស្ថាពរ។

-ថ្លែងអំណរគុណចំពោះឯកឧត្តម លោក លោកស្រី ដែលជាថ្នាក់ដឹកនាំ និងជាមន្ត្រីរាជការទាំងអស់ នៃវិទ្យាស្ថានជាតិអប់រំដែលបានផ្តល់ទីតាំង និងបានសម្របសម្រួលដល់ដំណើរការនៃការបណ្តុះបណ្តាលក្នុងវគ្គនេះប្រកបដោយជោគជ័យគួរជាទីមោទនៈ។

-ថ្លែងអំណរគុណចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ដែលបានផ្តល់ព័ត៌មានយ៉ាងលម្អិត និងគ្រប់ជ្រុងជ្រោយចំពោះការសម្ភាសន៍យកព័ត៌មានមកសរសេរក្នុងនិក្ខេបបទនេះ រហូតបានបញ្ចប់ជាស្ថាពរ។

-ថ្លែងអំណរគុណចំពោះ លោក លោកស្រី សាស្ត្រាចារ្យ ជាតិ អន្តរជាតិទាំងអស់ ដែលបានខិតខំអស់ពីកម្លាំងកាយចិត្ត សម្ភារ ក្នុងការផ្តល់ពុទ្ធិ ចំណេះធ្វើ ឥរិយាបថ ពិសេសផ្តល់ជាទ្រឹស្តី បទពិសោធន៍ល្អដែលទាំងនេះជាចំណេះដឹងមួយដ៏សំខាន់ និងចាំបាច់បំផុតសម្រាប់អនុវត្ត ព្រមទាំងឆ្លុះបញ្ចាំងពីការអនុវត្តការងារ បច្ចុប្បន្ន។

ជាទីបញ្ចប់នេះ ខ្ញុំបាទសូមគោរពជូនពរ និងប្រសិទ្ធិពរ លោកអ្នកមានគុណទាំងពីរ ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា និងឯកឧត្តមលោកជំទាវ លោក លោកស្រីតំណាង អង្គការ CIESF ឯកឧត្តមបណ្ឌិត សាស្ត្រាចារ្យជាតិ អន្តរជាតិទាំងអស់ នៃវិទ្យាស្ថានជាតិអប់រំ សូមឱ្យជួបប្រទះនៃសេចក្តីសុខគ្រប់ប្រការ មានសុខភាពល្អ សម្រេចជោគជ័យគ្រប់ភារកិច្ច និងទទួលបាននូវពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

<u>សូមអរគុណ!!!</u>

# មូលន័យសង្ខេប


គោលវិធីសិស្សមជ្ឈមណ្ឌលជាគោលវិធីដ៏មានសារៈសំខាន់មួយក្នុងការបង្រៀន និងរៀនដែលគ្រូត្រូវតែយកមកអនុវត្តដើម្បីជួយពង្រឹងសមត្ថភាពសិស្សឱ្យក្លាយជាសិស្សល្អ មិត្តល្អ កូនល្អដើម្បីឱ្យពួកគេក្លាយជាពលរដ្ឋល្អក្នុងការអភិវឌ្ឍន៍ប្រទេសឱ្យមានការរីកចម្រើន។ គោលវិធីសិស្សមជ្ឈមណ្ឌលត្រូវបានយកមកអនុវត្តនៅក្នុងបរិបទប្រទេសកម្ពុជា នៅអំឡុងឆ្នាំ១៩៩៧។ ការនាំយកនូវវិធីសាស្ត្របង្រៀននេះ ក្នុងគោលបំណងធ្វើឱ្យសិស្សធ្វើសកម្មភាពយ៉ាងសកម្មហើយរៀបចំបង្កើតការសិក្សាដោយខ្លួនឯងដោយគ្រាន់តែមានជំនួយ និងធ្វើការសម្របសម្រួលពីលោកគ្រូ អ្នកគ្រូ។ ហើយម្យ៉ាងទៀតការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការបង្រៀនមុខវិជ្ជាភាសាអង់គ្លេស ពីព្រោះការអនុវត្តនេះសិស្សមានសកម្មភាពច្រើន និងអាចចងក្រងខ្លឹមសារមេរៀន(រូបមន្ត ទ្រឹស្តី ខ្លឹមសារសំខាន់ៗនៃមេរៀន) ក្រោមការណែនាំ និងកែលម្អពីគ្រូដើម្បីឱ្យសិស្សមានសមត្ថភាពពេញលេញអាចដោះស្រាយបញ្ហាដែលកើតមានឡើង។ ប្រធានបទស្តីពី **“ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន ភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ(ថ្នាក់ទី១១) ក្នុងខេត្តតាកែវ”** ត្រូវបានធ្វើឡើងដើម្បីពិនិត្យមើលពីស្ថានភាពបច្ចុប្បន្ននៃការរៀន និងការបង្រៀន និងរួមចំណែកជួយដោះស្រាយភាពអសកម្មមួយចំនួនដែលកំពុងកើតមានឡើងតាមរយៈការបង្ហាញនូវមូលដ្ឋានទ្រឹស្តី និងការអនុវត្តវិធីសាស្ត្របង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការរៀន និងការបង្រៀនភាសាអង់គ្លេស នៅក្នុងថ្នាក់រៀនឱ្យមានប្រសិទ្ធភាព។គោលវិធីនេះគឺធ្វើយ៉ាងណាឱ្យសិស្សយល់ឱ្យកាន់តែច្បាស់ប្រកបដោយគុណភាព និងធានាបានថាសិស្សានុសិស្សគ្រប់រូបទទួលបានចំណេះដឹងជំនាញក្នុងការគិត និងហេតុផល មានបទពិសោធន៍ក្នុងការសិក្សាប្រកបដោយគុណភាព ប្រសិទ្ធភាព ភាពឆ្លើយតប និងប្រសិទ្ធផល។

ការសិក្សានេះត្រូវបានអនុវត្តនៅវិទ្យាល័យចំនួន០៣ នៅក្នុងខេត្តតាកែវ ដែលមានអ្នកចូលរួមជាគណៈគ្រប់គ្រងសាលាចំនួន១០រូប លោកគ្រូ អ្នកគ្រូចំនួន០៨រូប និងសិស្សានុសិស្សចំនួន១៤៨នាក់បំពេញកម្រងសំណួរ និងធ្វើការសម្ភាស។ទិន្នន័យត្រូវបានវិភាគដោយប្រើកម្មវិធី SPSS និង EXCEL និង

បង្ហាញជាតារាងស្ថិតិពណ៌នា ដើម្បីបកស្រាយពីការវាយតម្លៃការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនភាសាអង់គ្លេសដោយផ្អែកលើតំបន់ទីប្រជុំជន និងជនបទ។

លទ្ធផលសំខាន់ៗនៃការស្រាវជ្រាវនេះ បានបង្ហាញថាការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១១) ក្នុងខេត្តតាកែវ គឺអនុវត្តបានល្អ។ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងគណៈគ្រប់គ្រងបានវាយតម្លៃថាពួកគាត់បានចំណាយពេលច្រើនក្នុងការត្រៀមលក្ខណៈមុនពេលបង្រៀន ក៏ដូចជាលក្ខណៈទូទៅនៃការបង្រៀន ប៉ុន្តែក្នុងសកម្មភាពបង្រៀនផ្ទាល់ឃើញថាក៏នៅមានចំណុចខ្វះខាតបន្តិចបន្តួច គឺសិស្សមួយចំនួនសមត្ថភាពនៅមានកម្រិត កង្វះខាតសម្ភារឧបទេស នៅក្នុងដំណើរការបង្រៀន និងរៀន និងគ្រប់គ្រងពេលវេលាមិនបានសមស្រប។ លើសពីនេះការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១១) ក្នុងខេត្តតាកែវ យើងសង្កេតឃើញថាលោកគ្រូអ្នកគ្រូនៅតាមទីប្រជុំជនបានអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនភាសាអង់គ្លេស បានល្អជាងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនភាសាអង់គ្លេសនៅតាមទីជនបទ។

# ABSTRACT

Student-centered approach is very essential for teaching and learning that teachers must use in order to help students to gain effective and good abilities to be a good student, good friend, and a good child so that they can become a good citizen to develop the country. This approach has been used since 1997.

This teaching method can help students to be more active and to organize students learn themselves with helping and facilitating by their teachers. This also helps for English teachers because it makes students to be more active and they can summarize, include, and solve the formulas, theories, and all-important points in the lesson by introducing and correcting by their teachers with some of their problems that they are facing.

"Student-centered approach implementation in English teaching at upper secondary school in Takeo province" that show here is to observe the present situation of learning and teaching and to solve some matters that are inactive by showing the basic of theories and real practice in learning and teaching English in class. This approach is to make students have a clear understanding and to assure that all the students can get more knowledge, good decision making with good reasons and to get experiences in learning that have good quality, effectiveness, good responding and good results.

This research has been done at 3 high school in Takeo province with 10 school directors and subdirectors, 8 teachers and 148 students by doing the interview and completing the questionnaires. The data is analyzed by using SPSS program and EXCEL to show and to compare the downtown countryside areas.

The result of this research show that "Student-centered approach implementation in English teaching at upper secondary school in Takeo province" for grade 11 students is good. All the participants valuate that they have a good

preparation before teaching as well as during the teaching, but during the teaching they still have some difficulties because some students their ability is still low, sometimes the studying equipment and tools are not enough and time management is also the problems. Moreover, the practicing of this approach at downtown is better than at rural areas.

# មាតិកា

សេចក្តីប្រកាសអះអាងរបស់បេក្ខជន ........ i
សេចក្តីបញ្ជាក់ពីសាស្រ្តាចារ្យដឹកនាំ ........ ii
សេចក្តីថ្លែងអំណរគុណ ........ iii
មូលន័យសង្ខេប ........ v
បញ្ជីតារាង ........ xii
បញ្ជីអក្សរកាត់ ........ xiii
........ 1
ជំពូក១៖ ........ 2
សេចក្តីផ្តើម ........ 2
១.១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ 2
១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ 4
១.៣. គោលបំណងនៃការស្រាវជ្រាវ ........ 6
១.៤. សំណួរស្រាវជ្រាវ ........ 6
១.៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ 7
១.៦. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ 8
១.៦.១. វិសាលភាពនៃការស្រាវជ្រាវ ........ 8
១.៦.២. ដែនកំណត់នៃការស្រាវជ្រាវ ........ 8
១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ 9
ជំពូក២៖ ........ 12
រំលឹកទ្រឹស្តី ........ 12
២.១. និយមន័យពាក្យគន្លឹះ ........ 12
២.១.១. វិធីសាស្រ្តបង្រៀន ........ 12
២.១.២. ការបង្រៀន និងរៀន ........ 12

២.១.៣. គោលវិធីសិស្សមជ្ឈមណ្ឌល ......14
២.២. ការរៀបចំការរៀន និងការបង្រៀនតាមបែបសិស្សមជ្ឈមណ្ឌល ......16
២.២.៣. វិធីសាស្ត្ររៀន និងបង្រៀននានាគាំទ្រគោលវិធីសិស្សមជ្ឈមណ្ឌល ......30
២.៣. វិធីសាស្ត្របង្រៀនភាសាអង់គ្លេស ......32
២.៤. គោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនភាសាអង់គ្លេស ......33
២.៥. ការរៀបចំសិស្ស ......35
២.៦. របៀបសិក្សា ......36
២.៧. តួនាទីគ្រូបង្រៀនក្នុងការបង្រៀនបែបអង់គ្លេស ......36
២.៧.១. តួនាទីជាអ្នកធ្វើផែនការ ......36
២.៧.២. តួនាទីជាអ្នកសម្របសម្រួល ......37
២.៧.៣. តួនាទីជាអ្នកដឹកនាំ ......37
២.៧.៤. តួនាទីជាអ្នកត្រួតពិនិត្យតាមដាន និងវាយតម្លៃ ......38
២.៨. បញ្ហាប្រឈមនៅក្នុងការអនុវត្តកម្មវិធីសិស្សមជ្ឈមណ្ឌល ......38
ជំពូកទី៣៖ ......41
វិធីសាស្ត្រស្រាវជ្រាវ ......41
៣.១. ដែនកំណត់ និងវិសាលភាព ......41
៣.២. ការជ្រើសរើសភាគសំណាក ......41
៣.២.១. ព័ត៌មានផ្ទាល់ខ្លួនរបស់គណៈគ្រប់គ្រងដែលចូលរួមក្នុងការស្រាវជ្រាវ ......41
៣.២.២. ព័ត៌មានផ្ទាល់ខ្លួនរបស់ លោកគ្រូ-អ្នកគ្រូ ដែលចូលរួមក្នុងការស្រាវជ្រាវ ......43
៣.២.៣. ព័ត៌មានផ្ទាល់ខ្លួនរបស់ សិស្សានុសិស្ស ដែលចូលរួមក្នុងការស្រាវជ្រាវ ......44
៣.៣. ឧបករណ៍ស្រាវជ្រាវ ......44
៣.៤. នីតិវិធី ឬដំណើរការប្រមូលទិន្នន័យ ......45
៣.៥. ការវិភាគទិន្នន័យ ......46
......47

ជំពូក ៤៖ ...............................................................................................................49
លទ្ធផល និងការពិភាក្សា ................................................................................................49
៤.១. ការសម្ភាសន៍ជាមួយនាយក នាយិកា នាយករង នាយិការរង...............................................49
៤.២. សម្ភារឧបទេស.........................................................................................................50
៤.៣. កិច្ចតែងការបង្រៀន ..................................................................................................54
៤.៤. អធិការកិច្ច...............................................................................................................55
៤.៥. សកម្មភាពពេលកំពុងបង្រៀន.........................................................................................58
៤.៦. ការសម្ភាសន៍ជាមួយគ្រូបង្រៀនភាសាអង់គ្លេស ..................................................................63
៤.៦.១. ស្ថិតិលោកគ្រូអ្នកបង្រៀនភាសាអង់គ្លេស...........................................................................64
៤.៦.២. ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល ............................................................................65
៤.៦. លទ្ធផលដែលទទួលបានតាមរយៈការបំពេញកម្រងសំណួររបស់សិស្ស ..................................79
៤.៦.១. ចំនួនសិស្សដែលបានបំពេញកម្រងសំណួរតាមវិទ្យាល័យគោលដៅ.......................................79
៤.៦.២. ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល ............................................................................80
៤.៦.៣. ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលនៃការបង្រៀនភាសាអង់គ្លេស .................................101
ជំពូកទី៥៖ .............................................................................................................107
សេចក្តីសន្និដ្ឋាន និងសំណូមពរ......................................................................................107
៥.១. សេចក្តីសន្និដ្ឋាន.......................................................................................................107
៥.២. សំណូមពរ .............................................................................................................108
ឯកសារយោង ..........................................................................................................112
ឧបសម្ព័ន្ធ...............................................................................................................114

# បញ្ជីតារាង

តារាង 1៖ បំណែងចែកសមាសភាពរបស់គណៈគ្រប់គ្រងតាមវិទ្យាល័យ ........................................41

តារាង 2៖ បទពិសោធន៍ការងាររបស់គណៈគ្រប់គ្រងតាមវិទ្យាល័យ ............................................ 42

តារាង 3៖ ព័ត៌មានទាក់ទងនឹងកម្រិតសិក្សារបស់លោកគ្រូ-អ្នកគ្រូ ............................................... 43

តារាង 4៖ បំណែងចែកសមាសភាពរបស់លោកគ្រូ-អ្នកគ្រូតាមវិទ្យាល័យ ...................................... 43

តារាង 5៖ បំណែងចែកសមាសភាពរបស់សិស្សានុសិស្សថ្នាក់ទី១១តាមវិទ្យាល័យ ........................... 44

# បញ្ជីអក្សរកាត់

## Abbreviation

- អ.យ.ក ក្រសួងអប់រំ យុវជន និងកីឡា
- MoEYS Ministry of Education Youth and Sports
- NIE National Institute of Education
- CIESF Cambodia International Education Support foundation
- វិ.ស. អ.ព.ស វិទ្យាល័យសុខ អាន ព្រៃសណ្តែក
- វិ.ស. អ.ថ.ប វិទ្យាល័យសុខ អាន ថ្នល់បំបែក
- វិ.ស. អ.ខ្វាវ វិទ្យាល័យសុខ អាន ខ្វាវ

# ជំពូកទី១

# សេចក្តីផ្តើម

# ជំពូក១

# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងសតវត្សរ៍ទី២១នេះ គ្រប់ប្រទេសលើសកលលោកបាននឹងកំពុងធ្វើកំណែទម្រង់លើគ្រប់វិស័យក្នុងគោលបំណងដើម្បីឆ្លើយតបទៅនឹងការរីកចម្រើនឥតឈប់ឈរ និងតម្រូវការគ្មានទីបញ្ចប់របស់មនុស្សសំដៅលើកកម្ពស់គុណភាពជីវិត សេចក្តីថ្លៃថ្នូរ និងសិទ្ធិសេរីភាព។ ដើម្បីអាចសម្របខ្លួនទៅនឹងការវិវត្តរបស់ពិភពលោក និងតំបន់ក្នុងន័យដើម្បីឆ្លើយតបចំពោះការប្រកួតប្រជែងប្រទេសកម្ពុជាត្រូវតែមានធនធានមនុស្សដែលមានសមត្ថភាព និងជំនាញវិជ្ជាជីវៈខ្ពស់ (ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨, ឆ្នាំ២០១៤)។ រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សដោយបានដាក់ចេញនូវគោលនយោបាយ ធ្វើកំណែទម្រង់លើវិស័យផ្សេងៗដែលជាអទិភាពដើម្បីសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍសហវត្សរ៍ក្នុងឆ្នាំ២០១៦-២០៣០ ដែលគោលដៅផ្តោតទៅលើបញ្ហាចម្បងៗដូចជាបញ្ហាសមធម៌ គុណភាពអប់រំ និងទស្សនៈនៃការសិក្សារៀនសូត្រពេញមួយជីវិត(វិស័យអប់រំឆ្នាំ ២០៣០, ឆ្នាំ២០១៥)។

ការអប់រំពិតជាសំខាន់ណាស់ អាទិភាពចម្បងរបស់ប្រទេសកម្ពុជាគឺការធានាថាការអប់រំមានគុណភាពល្អ និងឈានដល់កម្រិតស្តង់ដាខ្ពស់ និងមានការទទួលស្គាល់ពីគ្រប់មជ្ឈដ្ឋានជាតិ អន្តរជាតិ ដូចមានចែងនៅក្នុងច្បាប់ស្តីពីការអប់រំរបស់ប្រទេសថា «រដ្ឋត្រូវលើកកម្ពស់គុណភាពអប់រំដើម្បីបំពេញសេចក្តីត្រូវការសម្រាប់ការអប់រំជាមូលដ្ឋាន និងសេចក្តីត្រូវការជំនាញដើម្បីធ្វើឲ្យអ្នកសិក្សាមានសមត្ថភាព និងលទ្ធភាពចូលរួមអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព"(ហង់ ជួន ណារ៉ុន, ២០១៦)។ ដើម្បីសម្រេចបានតាមគោលដៅខាងលើក្រសួងអប់រំ យុវជននិងកីឡាបានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៤ - ២០១៨ ក្នុងគោលបំណងអភិវឌ្ឍធនធានមនុស្សដើម្បីឲ្យកម្ពុជាក្លាយជាប្រទេសមួយ ដែលមានប្រាក់ចំណូលមធ្យមកំរិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០ និងផ្តល់នូវការរៀនសូត្រមួយប្រកបដោយគុណភាពខ្ពស់។ សេវាអប់រំត្រូវបានផ្តល់ប្រកបដោយវិជ្ជាជីវៈ និងគណនេយ្យភាពក្នុងគោលបំណងដើម្បីបណ្តុះ

គ្រឹះចំណេះដឹងជំនាញសេដ្ឋកិច្ចមូលដ្ឋានរឹងមាំ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤ - ២០១៨ បានដាក់ចេញនូវគោលនយោបាយសំខាន់ៗចំនួនពីរគឺៈ (១) ធានាឲ្យការអប់រំមានគុណភាពប្រកបដោយសមធម៌បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយមួយជីវិតសម្រាប់ទាំងអស់គ្នា (២) ធានាភាពសក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់(សន្និបាតអប់រំ,ឆ្នាំ២០១៧)។

វិស័យអប់រំដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកដល់ការអភិវឌ្ឍប្រទេសជាតិ ដែលក្នុងនោះ កុមារយុវជន និងមនុស្សពេញវ័យត្រូវទទួលបានការសិក្សាអប់រំពេញលេញ និងពេញមួយជីវិតដើម្បីឆ្លើយតបទៅនិងតម្រូវការទីផ្សារការងារប្រកបដោយគុណភាពខ្ពស់។ គោលដៅនៃការអប់រំនៅគ្រប់កម្រិតសិក្សាទាំអស់គឺបង្រៀនសិស្សឲ្យចេះកសាងជំនាញ ចេះរស់នៅក្នុងជីវិតជាក់ស្តែងប្រកបដោយភាពថ្លៃថ្នូរ ព្រមទាំងចេះបណ្តុះគំនិតថ្មីៗសមស្របតាមស្ថានភាពសង្គម និងបង្រៀនពួកគេឲ្យចេះដោះស្រាយបញ្ហាដែលជួបប្រទះ ហើយចេះផ្សារភ្ជាប់ទ្រឹស្តីដែលបានរៀននៅក្នុងសាលាទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ។ ការអប់រំនេះអាចអនុវត្តបានប្រកបដោយប្រសិទ្ធភាពគឺអាស្រ័យលើគ្រូបង្រៀនពីព្រោះគ្រូបង្រៀន គឺជាធាតុចូលដ៏មានសារៈសំខាន់បំផុតសម្រាប់ផ្តល់នូវគុណភាពនៃការសិក្សា។ គ្រូបង្រៀនពិតជាចាំបាច់ត្រូវការទាំងទ្រឹស្តីបទពិសោធន៍ វិធីសាស្ត្រ បច្ចេកទេសក្នុងការផ្ទេរចំណេះដឹង បំណិន សីលធម៌ ឥរិយាបទល្អៗដល់សិស្សស្របតាមចតុស្តម្ភទាំងបួននៃការអប់រំសម្រាប់សតវត្សទី២១គឺ រៀនដើម្បីមានចំណេះដឹង រៀនដើម្បីចេះធ្វើ រៀនដើម្បីក្លាយជាពលរដ្ឋល្អ និងរៀនដើម្បីចេះរស់នៅជាមួយគ្នា។

ជាការពិតណាស់នៅពាក់កណ្តាលសតវត្សរ៍ទី២០ គោលវិធីសិស្សមជ្ឈមណ្ឌលជាវិធីសាស្ត្របង្រៀនថ្មីហើយត្រូវបានប្រទេសជឿនលឿននៅលើសកលលោកនិយមប្រើប្រាស់ ពីព្រោះការបង្រៀនតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌលពិតជាបានធ្វើឲ្យសិស្សទទួលបាននូវចំណេះដឹងបំណិន និងអភិវឌ្ឍបុគ្គលិកលក្ខណៈបានឆាប់រហ័សដើម្បីបន្សាំខ្លួនទៅនឹងបច្ចេកវិទ្យាទំនើបៗ និងចរន្តប្រជាធិបតេយ្យនឹងមានប្រសិទ្ធភាពជាងវិធីសាស្ត្របែបបុរាណ ឬការបង្រៀនតាមបែបគ្រូមជ្ឈមណ្ឌល។ ដោយឡែកនៅក្នុងប្រទេសកម្ពុជាវិធីសាស្ត្របង្រៀនសិស្សតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌលនេះ មានឥទ្ធិពលខ្លាំងនៅចុងសតវត្សរ៍ទី២០ដោយមានការចេញសេចក្តីណែនាំឲ្យអនុវត្តនៅថ្ងៃទី៤ ខែ កញ្ញា ឆ្នាំ ១៩៩៧ ដោយក្រសួងអប់រំ យុវជន និងកីឡា មាន

សេចក្តីថា″ ការអនុវត្តក្នុងការរៀន និងបង្រៀនដោយផ្តោតលើវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល″។ វិធីសាស្ត្របង្រៀនសិស្សមជ្ឈមណ្ឌលដែលមានប្រសិទ្ធភាពនោះ គឺសិស្សធ្វើសកម្មភាពហើយកសាងរៀបចំបង្កើត ដោយខ្លួនឯងក្នុងការសិក្សាដោយមានការជំនួយពីសំណាក់គ្រូ និងមានការបំប៉នវិធីសាស្ត្រថ្មីៗនេះជាលើកដំបូងសម្រាប់គ្រូបង្រៀនពីថ្នាក់ទី១ដល់ថ្នាក់ទី៦នៅកម្រិតបឋមសិក្សា និងថ្នាក់ទី៧ នៃមធ្យមសិក្សាបឋមភូមិហើយក៏បានធ្វើវិក្រឹតការលើកម្មវិធីសិក្សាថ្មីជូនលោកគ្រូ-អ្នកគ្រូក្នុងកម្រិតសិក្សានេះដែរ (មាយ សារី ២០០២)។

ការអប់រំ គឺអភិវឌ្ឍបុគ្គលម្នាក់ៗដើម្បីឲ្យគេមានសមត្ថភាពចូលរួមកសាងសង្គម។ មានន័យថាការអប់រំត្រូវផ្តល់ឱកាសឲ្យបុគ្គលគ្រប់ៗ រូបកសាងសមត្ថភាពខ្លួនគេទាំងរូបរាងកាយ បញ្ញា ស្មារតី សតិអារម្មណ៍ សីលធម៌ និងសោភ័ណ។ ផ្តើមចេញពីនេះគ្រូបង្រៀនម្នាក់ៗត្រូវចាប់អារម្មណ៍ជានិច្ចថាខ្លួន ជាអ្នកសម្របសម្រួលការរៀនសូត្ររបស់សិស្សមិនមែនបង្ខំឲ្យសិស្សធ្វើតាមឡើយ។ ហើយគោលវិធីសិស្សមជ្ឈមណ្ឌលពិតជាមានសារៈណាស់ ដើម្បីយកមកបង្រៀនឲ្យសិស្សានុសិស្សទទួលបានជោគជ័យ ក្នុងការរៀនភាសាអង់គ្លេសឲ្យមានប្រសិទ្ធភាព មានសមត្ថភាពច្បាស់លាស់ ដើម្បីក្លាយជា សិស្សល្អ កូនល្អ ពលរដ្ឋល្អ ដែលជាកត្តាធ្វើឲ្យប្រទេសជាតិមានការរីកចម្រើន។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ទោះបីជាបច្ចុប្បន្ននេះ មានវិធីសាស្ត្របង្រៀនច្រើនពិតមែនហើយគោលវិធីដែលបានប្រើប្រាស់នាពាក់កណ្តាលសតវត្សរ៍ទី២០គឺគោលវិធីសិស្សមជ្ឈមណ្ឌល ហើយគោលវិធីនេះជាវិធីសាស្ត្រដែលអាចជួយដល់ការបង្រៀននិងរៀនឲ្យមានប្រសិទ្ធភាពខ្ពស់ ហើយវាជាវិធីសាស្ត្របង្រៀនថ្មីដែលត្រូវបានបណ្តាប្រទេសជឿនលឿននៅលើសកលលោកនិយមប្រើប្រាស់ ព្រោះគោលវិធីនេះបានធ្វើឲ្យសិស្សទទួលបាននូវចំណេះដឹង បំណិន និងឥរិយាបថល្អនិងសមជាប្រជាពលរដ្ឋថ្លៃថ្នូរមែន។ ប៉ុន្តែគោលវិធីនេះក៏មិនត្រូវទទួលបានការចាប់អារម្មណ៍ និងព្យាយាមអនុវត្តតាមទាំងស្រុងនៅឡើយដែរ ព្រោះតែទ្រឹស្តី និងគោលការណ៍អនុវត្តនៃវិធីសាស្ត្របង្រៀននេះនៅមិនទាន់បានធ្វើការផ្សព្វផ្សាយឲ្យទូលំទូលាយ និងគ្មានការឯកភាពគ្នាក្នុងការអនុវត្តសម្រាប់ការបង្រៀន និងរៀននៅគ្រប់ភូមិសិក្សានោះដែរ ។ ម៉្យាងវិញទៀតស្ថានភាពនៃការអប់រំនៅក្នុងប្រទេសកម្ពុជា នៅមិនទាន់មានលក្ខណៈសមស្របក្នុងការអនុវត្តវិធីសាស្ត្របង្រៀនតាមគោលវិធីសិស្ស

មជ្ឈមណ្ឌលនៅឡើយដែរ ព្រោះតែនៅតាមសាលារៀនមួយចំនួនដូចជា នៅទីជនបទមិនមានថ្នាក់រៀនគ្រប់គ្រាន់សិស្សក្នុងមួយថ្នាក់ៗមានចំនួនច្រើនខ្លឹមសារមេរៀនច្រើនគ្មានសម្ភារ និងឧបករណ៍បង្រៀនគ្រប់គ្រាន់ជាដើម។ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រទេសកម្ពុជាបាននឹងកំពុងធ្វើកំណែទម្រង់ការអប់រំ និងការកែលម្អវិធីសាស្ត្របង្រៀនក្នុងគោលដៅលើកកម្ពស់ជំនាញទន់ គុណភាពអប់រំ និងកំពុងអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤ - ២០១៨ ដើម្បីឆ្លើយតបទៅនឹងដំណើរការអភិវឌ្ឍរបស់រដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា។ ទន្ទឹមនឹងដំណើរការកំណែទម្រង់នេះ បញ្ហាប្រឈមជាច្រើនក៏បានកើតឡើងជាបន្តបន្ទាប់ ដូចជាគ្រឹះស្ថានសិក្សា និងកម្មវិធីសិក្សាមិនមានស្តង់ដាគ្រូបង្រៀននៅមានគុណវុឌ្ឍិទាបសិស្សបោះបង់ការសិក្សាច្រើននៅកម្រិតមធ្យមសិក្សាបឋមភូមិដោយសារពួកគេមិនចាប់អារម្មណ៍ក្នុងការសិក្សាបញ្ហាជីវភាពគ្រួសារ។ល។ បើមើលតាមស្ថានភាព ជាក់ស្តែងសិស្សខ្លះដែលបានបញ្ចប់ការសិក្សាក៏ដោយ ក៏មិនអាចរកការងារបានធ្វើព្រោះតែសមត្ថភាពជំនាញមិនអាចឆ្លើយតបនឹងតម្រូវការទីផ្សារ (ប្រសាសន៍របស់ ឯកឧត្តមបណ្ឌិត ហង់ ជួន ណារ៉ុន, ឆ្នាំ២០១៨)។ ជាក់ស្តែងប្រព័ន្ធអប់រំនៅប្រទេសកម្ពុជាកំពុងជួបបញ្ហាដូចជាធនធានមនុស្សខុសពីតម្រូវការទីផ្សារ គុណភាពអប់រំ នៅមានកម្រិតទាប ការអនុវត្តកម្មវិធីសិក្សាស្ថិតក្រោមស្តង់ដា គុណភាពគ្រូបង្រៀននៅមានកម្រិត ហេដ្ឋារចនាសម្ព័ន្ធសាលារៀននៅខ្វះខាតកង្វះការប្រើប្រាស់សម្ភារៈព័ត៌បច្ចេកវិទ្យា និងមន្ទីរពិសោធន៍ក្នុងការបង្រៀន ទំនាក់ទំនងរវាងគោលនយោបាយ ការបណ្តុះបណ្តាលគ្រូ សាលារៀន និងថ្នាក់រៀនស្ថិតនៅក្នុងសតវត្សទី២០នៅឡើយ ( សន្និបាតអប់រំ ខែមីនា ឆ្នាំ ២០១៨ )។ គ្រូបង្រៀនត្រូវតែយល់ដឹងពីតួនាទីដ៏សំខាន់របស់ខ្លួននៅក្នុងសង្គម មានសមត្ថភាពក្នុងការកសាង និងប្រើប្រាស់សម្ភារផ្សេងៗដែលបម្រើឲ្យការងារអប់រំ យល់ដឹងពីកម្មវិធីសិក្សា មានទស្សនវិជ្ជាអប់រំ មានមនសិការវិជ្ជាជីវៈខ្ពស់ ថាតើគាត់ជ្រើសរើសយកវិធីសាស្ត្របង្រៀនបែបណា ក្នុងការផ្តល់ ឬផ្ទេរនូវចំណេះដឹង បំណិន ជំនាញ បទពិសោធន៍ដល់សិស្ស ។ លើសពីនេះទៅទៀត ការរៀបចំសៀវភៅគ្រូ និងកិច្ចតែងការបង្រៀនគឺជាវិធីសាស្ត្រដ៏ល្អក្នុងការកែលម្អគុណភាពរៀន និងបង្រៀន នេះមានន័យថា គ្រូបង្រៀនត្រូវមានគរុកោសល្យ និងចេះប្រើប្រាស់វិធីសាស្ត្របង្រៀនថ្មីៗដើម្បីទាក់ទាញសិស្សឲ្យផ្តោតអារម្មណ៍ទៅលើការសិក្សា( ក្រសួងអប់រំ យុវជន និងកីឡា , ២០១៤ )។ ដូចនេះការបង្រៀនមិនមែនស្ថិតនៅត្រង់យកចំណេះដឹងទៅបង្រៀនសិស្ស

នោះទេ ប៉ុន្តែកត្តាសំខាន់គឺស្ថិតនៅត្រង់ជួយសិស្សយ៉ាងណាឲ្យមានទឹកចិត្តមើលឃើញថាការរៀនមានន័យសម្រាប់ពួកគេ។ ប្រសិនបើសិស្សរបស់អ្នកអាចមើលឃើញពីទំនាក់ទំនងរបស់ចំណេះដឹងនោះ មកក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេនោះអ្នកនឹងជួបជ័យជំនះហើយ ( អ៊ឹម កុច , ១៩៩៩ ) ។ ហេតុដូចនេះហើយទើបមានការសិក្សាស្រាវជ្រាវមួយស្តីពី " **ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១១)ក្នុង ខេត្តតាកែវ** " ក្នុងគោលបំណងពិនិត្យមើលពីភាពអសកម្មមួយចំនួនដែលកំពុងកើតមានតាមរយៈការបង្ហាញនូវមូលដ្ឋានគ្រឹះទ្រឹស្តី និងការអនុវត្តវិធីសាស្ត្របង្រៀនតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌលនៅក្នុងថ្នាក់រៀន និងក្រៅថ្នាក់រៀន។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងបញ្ហារៀបរាប់ខាងលើ ការស្រាវជ្រាវនេះគឺផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើគ្រូបង្រៀន និងសិស្ស ។ ដូចនេះវត្ថុបំណងសំខាន់នៃការស្រាវជ្រាវគឺ៖

1) រកឱ្យឃើញពីស្ថានភាពនៃការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនភាសាអង់គ្លេស នៅកម្រិតមធ្យមសិក្សាទុតិយភូមិ( ថ្នាក់ទី១១ )ក្នុងខេត្តតាកែវ ។
2) សិក្សាប្រៀបធៀបរវាងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល រវាងគ្រូនៅទីប្រជុំជន និងលោកគ្រូ-អ្នកគ្រូនៅជនបទ។

## ១.៤ សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងវត្ថុបំណងស្រាវជ្រាវនេះ សំណួរស្រាវជ្រាវត្រូវបានកំណត់ដូចខាងក្រោម៖

1) តើគ្រូបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ( ១១ ) បានអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនភាសាអង់គ្លេសបានកម្រិតណា ?
2) តើការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល នៅតាមទីប្រជុំជន និងនៅតាមជនបទមានកម្រិតខុសគ្នាយ៉ាងដូចម្តេច ?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះពិតជាមានសារៈសំខាន់ណាស់សម្រាប់អ្នកសិក្សា លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សដែលកំពុងសិក្សារៀនសូត្រ និងរស់នៅក្នុងប្រទេសដែលកំពុងអភិវឌ្ឍមួយនេះ។ ការសិក្សាស្រាវជ្រាវនេះ គឺពិតជាបានរកឃើញនូវបញ្ហាដែលកំពុងតែកើតឡើងនៅក្នុងប្រព័ន្ធអប់រំរបស់ប្រទេសកម្ពុជា ដើម្បីចូលរួមធ្វើការដោះស្រាយឲ្យបានទាន់ពេលវេលានិងកែលម្អគុណភាព ប្រសិទ្ធភាពនៃការបង្រៀន និងរៀនស្របតាមកម្មវិធីសិក្សាថ្មីក្នុងសម័យកាលកំណែទម្រង់អប់រំនេះ។ ការរៀនរបស់សិស្សចាំបាច់ត្រូវតែមានទំនាក់ទំនងទៅនឹងកម្មវិធីអប់រំ បទពិសោធន៍ក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស វិធីសាស្ត្របង្រៀនភាសាអង់គ្លេស និងការគាំទ្រយុទ្ធសាស្ត្រសិក្សាដែលគ្រូបង្រៀនបានបម្រុងទុក ដើម្បីដោះស្រាយទៅនឹងតម្រូវការនៃការរៀនផលប្រយោជន៍ សេចក្តីប្រាថ្នា ឬទំនៀមទម្លាប់ខុសៗគ្នារបស់សិស្ស។ ដើម្បីសម្រេចបានតាមគោលដៅទាំងនេះ សាលារៀន ជាពិសេសគ្រូបង្រៀនត្រូវជ្រើសរើសវិធីសាស្ត្របែប "គោលវិធីសិស្សមជ្ឈមណ្ឌលដែលជាលំនាំនៃការរៀន និងបង្រៀនមួយដោយផ្តោតទៅលើសកម្មភាពសិស្សជាចម្បង"។ គោលវិធីនេះតម្រូវឲ្យសិស្សធ្វើសកម្មភាពស្វែងយល់ដើម្បីឈានទៅរកបកគំហើញខ្លឹមសារណាមួយ ដោយខ្លួនឯងក្រោមការជម្រុញ និងដឹកនាំរបស់គ្រូសំដៅសម្រេចឲ្យបាននូវការផ្តល់ចំណេះដឹង បំណិន និងឥរិយាបថវិជ្ជមាន។ ក្នុងលំនាំនេះ សិស្សអាចធ្វើសកម្មភាពសិក្សាស្វែងយល់ជាបុគ្គល ជាដៃគូរ ជាក្រុមតូច និងក្រុមធំ។ ក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលនេះ សកម្មភាពសិស្ស និងសកម្មភាពគ្រូ ត្រូវតែផ្សារភ្ជាប់គ្នាគ្នាយ៉ាងជិតស្និទ្ធមិនអាចខ្វះបានឡើយ ក្នុងន័យដើម្បីឲ្យសិស្សានុសិស្សគ្រប់រូប កសាងសមត្ថភាពខ្លួនគេទាំងរូបរាងកាយ បញ្ញាស្មារតី សតិអារម្មណ៍ សីលធម៌ និងសោភ័ណ។ ហើយគោលវិធីនេះ ព្រមទាំងអាចធ្វើឲ្យថ្នាក់រៀនមានភាពរស់រវើកប្រកបដោយបរិយាកាសគរុកោសល្យល្អ អាចធ្វើឲ្យសិស្សចេះយល់ចិត្តគ្នា មានអធ្យាស្រ័យគ្នាចេះអត់ធ្មត់ ដើម្បីឈានទៅរកសាមគ្គីភាព បំបាត់អំពើហិង្សា ចេះរួមរស់ជាមួយគ្នា ក្នុងសង្គម។ ដូចនេះប្រទេសជាតិទាំងមូលនឹងទទួលបានប្រជាធិបតេយ្យ និងសន្តិភាពដែលជាជំហរខ្ពស់បំផុតឆ្ពោះទៅដល់ការអភិវឌ្ឍប្រទេសទាំងមូល។

## ១.៦ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៦.១ វិសាលភាពនៃការស្រាវជ្រាវ

វិសាលភាពនៃការសិក្សាស្រាវជ្រាវ ផ្តោតសំខាន់ទៅលើគុណភាពនៃការបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌលរបស់លោកគ្រូអ្នកគ្រូនៅតាមវិទ្យាល័យនៅក្នុងខេត្តតាកែវ លើមុខវិជ្ជាឯកទេសភាសាអង់គ្លេសតែប៉ុណ្ណោះ។ ដោយសារតែពេលវេលាមានកំណត់ដើម្បីឲ្យការសិក្សាស្រាវជ្រាវមានភាពជាក់លាក់ និងលទ្ធផលអាចយកជាការបានខ្ញុំបាទសម្រេចចិត្តធ្វើការសិក្សាស្រាវជ្រាវដោយប្រើកម្រងសំណួរដែលបានកំណត់រួចចំនួន៣ប្រភេទទៅលើមុខវិជ្ជាឯកទេសភាសាអង់គ្លេស និងការចូលសង្កេតដោយផ្ទាល់ទៅលើការបង្រៀននិងរៀនរបស់លោកគ្រូអ្នកគ្រូកម្រងសំណួរសម្រាប់គ្រូ សិស្ស និងកម្រងសំណួរសម្រាប់សម្ភាសន៍នាយក/នាយិកាសាលា នៅសាលាគោលដៅដែលបានគ្រោងទុកតែប៉ុណ្ណោះ។

### ១.៦.២ ដែនកំណត់នៃការស្រាវជ្រាវ

ចំពោះភាគសំណាកនៃការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសយកខេត្តតាកែវជាគោលដៅដោយយកសិស្សមធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី១១។ ក្នុងចំណោមស្រុកទាំង៩និងក្រុង១នៃខេត្តតាកែវ អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសយកស្រុកទ្រាំងហើយ ស្រុកទ្រាំងជ្រើសរើសយក៣វិទ្យាល័យ គឺវិទ្យាល័យសុខអានព្រៃសណ្តែក វិទ្យាល័យ សុខ អានថ្នល់បំបែក និងវិទ្យាល័យសុខ អានខ្វាវ ហើយក្នុង១វិទ្យាល័យជ្រើសរើស២ថ្នាក់។

អ្នកស្រាវជ្រាវបានប្រើប្រាស់ភាគសំណា៣ប្រភេទគឺៈ

១. នាយក/នាយិកា នាយករង/នាយិការង នៅសាលាមធ្យមសិក្សាទុតិយភូមិ នៃវិទ្យាល័យ។

២. លោកគ្រូ អ្នកគ្រូបង្រៀនភាសាអង់គ្លេស ថ្នាក់ទី១១ នៅតាមវិទ្យាល័យនៅក្នុងខេត្តតាកែវ ដែលបានជ្រើសរើស។

៣. សិស្សានុសិស្សថ្នាក់ទី១១ នៅក្នុងសាលាដែលបានជ្រើសរើសពីរថ្នាក់ ថ្នាក់វិទ្យាសាស្ត្រពិតមួយថ្នាក់ និងថ្នាក់វិទ្យាសាស្ត្រសង្គមមួយថ្នាក់។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានបែងចែកជា ៥ ជំពូកដូចខាងក្រោម៖

**ជំពូក១៖ សេចក្ដីផ្ដើម** នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានលើកឡើងពី លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការសិក្សាស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវលើប្រធានបទ "**ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១១)ក្នុង ខេត្តតាកែវ** " ។

**ជំពូក២៖ រំលឹកទ្រឹស្ដី** នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានប្រមូលយកទ្រឹស្ដីរបស់អ្នកប្រាជ្ញលិខិតបទដ្ឋានគតិយុត្តិសំខាន់ៗ ទ្រឹស្ដីចាស់ៗ ពីអ្នកសិក្សាស្រាវជ្រាវមុនៗ និងឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងវិធីសាស្ត្របង្រៀន និងរៀនជាពិសេសគោលវិធីសិស្សមណ្ឌលដើម្បីឲ្យការបង្រៀន និងរៀនក្នុងសាលាកាន់តែល្អប្រសើរឡើង។

**ជំពូក៣៖ វិធីសាស្ត្រស្រាវជ្រាវ** នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញនូវឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ វិធីសាស្ត្រក្នុងការជ្រើសរើសសំណាក និងប្រភេទសំណាកព្រមទាំងវិធីសាស្ត្រក្នុងការវិភាគទិន្នន័យរកតម្លៃមធ្យម និងភាគរយតាមរយៈកម្មវិធី SPSS និងកម្មវិធី Ms. EXCEL សម្រាប់សង់ក្រាហ្វិក និងផ្គុំទិន្នន័យបញ្ចូលគ្នា។

**ជំពូក៤៖ លទ្ធផលនៃការស្រាវជ្រាវ** នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងលើកឡើងពីលក្ខណៈជាក់ស្ដែងដែលបានធ្វើការសិក្សាស្រាវជ្រាវ នឹងយកទិន្នន័យដែលប្រមូលបានមកធ្វើការវិភាគ និងធ្វើការបកស្រាយឲ្យបានយ៉ាងក្បោះក្បាយ ដើម្បីរកឲ្យឃើញនូវចំណុចល្អ ចំណុចដែលត្រូវកែលម្អនៅក្នុងបរិបទជាក់ស្ដែង ក្នុងគោលបំណងវិភាគឲ្យឃើញចំណុចខ្វះខាត បញ្ហាប្រឈម ដើម្បីធ្វើការកែលម្អឲ្យកាន់តែល្អប្រសើរឡើង។

**ជំពូក៥៖ សេចក្ដីសន្និដ្ឋាន និងសំណូមពរ** ជាផ្នែកមួយដែលអ្នកសិក្សាស្រាវជ្រាវត្រូវធ្វើការសន្និដ្ឋានលើចំណុចរួមទាំងអស់ដែលបានវិភាគ និងផ្ដល់ជាយោបល់ ជាសំណូមពរទៅលើចំណុចដែលត្រូវកែលម្អ

ទាក់ទងទៅនឹងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ នឹងធ្វើការសំណូមពរដល់ក្រសួងអប់រំ យុវជន និងកីឡា និងស្ថាប័នពាក់ព័ន្ធជួយជម្រុញការផ្សព្វផ្សាយ បញ្ជ្រាប បំប៉ន បណ្តុះបណ្តាល នូវវិធីសាស្ត្របង្រៀនថ្មីៗ ជាពិសេសវិធីសាស្ត្របង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌលឲ្យបានទូលំទូលាយ និងមានប្រសិទ្ធភាព ដើម្បីធានាបាននូវគុណភាពអប់រំ ឆ្លើយតបទៅនឹងការអប់រំ នាសតវត្សរ៍ទី២១នេះ។

# ជំពូកទី២

# រំលឹកទ្រឹស្តី

# ជំពូក២

# រំលឹកទ្រឹស្តី

## ២.១ និយមន័យពាក្យគន្លឹះ

### ២.១.១ វិធីសាស្ត្របង្រៀន

វិធីសាស្ត្របង្រៀន ជារបៀបបង្រៀន ល្បិចបង្រៀន មធ្យោបាយ ការគួបផ្សំនៃរបៀបធ្វើការរួមរបស់សាស្ត្រាចារ្យ និងសិស្សក្រោមតួនាទីដឹកនាំរបស់សាស្ត្រាចារ្យ សំដៅប្រតិបត្តិឲ្យបានល្អលើគ្រប់ភារកិច្ចនៃការបង្រៀន(**ចាន់ វឌ្ឍសុផា, ២០០៤**)។ម្យ៉ាងទៀត វិធីសាស្ត្របង្រៀនជាមគ្គុទេសធ្វើឲ្យការងាររបស់គ្រូ និងសិស្សក្រោមការដឹកនាំរបស់គ្រូ សិស្សស្គាល់បាននូវចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសព្វព្រមទាំងពង្រីកសតិបញ្ញារបស់សិស្សសំដៅប្រតិបត្តិលើគ្រប់ភារកិច្ចនៃការបង្រៀន(**ចាន់ វឌ្ឍសុផា, ២០០៤**)។ គោលដៅធំបំផុតនៃការបង្រៀន និងរៀន គឺធ្វើឲ្យអ្នកសិក្សាទទួលបានលទ្ធផលល្អហើយដើម្បីសម្រេចគោលបំណងនេះការបង្រៀន និងរៀនត្រូវពឹងផ្អែកជាចម្បងទៅលើវិធីសាស្ត្របង្រៀន។ បើគ្រូប្រើវិធីសាស្ត្របង្រៀនបានសមស្រប នោះការបង្រៀន និងរៀននឹងទទួលបានលទ្ធផលល្អ។ ផ្ទុយទៅវិញបើគ្រូប្រើប្រាស់វិធីសាស្ត្របង្រៀនមិនបានសមស្របនោះនឹងមិនអាចសម្រេចវត្ថុបំណងមេរៀនបានឡើយ។ យើងដឹងហើយថា ពុំមានវិធីសាស្ត្រណាល្អបំផុតដាច់គេនោះទេ ពោលគឺវិធីសាស្ត្រណាក៏មានចំណុចល្អដែរ។ ចំណុចសំខាន់ត្រង់ថាអ្នកអនុវត្ត ចេះច្នៃប្រឌិតយកមកប្រើប្រាស់ឲ្យសមស្របនឹងកាលៈទេសៈ។ ដូចនេះក្នុងដំណើរការបង្រៀន និងរៀនគ្រូត្រូវប្រើវិធីសាស្ត្រឲ្យបានសមស្របនឹងសង្គមបរិយាកាស ជាពិសេសគប្បីយកចិត្តទុកដាក់ទៅលើវិធីសាស្ត្រដែលទំនើបមានលក្ខណៈបច្ចុប្បន្នភាព និងប្រសិទ្ធភាព ដើម្បីឲ្យលទ្ធផលសិក្សារបស់សិស្សឆ្លើយតបទៅនឹងសង្គមបរិយាកាស( ចាន់ វឌ្ឍសុផា, ២០០៤ )។

### ២.១.២ ការបង្រៀន និងរៀន

**ការបង្រៀន ៖** ពាក្យថាការបង្រៀន( Teaching ) ក្លាយមកពីពាក្យបង្រៀន( Teach ) គឺសំដៅលើ ដំណើរការក្នុងថ្នាក់រៀនមួយដែលមានការចូលរួមពីគ្រូ ហើយមានអន្តរកម្មជាមួយសិស្ស ដែលក្នុងនោះសិស្សគឺជាអ្នកទទួលបាននូវឥទ្ធិពលពីដំណើរការនេះ ។ បើតាមលោក Calfee , 1986 បានលើកឡើងថា

ការបង្រៀន គឺជាការពន្យល់ (Teaching is explanation) គឺមានន័យថាគ្រូមានតួនាទីក្នុងការបង្ហាញផ្លូវដល់សិស្ស គ្រូជាអ្នកណែនាំ។ ក្នុងសេចក្ដីពន្យល់របស់គាត់បានកំណត់ថា ការពន្យល់ល្អ គឺពិតជាមានសារៈសំខាន់ណាស់ក្នុងដំណើរការបង្រៀន ព្រមជាមួយនឹងវិធីសាស្ត្របង្រៀនដែលល្អផងដែរ ដែលគ្រូត្រូវអនុវត្ត ( Using Explanation as a Teaching Method: How Prepare Are High School Technology in Free State Province, South Africa?, Kamla-Raj 2014) ។

**ការរៀន** ៖ ការរៀន គឺជាការសិក្សា ការសង្កេតឲ្យចេះ ការស្រូបទទួលយកនូវចំណេះដឹងថ្មី ការហ្វឹកហាត់ ការអនុវត្ត ការធ្វើសកម្មភាពដើម្បីទទួលបានបំណិន ឬជាដំណើរការដើម្បីទទួលចំណេះដឹង បំណិន ឥរិយាបថ សីលធម៌ផ្សេងៗ។ សិស្សជាអ្នកធ្វើសកម្មភាពនៅក្នុងដំណើរការសិក្សារៀនសូត្រ ដើម្បីយល់នូវអត្ថន័យមេរៀនតាមឥន្ទ្រីយ៍របស់ខ្លួនហើយទទួលបានបទពិសោធន៍ថ្មីតាមរយៈការអនុវត្តផ្ទាល់ (Kingsley and R. Garry, 1957)។ ការរៀន គឺជាឥទ្ធពលដែលនាំឲ្យមានការផ្លាស់ប្ដូរឥរិយាបថជាអចិន្ត្រៃយ៍កើតឡើងជាលទ្ធផលនៃការអនុវត្ត (Kimble, 1961)។ ការរៀន គឺជាការទាញយកនូវឥរិយាបថថ្មី ឬជាការធ្វើឲ្យប្រសើរឡើងនូវចំណុចខ្សោយ ព្រមទាំងពង្រឹងនូវចំណុចខ្លាំងដែលទទួលបានតាមរយៈបទពិសោធន៍(Henry P. Smith, 1962)។ បើតាមលោក Garder Murphy, 1968 បានឲ្យនិយមន័យការរៀនថា ការរៀន គឺគ្រប់ដណ្ដប់ទៅលើឥរិយាបថដើម្បីឲ្យត្រូវជាមួយនឹងបរិស្ថានដែលនៅជុំវិញខ្លួន។ ការរៀនផ្ដោតសំខាន់ទៅលើសម្បទាឬបញ្ញា និងការយល់ដឹងពីរបៀបដែលបុគ្គលិកលក្ខណៈរបស់មនុស្សមានឥទ្ធិពលទៅលើរបៀបដែលពួកគេមានប្រតិកម្មដោយខ្លួនឯងផ្ទាល់ហើយឆ្លើយតបគ្នាក្នុងមជ្ឈដ្ឋានរៀនសូត្រ។ ការរៀនមានច្រើនរបៀប ប៉ុន្តែគម្រូនៃការរៀនសូត្រគឺផ្អែកទៅលើការងារ និងបទពិសោធន៍នៃសកម្មភាពផ្ទាល់ខ្លួន។ តាមរយៈការរៀនរបស់សិស្សត្រូវបានអង្គការយូណេស្កូ ( UNESCO, Jacques Delor, 1996,Unesco ) ពណ៌នាអំពីមុខនាទីនៃការរៀនមានដូចជា៖

- រៀនដើម្បីដឹង ( Learn to know)
- រៀនដើម្បីចេះទទួលខុសត្រូវ ( Learn to response )
- រៀនដើម្បីចេះរស់នៅជាមួយគ្នា ( Learn to live together )

- រៀនដើម្បីអនុវត្ត ( Learn to do )

**ការបង្រៀន និងរៀន**គឺជាលំនាំនៃសកម្មភាពដែលមានគោលបំណង មានផែនការច្បាស់ លាស់ មានការរៀបចំត្រឹមត្រូវរវាងគ្រូ និងសិស្ស សំដៅធ្វើឲ្យសិស្សទទួលបានចំនេះដឹង បំណិន និងឥរិយាបថវិជ្ជមាន(ចាន់ វេ្ឋសុផា, ២០០៤)។

**លំនាំនៃការបង្រៀន និងរៀនៈ** គឺជាសំណុំនៃសកម្មភាពរវាងគ្រូនិងសិស្សដែលមានគ្រូជាអ្នកដឹកនាំសកម្មភាពសិស្សជាអ្នកអនុវត្តសកម្មភាពសំដៅក្តាប់បានប្រព័ន្ធចំណេះដឹង បំណិន និងឥរិយាបថវិជ្ជមាន( ចាន់ វេ្ឋសុផា, ២០០៤)។

### ២.១.៣ គោលវិធីសិស្សមជ្ឈមណ្ឌល

គោលវិធីសិស្សមជ្ឈមណ្ឌល គឺជាវិធីបង្រៀនមួយដែលត្រូវបានគេអនុវត្តជាទូទៅក្នុងពិភពលោក។ ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលនេះសំដៅធ្វើឲ្យឆ្លើយតបទៅនឹង សាកលភាវូបនីយកម្មលើផ្នែកវិធីសាស្រ្តបង្រៀននិងរៀន ដែលជាស្នូលដ៏សំខាន់មួយសម្រាប់ការលើកកម្ពស់វិស័យគុណភាពអប់រំនៅកម្ពុជា ។

*អត្ថន័យគោលវិធីសិស្សមជ្ឈមណ្ឌល*

គោលវិធីសិស្សមជ្ឈមណ្ឌល គឺជាលំនាំនៃការរៀននិងបងរៀនមួយដោយផ្តោតទៅលើសកម្មភាពសិស្សជាមូលដ្ឋាន។ នៅក្នុងគោលវិធីសិស្សមជ្ឈមណ្ឌលទាមទារឲ្យសិស្សមានតួនាទីជាអ្នកធ្វើសកម្មភាពស្វែងយល់ដើម្បីឈានទៅរកបេកគំហើញខ្លឹមសារណាមួយដោយខ្លួនឯងក្រោមការជំរុញនិងសម្របសម្រួលណែនាំរបស់គ្រូ សំដៅឲ្យសិស្សសម្រេចបាននូវការកសាងចំនេះដឹង បំណិន និងឥរិយាបថវិជ្ជមាន។ ក្នុងគោលវិធីនេះ សិស្សអាចធ្វើសកម្មភាពសិក្សាស្វែងយល់ជាបុគ្គល ជាដៃគូ ជាក្រុមតូច និងក្រុមធំ។ ក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលសកម្មភាពសិស្ស និងសកម្មភាពគ្រូត្រូវផ្សារភ្ជាប់គ្នាយ៉ាងជិតស្និតមិនអាចខ្វះបាន (នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ, ២០០៦)។ ការស្រាវជ្រាវផ្សេងទៀតបានបង្ហាញពីបញ្ញត្តិនេះថា "គោលវិធីសិស្សមជ្ឈមណ្ឌល គឺជាវិធីបង្រៀនដែលគ្រូជាអ្នកសម្របសម្រួលដល់ការសិក្សារបស់សិស្សដោយផ្តល់រចនាសម្ព័ន្ធនិងដឹកនាំផ្លូវសិស្ស"។ មួយវិញទៀតនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ,២០០៨ គោលវិធីសិស្សមជ្ឈមណ្ឌល គឺជាវិធីឬរបៀបមួយនៃការបង្រៀន និងរៀន ដែលគ្រូទុកឱកាសឲ្យសិស្សបាន

ធ្វើសកម្មភាពជាច្រើនដោយផ្ទាល់។ ការបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌលតម្រូវឲ្យគ្រូចាត់ទុកសិស្សជាមជ្ឈមណ្ឌលនៃសកម្មភាពគ្រូដោយគ្រូ ត្រូវផ្ដល់ឱកាសឲ្យសិស្សទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួនដោយផ្អែកលើតម្រូវការ និងការយល់ដឹងរបស់ខ្លួនឯង។ គ្រូគ្រាន់តែមានតួនាទីសម្របសម្រួល និងណែនាំតម្រង់ផ្លូវដល់សិស្សដើម្បីឈានទៅស្វ័យអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់ខ្លួនដូចជា៖

១. បង្កលក្ខណៈឲ្យសិស្សមានសមត្ថភាពឬចូលរួមក្នុងការសិក្សាដោយរីករាយ

២. បង្កឲ្យសិស្សមានទំនាក់ទំនងជាក់លាក់ និងសកម្មភាពប្រកបដោយអត្ថន័យត្រឹមត្រូវដែលជាគន្លឹះនាំឲ្យសិស្សយល់ និងមានបទពិសោធន៍ច្បាស់លាស់

៣. ឲ្យសិស្សមានការអភិវឌ្ឍលើបំណិនគិត ការស្វែងយល់ពីសង្គម និងឥរិយាបថ

៤. ជម្រុញទឹកចិត្តភាពក្លាហាន មានស្មារតីទទួលខុសត្រូវ គំនិតច្នៃប្រឌិត សាមគ្គីភាព ចេះរួមរស់ជាមួយអ្នកដទៃ។

**គោលបំណងនៃការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល**

ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលមានគោលបំណងសំខាន់ចាំបាច់ឲ្យសិស្ស៖

- ចូលចិត្ត និងចាប់អារម្មណ៍លើការសិក្សា
- មានការអភិវឌ្ឍពីមួយថ្ងៃ ទៅមួយថ្ងៃ
- ចូលរួមយ៉ាងសកម្មលើការសិក្សារបស់ខ្លួន
- យល់ថាខ្លួនជាមនុស្សមានតម្លៃ
- ដឹងថាមានគេយល់ចិត្ត នឹងអបអរសាទរចំពោះខ្លួន
- បានបញ្ចេញមតិយោបល់របស់ខ្លួន
- មានស្មារតីទទួលខុសត្រូវ
- ទទួលការហាត់រៀនឲ្យចេះរស់នៅក្នុងសហគមន៍ និងសហការជាមួយអ្នកដទៃ
- អាចបំពេញតម្រូវការនៃចំណងចំណូលចិត្តរបស់ខ្លួន

- អាចទទួលការអប់រំសោភ័ណខាងសិល្បៈ តូរ្យតន្ត្រី អក្សរសិល្ប៍ ធម្មជាតិ ចរិយាសម្បត្តិ តម្លៃអប់រំ និងគុណធម៌...
- ចេះប្រើពេលវេលាឲ្យមានប្រយោជន៍
- មានឱកាសជួយគ្នាទៅវិញទៅមក

***សារៈប្រយោជន៍នៃការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល***

ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល សំដៅឲ្យសិស្សធ្វើសកម្មភាពរៀន ដើម្បីស្វែងរកចំណេះដឹងបំណិនដោយខ្លួនឯង ជាពិសេសចង់ឲ្យសិស្សក្លាយជាមនុស្ស ចេះរស់នៅដោយខ្លួនឯងបាន ចេះទទួលខុសត្រូវនូវអ្វីដែលគេបានធ្វើចេះសហការ មានស្មារតីស្មោះត្រង់ និងមានសាមគ្គីភាពថែមទៀតផង។ ផ្អែកលើលក្ខណៈទាំងនេះសិស្សនឹងក្លាយជាមនុស្សល្អ មានមនសិការជាតិ មានការទទួលខុសត្រូវលើការងារគ្រប់គ្រង ដឹកនាំ មានអធ្យាស្រ័យល្អ មិនអត្តនោម័ត ដែលជាប្រភពលុបបំបាត់អំពើផ្តាច់ការ។ ដូច្នេះសង្គមទាំងមូល នឹងទទួលបានប្រជាធិបតេយ្យ និងសន្តិភាពដែលជាជំហានខ្ពស់បំផុត ឆ្ពោះទៅដល់ការអភិវឌ្ឍប្រទេសជាតិ( នាយកដ្ឋាន និងបណ្តុះបណ្តាល និងវិក្រិតការ,២០១៧ )។

## ២.២ ការរៀបចំការរៀន និងការបង្រៀនតាមបែបសិស្សមជ្ឈមណ្ឌល

### ២.២.១ ការរៀបចំការរៀន និងការបង្រៀន

ការបង្រៀន គឺជាសកម្មភាពមួយនៅក្នុងការជួយបណ្តុះគំនិតអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់សិស្សឲ្យមានចរិកសកម្ម និងចរិកម្ចាស់ការទំនួលខុសត្រូវប្រកបដោយការច្នៃប្រឌិតខ្ពស់ក្នុងការកំណត់វាសនានៃការសិក្សារបស់ពួកគេ ដូចទៅនឹងទស្សនៈលើកឡើងរបស់លោក រ៉ូស្សូ (១៧១២-១៨៦៦) លោក ប៉េស្តាឡូស៊ី (១៧៤៦-១៨២៧) លោក ឌីស ស្ទិវិច (១៧៩០-១៨៦៦) លោក អ៊ូជិនស្គី (១៨២៤-១៨៧០) ដែលសុទ្ធសឹងជាគរុកោសល្យវិទូដ៏ល្បីការល្បាញនៅអ៊ឺរ៉ុប(ចាន់ រដ្ឋសុផា២០០៨)។

បង្រៀន និងការរៀន គឺជាធាតុដ៏សំខាន់មួយសម្រាប់ការអភិវឌ្ឍធនធានមនុស្សមួយប្រកបដោយប្រសិទ្ធភាព និងការផ្លាស់ប្តូរ។ បានសេចក្តីថាកម្មវិធីសិក្សាជាតិមួយ និងសកម្មភាពរៀនរបស់សិស្សថា តើការបង្រៀនរបស់គាត់មានប្រសិទ្ធភាព ឬមិនមានប្រសិទ្ធភាព។ ចំពោះសិស្សវិញ គឺចាំបាច់ត្រូវលើកទឹកចិត្តឲ្យ

ចូលរួមសកម្មភាពរៀនសូត្រជាមួយគ្រូដែលសកម្មភាពនេះ ឆ្លុះបញ្ចាំងឲ្យឃើញពីការចំណាយយពេលវាលា របស់សិស្សក្នុងការសិក្សាស្រាវជ្រាវការធ្វើតេស្តវាស់កម្រិតចំណេះដឹង និងភាពជឿនលឿនរបស់សិស្សលើខ្លឹម សារនៃមុខវិជ្ជាសិក្សារួមទាំងរបៀបបង្រៀនរបស់គ្រូ និងតិចនិចនៃការបង្រៀន ជាពិសេសគឺយុទ្ធសាស្ត្រល្អៗ ក្នុងការរៀបចំ និងគ្រប់គ្រងថ្នាក់រៀន (យូណេស្កូ ២០០៥)។

ដើម្បីឲ្យដំណើរបង្រៀន និងរៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌលរបស់លោកគ្រូ អ្នកគ្រូទទួលបាន ប្រសិទ្ធភាព និងប្រកបដោយគុណភាពនោះគ្រូ នឹងសិស្សត្រូវរៀបចំដូចជា៖

- **ការចាត់តាំងសកម្មភាពរៀន និងបង្រៀន**

- រៀបចំសិស្សឲ្យអង្គុយរៀន និងពិភាក្សាដោយចម្រុះភេទ
- ណែនាំ និងសម្របសម្រួលការងារជាមួយសិស្សពេលធ្វើសកម្មភាពរៀន និងបង្រៀន
- មានសកម្មភាពសិក្សាទាំងក្នុង ឬក្រៅថ្នាក់
- បង្រៀនឡើងវិញនូវផ្នែកខ្លះដែលសិស្សមិនទាន់យល់ច្បាស់

- **ការប្រើប្រាស់សំណួរ**

- គោលដៅរបស់គ្រូបង្រៀន គឺជួយសិស្សឲ្យរៀនពីរបៀបដោះស្រាយការសម្រេចចិត្តវិនិច្ឆ័យលើតម្លៃ គិតឲ្យបានល្អិតល្អន់ប្រកបដោយភាពច្នៃប្រឌិត មានអារម្មណ៍ល្អពីខ្លួនគេ និងការសិក្សារបស់គេ ជាជាងការ បំពេញចំណេះដឹងឲ្យសិស្សដោយគ្រាន់តែផ្តល់ព័ត៌មានដែលសិស្សអាចនឹងភ្លេចទៅវិញយ៉ាងងាយ។

- គ្រូគប្បីរៀបចំសំណួរ និងប្រើយុទ្ធវិធីយ៉ាងណាដើម្បីឲ្យឆ្លើយតបទៅនឹងគោលដៅទាំងនេះពិសេស ការប្រើប្រាស់សំណួរ គឺជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងដំណើរការបង្រៀន និងរៀន។ សិស្សអាចអភិវឌ្ឍ ចំណេះដឹង បំណិន ចំណេះធ្វើ និងឥរិយាបថរបស់គេបានយ៉ាងប្រសើរ តាមរយៈការប្រើប្រាស់សំណួរដែល មានប្រសិទ្ធភាព។ ដូច្នេះមុនពេលបង្រៀន គ្រូត្រូវត្រៀមជាស្រេចនូវសំណួរផ្សេងៗទៅតាមមុខវិជ្ជាឯកទេស និងខ្លឹមសារមេរៀន។

- **ប្រភេទផ្សេងៗគ្នានៃសំណួរ**

- សំណួរមានច្រើនប្រភេទ គ្រប់ប្រភេទសំណួរសុទ្ធតែបានរួមចំណែកបង្កើនការគិតសម្រាប់សិស្ស ហើយនេះគឺជាប្រភេទសំណួរមួយចំនួនដែលគ្រូតែងប្រើប្រាស់នៅពេលបង្រៀន និងរៀន។

**សំណួរបើក៖** សំណួរប្រភេទនេះមានចម្លើយទូលាយច្រើនបែបទៅតាមការយល់ឃើញរបស់អ្នកឆ្លើយ ហើយក្នុងចំណោមចម្លើយទាំងអស់អាចមានចម្លើយត្រឹមត្រូវច្រើន។

**សំណួរបិទ៖** គេចែកសំណួរប្រភេទនេះជាពីរ គឺសំណួរបិទចម្លើយខ្លីនិងសំណួរបិទចម្លើយវែង។ សំណួរបិទចម្លើយខ្លី គឺជាប្រភេទសំណួរដែលមានចម្លើយត្រូវតែមួយ។ រីឯសំណួរបិទចម្លើយវែង គឺជាប្រភេទសំណួរដែលមានចម្លើយត្រូវតែមួយដែរ ប៉ុន្តែទាមទារឲ្យអ្នកឆ្លើយសរសេររៀបរាប់ ឬឆ្លើយផ្ទាល់មាត់វែង។

**សំណួរឆ្លាស់៖** សំណួរឆ្លាស់ ជាសំណួរដែលមានសម្រាប់ព័ត៌មានច្រើន ហើយព័ត៌មាននីមួយៗអាចជាចម្លើយខុស ឬត្រូវ ព្រម ឬមិនព្រម បាទ/ចាស់ ឬទេ។ គេប្រើប្រភេទនេះ សម្រាប់ការវាយតម្លៃ ការធ្វើតេស្ត និងការប្រលងជាដើម។

**សំណួរពហុជ្រើសរើស៖** សំណួរពហុជ្រើសរើសជាប្រភេទសំណួរដែលគេប្រាប់ចម្លើយច្រើនហើយចម្លើយត្រឹមត្រូវមានតែមួយហើយសំណួរនេះ ត្រូវបានគេប្រើប្រាស់ជាញឹកញាប់សម្រាប់ការវាយតម្លៃ ការធ្វើតេស្ត និងការប្រឡងជាដើម។

**សំណួរផ្គូរផ្គង៖** សំណួរផ្គូរផ្គង ជាប្រភេទសំណួរដែលគូសភ្ជាប់រវាងសំណួរទៅនឹងចម្លើយ ឬជាការគូសភ្ជាប់រវាងផ្នែកមួយទៅនឹងផ្នែកមួយទៀត ដើម្បីឲ្យបានចម្លើយត្រឹមត្រូវ។ គេប្រើសំណួរប្រភេទនេះសម្រាប់ការវាយតម្លៃ ការធ្វើតេស្ត និងការប្រលងជាដើម។ ក្រៅពីនេះនៅមានសំណួរមួយផ្សេងទៀត គឺសំណួរបែបបញ្ហា។

- **កម្រិតនៃការគិតរបស់សំណួរ**

ដោយយោងតាមឯកសារសម្រាប់វគ្គតម្រង់ទិស ការប្រើប្រាស់កម្មវិធីសិក្សា និងសៀវភៅសិក្សាថ្មីក្នុងដំណាក់កាលនេះ គេបានបែងចែកសំណួរជាបីកម្រិតសម្រាប់ការបង្រៀន និងរៀន។

សំណួរទាំងបីកម្រិតនេះរួមមាន ៖

- សំណួរចងចាំ
- សំណួរយល់ដឹង
- សំណួរអនុវត្ត

ដំណាក់កាលបច្ចុប្បន្ន គេបានចែកសំណួរជា៦ កម្រិតទាបបំផុតទៅកម្រិតខ្ពស់បំផុតហើយសំណួរទាំង៦កម្រិតរួមមាន ៖

- សំណួរប្រភេទចំណេះដឹងឬចងចាំ
- សំណួរប្រភេទយល់ដឹង
- សំណួរប្រភេទអនុវត្ត
- សំណួរប្រភេទវិភាគ
- សំណួរប្រភេទសំយោគ
- សំណួរប្រភេទវាយតម្លៃ។

ដូចនេះគ្រូបង្រៀនត្រូវចេះប្រើប្រាស់សំណួរឲ្យបានសមស្របទៅតាមកម្រិតយល់ដឹងរបស់សិស្សនៅក្នុងថ្នាក់រៀននីមួយៗ ស្របតាមសតវត្សរ៍ទី២១គឺត្រូវចេះ ៖

- ប្រើប្រាស់សំណួរទាំង៦កម្រិតស្របតាមកម្រិតយល់ដឹងរបស់សិស្ស នឹងខ្លឹមសារមេរៀន
- ប្រើប្រាស់សំណួរដែលមានការគិតកម្រិតខ្ពស់ញឹកញាប់
- សំណួរពាក់ព័ន្ធនឹងការប្រើប្រាស់ចំណេះដឹងប្រចាំថ្ងៃ

- **ការប្រើប្រាស់សម្ភារឧបទេសក្នុងការបង្រៀន និងការរៀន**

**សម្ភារឧបទេស**

សម្ភារឧបទេសជាមធ្យោបាយ និងជាលក្ខខណ្ឌចាំបាច់សម្រាប់ដំណើរការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព និងគុណភាព។ ដូច្នេះសម្ភារឧបទេសគឺជាធនធានទាំងឡាយដែលគ្រូនិងសិស្សយកមកប្រើប្រាស់សម្រាប់ការបង្រៀន និងរៀនដើម្បីឲ្យខ្លឹមសារមេរៀនកាន់ តែជាក់លាក់ច្បាស់លាស់ ង

យយល់ ងាយចាប់បាន ដែលអាចសម្រេចនូវវត្ថុបំណងមេរៀន។ សម្ភារត្រូវមានទាំងគ្រូទាំងសិស្ស ហើយសម្ភារឧបទេសមានលក្ខណៈទូលំទៅលាយនិងច្រើនប្រភេទណាស់។

**សារប្រយោជន៍នៃសម្ភារឧបទេស**

សម្ភារឧបទេស ជាមធ្យោបាយមួយដ៏ចាំបាច់បំផុតសម្រាប់ជួយដល់សកម្មភាពបង្រៀន និងរៀនដូចជាៈ

- ធ្វើឲ្យសិស្សចូលរួមក្នុងការសិក្សាប្រកបដោយភាពរីករាយ
- ធ្វើឲ្យថ្នាក់រៀនមានភាពរស់រវើក
- ធ្វើឲ្យសិស្សចាប់យកមេរៀនថ្មីបានងាយស្រួល
- ធ្វើឲ្យសិស្សចងចាំមេរៀនបានបានយូរ
- ធ្វើឲ្យចំណេញពេលវេលាបង្រៀន
- ធ្វើឲ្យសិស្សងាយយល់ ងាយចាំ អាចធ្វើការសន្ទនាបាន
- ជួយគ្រូឲ្យសម្រេចនូវវត្ថុបំណងមេរៀនបាន។

**ប្រភេទនៃសម្ភារឧបទេស**

សម្ភារឧបទេសមានច្រើនប្រភេទ ច្រើនបែប ច្រើនសណ្ឋានណាស់។ ដូច្នេះដើម្បីងាយស្រួលដល់ការប្រើប្រាស់ ការស្វែងរក និងការផលិត យើងអាចចែកវាជាបីប្រភេទ គឺសម្ភារធន ធានបរិស្ថាន សម្ភារអេឡិចត្រូនិច និងសម្ភារច្នៃប្រឌិត។

ដូចនេះគ្រូបង្រៀនត្រូវចេះរៀបចំទុកដាក់ ចេះផលិត និងចេះប្រើប្រាស់សម្ភារឧបទេស ឲ្យសមស្របតាមវត្ថុបំណង និងខ្លឹមសារមេរៀននីមួយៗគឺត្រូវៈ

- រៀបចំសម្ភារឧបទេស និងប្រើប្រាស់តាមលំដាប់លំដោយតាមសកម្មភាពនៃខ្លឹមសារមេរៀន
- ប្រើប្រាស់ធនធានសម្ភារៈក្នុងបន្ទប់រៀនផ្សារភ្ជាប់នឹងខ្លឹមសារមេរៀន
- ឲ្យសិស្សគ្រប់គ្នាបានប្រើសម្ភារឧបទេសក្នុងការសិក្សារៀនសូត្រ
- ការលើកទឹកចិត្តសិស្សឲ្យស្វែងរកសម្ភារឧបទេសក្នុងការរៀន

**ការប្រើប្រាស់សៀវភៅសិក្សាគោល និងឯកសារនានា**

យោងតាមការស្រាវជ្រាវរបស់លោក ចាន់ វឌ្ឍសុផា (២០០៤) បានបញ្ជាក់ថានៅក្នុងដំណើរការរៀន និងបង្រៀន សិស្សានុសិស្សត្រូវការប្រើប្រាស់សៀវភៅសិក្សាតាំងពីថ្នាក់បឋមសិក្សាឡើងទៅ។ បើកាលណាសិស្សរៀនដល់កម្រិតសិក្សាកាន់តែខ្ពស់ នោះតម្រូវការសិស្សខាងសៀវភៅសិក្សាក៏កាន់តែចាំបាច់ណាស់ ព្រោះសៀវភៅសិក្សាឆ្លុះបញ្ចាំងឲ្យឃើញនូវបទពិសោធន៍ដែលត្រូវបានធ្វើទូទៅកម្ម និងប្រព័ន្ធកម្មដែលមនុស្សជាតិបានចងក្រងទុកដោយឆ្លងកាត់ជំនាន់មនុស្សក្នុងសង្គម ហើយជាពិសេសគឺសៀវភៅសិក្សាក៏ឆ្លុះបញ្ចាំងពីបេកគំហើញថ្មីបំផុតរបស់វិទ្យាសាស្រ្ត បច្ចេកទេស អក្សរសាស្រ្តដែលជាប្រភពនៃចំណេះដឹងដ៏សម្បូរបែបប្រកបទៅដោយភាពរស់រវើកហើយអាចទាក់ទាញបាននូវអត្ថប្រយោជន៍ជាច្រើនសម្រាប់ជីវភាពពលកម្ម និងជីវភាពរស់នៅរបស់មនុស្ស។ លោកគ្រូ អ្នកគ្រូចាំបាច់ត្រូវមានសៀវភៅសិស្ស និងសៀវភៅគ្រូ ព្រោះសៀវភៅទាំងពីរនេះ គឺជាឧបករណ៍មួយដែលជាជំនួយដល់ការរៀនសូត្រ និងការបង្រៀន។

**ការរៀបចំថ្នាក់រៀន និងបរិយាកាសថ្នាក់រៀន**

- រក្សាបន្ទប់រៀនឲ្យបានស្អាត
- មានធុងដាក់សម្រាម និងចាក់វាចោលជារៀងរាល់ថ្ងៃ
- សម្អាត និងរៀបចំក្តារខៀនជារៀងរាល់ថ្ងៃ
- រៀបចំតុអង្គុយ ឬសម្ភារៈផ្សេងៗដើម្បីឲ្យសិស្សអាចរៀនតាមបែបផ្សេងៗពីគ្នា ( រៀនដោយខ្លួនឯង ជាដៃគូរ ជាក្រុមតូច ក្រុមធំ ឬថ្នាក់ទាំងមូល )
- ដាក់តាំងរូបភាព រូបគំនូរ តារាងផ្សេងៗ ផែនទី...នៅលើជញ្ជាំង
- ធ្វើ ឬដាក់តាំងរូបមន្ត ទ្រឹស្តីបទ ស្លាកសញ្ញា ប្រយោគអប់រំ
- ដាក់តាំងកិច្ចការ ឬស្នាដៃរបស់សិស្សនៅលើជញ្ជាំង
- មានសម្ភារឧបទេសសមស្របសម្រាប់មេរៀននីមួយៗទាំងគ្រូទាំងសិស្ស។

សរុបមកត្រូវរៀបចំថ្នាក់រៀនឲ្យមានបរិយាកាសគរុកោសល្យ ពោលគឺបន្ទប់រៀនមានពន្លឺគ្រប់គ្រាន់ មានខ្យល់ចេញចូល មានអនាម័យល្អ មានការតុបតែងសមស្រប ជាពិសេសគ្រូ និងសិស្សមានការទុកចិត្ត

គ្នា និងរួមសហការគ្នាបានល្អក្នុងការអនុវត្តគ្រប់សកម្មភាព ដើម្បីធ្វើឲ្យថ្នាក់រៀនមានភាពរស់រវើកពោរពេញដោយសកម្មភាព និងការយោគយល់គ្នា។

ការងារបន្តរបស់គ្រូ គឺត្រៀមលក្ខណៈដូចតទៅៈ

- ពិនិត្យ ឬវិភាគទៅលើខ្លឹមសារមេរៀនដែលត្រូវយកមកបង្រៀនសិស្ស
- ពិចារណាលើខ្លឹមសារមេរៀនជាចំណុចសំខាន់ៗដែលផ្សារភ្ជាប់ទៅនឹងខ្លឹមសារមេរៀនចាស់
- អត្ថន័យនៃពាក្យថ្មី និងខ្លឹមសារថ្មីក្នុងមេរៀនដែលគ្រូត្រូវលើកយកមកពន្យល់សិស្ស
- រៀបចំសំណួរ និងកំណត់រយៈពេលឲ្យសិស្សពិភាក្សាទៅលើសំណួរនីមួយៗ និងការសម្របសម្រួល
- ចំនួនសំណួរដែលលើកឡើងត្រូវឲ្យស៊ីគ្នានឹងរយៈពេលដែលសមស្របតាមកាលវិភាគសិក្សា
- គ្រូត្រូវត្រៀមសម្ភារឧបទេសសម្រាប់សិស្សតាមក្រុម
- គ្រូត្រូវគិតជាស្រេច ថាតើគួរឲ្យសិស្សពិភាក្សាជាក្រុមតូច ឬក្រុមធំ ឬជាដៃគូរ
- ការប្រើប្រាស់សំណួរទៅតាមកម្រិតយល់ដឹងសិស្សទៅតាមកម្រិតថ្នាក់នីមួយៗ

**ពេលចាប់ផ្តើមមេរៀនថ្មី**

- គ្រូត្រូវពន្យល់ និងណែនាំសិស្ស
- ត្រូវរៀបចំសិស្សឲ្យអង្គុយតាមក្រុម
- ដាក់កិច្ចការឲ្យសិស្សធ្វើ
- គ្រូបំផុសគំនិតឲ្យសិស្សពិភាក្សា
- ដើរពិនិត្យ អង្កេត ឬបកស្រាយចម្ងល់ដែលសិស្សបានសួរ
- គ្រូជម្រុញសិស្សម្នាក់ៗ ឲ្យស្វ័យត្រិះរិះពិចារណាដោះស្រាយចម្លើយ ស្វែងយល់ និងស្វ័យសិក្សាស្រាវជ្រាវមិនពឹងលើសមត្ថភាពរបស់មិត្តភក្តិ។

**ពេលដល់ម៉ោងកំណត់គ្រូត្រូវ**

- ហៅតំណាងក្រុមឡើងមានយោបល់ ឬសរសេរចម្លើយលើក្តារខៀន
- ឲ្យក្រុមផ្សេងទៀតជួយត្រួតពិនិត្យ និងកែលម្អ

- ជួយសម្របសម្រួល និងកែចម្លើយ
- ឲ្យសិស្សកត់ត្រាចម្លើយ សម្រាប់ទុកជាមេរៀន

**ពេលពិភាក្សាចប់សំណួរទាំងអស់គ្រូត្រូវ**

- ធ្វើការបូកសរុប និងវាយតម្លៃលើចម្លើយបានមកពីការពិភាក្សាតាមក្រុម
- ផ្តល់ព័ត៌មានត្រឡប់ឲ្យសិស្សបានទាន់ពេលវេលា
- លើកទឹកចិត្តសិស្ស និងស្នាដៃសិស្សដែលពិភាក្សាបានល្អ និងមានវិន័យល្អ
- បំផុសគំនិតសិស្សឲ្យចង់រៀនទៅទៀត
- បង្ហាញ ឬនិយាយប្រាប់ពីអត្ថន័យសំខាន់នៃការសិក្សាស្រាវជ្រាវ
- បំផុសគំនិតសិស្សខ្សោយឲ្យរៀនទាន់សិស្សមធ្យម
- នៅក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលគ្រូត្រូវតែត្រៀមចម្លើយគ្រប់សំណួរទាំងអស់
- លើក្រដាសមួយសន្លឹកដោយឡែក ភ្ជាប់ជាមួយកិច្ចតែងការបង្រៀន។

**ក្រោយពេលបង្រៀន ឬរៀនចប់**

ពេលចប់ម៉ោងបង្រៀន ត្រូវធ្វើឲ្យលទ្ធផលនៃការអនុវត្តតាមគោលដៅ និងសំណូមពររបស់មេរៀនលេចធ្លោឡើង។ ដូចនេះនៅពេលចប់ម៉ោងបង្រៀនសាស្ត្រាចារ្យអាចដាក់លំហាត់ឲ្យសិស្សធ្វើសំដៅអនុវត្តចំណេះដឹងដែលទើបបានរៀនរួច ឬលំហាត់ស្រាវជ្រាវសម្រាប់ពង្រឹងចំណេះដឹងរបស់សិស្ស។

**កិច្ចការផ្ទះ និងកំណែ**

កិច្ចការផ្ទះជាផ្នែកចុងក្រោយបង្អស់នៃសកម្មភាពបង្រៀន និងរៀននៅក្នុងថ្នាក់។ កិច្ចការផ្ទះគឺជាការងារក្រៅថ្នាក់ដែលគ្រូដាក់ឲ្យសិស្សអនុវត្ត ស្រាវជ្រាវ ដើម្បីពង្រឹងសមត្ថភាពបន្ថែម ដើម្បីទទួលបានលទ្ធផលត្រឡប់នៃការឆ្លុះបញ្ចាំងពីប្រសិទ្ធភាពនៃការរៀន និងការបង្រៀន។

កិច្ចការដែលគ្រូគួរដាក់ឲ្យសិស្សធ្វើ និងត្រូវសមស្របនឹងសមត្ថភាពសិស្ស កម្រិតថ្នាក់ និងមូលដ្ឋានរស់នៅជាក់ស្តែងមានបីប្រភេទគឺៈ

- ប្រភេទអនុវត្ត

- ប្រភេទរៀបចំ
- ប្រភេទស្រាវជ្រាវ

**ការវាយតម្លៃ និងលទ្ធផលសិក្សារបស់សិស្ស**

- សំណួរសរសេរ
- ឡើងធ្វើលំហាត់
- ឲ្យសិស្សពន្យល់បកស្រាយអ្វីមួយ
- សកម្មភាពពិភាក្សាតាមក្រុម
- រាល់ការវាយតម្លៃ និងការដាក់ពិន្ទុដល់សិស្សម្នាក់ៗត្រូវប្រកបដោយតម្លាភាព និងយុត្តិធម៌។

**២.២.២ មូលដ្ឋានទ្រឹស្តីនៃការរៀន និងការបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល**

នាយកដ្ឋានបណ្តុះបណ្តាលនឹងវិក្រឹតការ ២០០៦ បានលើកឡើងថា ដើម្បីធ្វើឲ្យការបង្រៀន និងរៀនមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អដោយលើកឡើងនូវទ្រឹស្តីមួយចំនួនៈ

**ទ្រឹស្តីអភិវឌ្ឍនិយមៈ** ពួកអ្នកអភិវឌ្ឍនិយម បានលើកឡើងនូវទ្រឹស្តីដែលមាន៥ចំណុចសំខាន់ៗ សម្រាប់គ្រូអនុវត្តនៅពេលដឹកនាំមេរៀននោះគឺៈ

ការបង្រៀនត្រូវជួយសិស្សឲ្យអភិវឌ្ឍលើគ្រប់វិស័យ ផ្លូវកាយ ផ្លូវចិត្ត ផ្លូវបញ្ញាស្មារតី និងសង្គម។ គោលបំណងនៃការបង្រៀន គឺបណ្តុះគំនិតប្រជាធិបតេយ្យដល់សិស្សឲ្យចេះស្គាល់ខ្លួនឯងស្គាល់សង្គមដែលខ្លួនកំពុងរស់នៅ និងចេះសម្របខ្លួនក្នុងការរស់នៅតាមការប្រែប្រួលនៃសង្គមពិសេសត្រូវចេះដោះស្រាយបញ្ហាប្រកបដោយការច្នៃប្រឌិតដើម្បីចូលរួមអភិវឌ្ឍសង្គមនោះផង។

គ្រូជាអ្នកសម្របសម្រួល ជួយជ្រោមជ្រែង ជួយណែនាំ គ្រប់គ្រងវិន័យ និងជម្រុញសិស្សឲ្យចេះត្រិះរិះពិចារណា ច្នៃប្រឌិត ដើម្បីដោះស្រាយចមម្ងល់ដោយខ្លួនឯង។ ទីបំផុតគ្រូត្រូវធ្វើការបូកសរុប និងសំយោគចំណេះដឹងឲ្យសិស្ស។

គ្រូផ្តល់ចំណេះដឹងឲ្យសមស្របទៅនឹងចំណង់ចំណូលចិត្ត និងតម្រូវការរបស់សិស្សពិសេសត្រូវឲ្យពាក់ព័ន្ធដល់ជីវភាពរស់នៅផ្ទាល់របស់គេផង។

ការរៀនសូត្រគឺជាសកម្មភាពស្រាវជ្រាវស្វែងយល់ពីបញ្ញត្តិ ទស្សនៈថ្មីៗ តាមរយៈការដកស្រង់បទពិសោធន៍ ការរៀនគឺជាការពិភាក្សាគ្នា ស្វែងយល់ និងជួយគ្នាទៅវិញទៅមក។ រៀនគឺផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែង។ រៀនគឺឡើងបញ្ចេញយោបល់ ចេះការពារគំនិតខ្លួនឯង និងចេះទទួលយកនឹងគាំទ្រគំនិតអ្នកដទៃ ព្រមទាំងចេះជំទាស់នឹងគំនិតអ្នកដទៃផង។

**ទស្សនៈកសាងចំណេះដឹង៖** ទស្សនៈនេះបានលើកឡើងថា

- ការរៀន គឺការថែបំប៉នការអភិវឌ្ឍ និងការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈរបស់ខ្លួនឲ្យមានលក្ខណៈសម្បត្តិសមស្រប

- គ្រូបង្រៀនត្រូវមានសាមគ្គីភាពជាមួយនឹងគ្រូបង្រៀនឯទៀត ចេះយកចិត្តទុកដាក់លើបញ្ហាសង្គម និងរួមចំណែកដោះស្រាយបញ្ហាសង្គម និងចេះណែនាំសិស្សឲ្យចេះរស់នៅក្នុងសង្គម។

- ការបង្រៀន គឺជាការនាំសិស្សតាមបែបប្រជាធិបតេយ្យពិសេសត្រូវទុកឱកាសឲ្យសិស្សចេះត្រិះរិះពិចារណាចេះវិភាគវែកញែកចេះបញ្ចេញយោបល់ចេះទាញហេតុផល សមស្របសម្រាប់ការពារយោបល់របស់ខ្លួនចេះទាញសេចក្តីសន្និដ្ឋាន។

- សិស្សរៀន ដើម្បីចេះមើលឃើញប្រយោជន៍រួមធំជាងប្រយោជន៍បុគ្គល ចេះសាមគ្គីរួមរស់ជាមួយអ្នកឯទៀត ដើម្បីមូលហេតុសង្គម និងប្រទេសជាតិ។

**ទស្សនៈអត្ថិភាពនិយម ៖** តាមទស្សនៈពួកអត្ថិភាពនិយមក្នុងពិភពលោកទាំងមូល មានភាវៈអាថកំបាំងសព្វបែបយ៉ាងច្រើនអនេក ហើយដែលមនុស្សមិនអាចយល់បាន។ ហេតុនេះមនុស្សត្រូវខិតខំសិក្សាស្វែងយល់ឲ្យបានទូលំទូលាយ និងស៊ីជម្រៅ។ មនុស្សមានឱកាសច្រើនក្នុងការជ្រើសរើស និងសិក្សាមុខវិជ្ជាផ្សេងៗ ដោយខ្លួនឯង ដើម្បីស្វែងយល់ពីអ្វីៗដែលខ្លួនចង់ដឹងប្រសើរជាងរងចាំទទួលការបណ្តុះបណ្តាលពីអ្នកឯទៀត។ ទ្រឹស្តីបទនេះបានលើកឡើងថា ៖

- ការរៀនមានទិសដៅស្វ័យអភិវឌ្ឍន៍ប្រកបដោយឥស្សរភាព និងស្មារតីទទួលខុសត្រូវ។
- ការបង្រៀន ត្រូវទុកឲ្យសិស្សមានលទ្ធភាពជ្រើសរើសចំណេះដឹងដោយខ្លួនឯង។
- ក្នុងលំនាំនៃការបង្រៀនគ្រូត្រូវចេះបង្កបរិយាកាសរៀនសូត្រដោយទុកឱកាសឲ្យ

- សិស្សរៀនសូត្រទៅតាមបំណិនឧបនិស្ស័យ និងចំណង់ចំណូលចិត្តរបស់ខ្លួនគេផ្ទាល់។

ទន្ទឹមនឹងនេះគ្រូត្រូវចេះបំផុសគំនិតសិស្សដើម្បីឲ្យមានលទ្ធភាពឈានទៅរកគោលដៅដោយខ្លួនឯង។

**ទស្សនៈមនុស្សនិយម៖** តាមទស្សនៈនេះបានឲ្យតម្លៃខ្ពស់ទៅលើសមត្ថភាពរបស់មនុស្សដោយបានលើកឡើងថា ៖

- មនុស្សកើតមកសុទ្ធតែល្អពីកំណើត គេមានសមត្ថភាពដែលអាចដឹកនាំខ្លួនឯង និងពឹងពាក់ខ្លួនឯងបានដោយម្ចាស់ការ
- មនុស្សមានសេរីភាពក្នុងការជ្រើសរើសអ្វីដែលគេចង់បាន
- ការបង្រៀនត្រូវធ្វើឲ្យសិស្សមានការអភិវឌ្ឍវិជ្ជមានបីយ៉ាង គឺចំណេះដឹង បំណិន និងឥរិយាបថ។

ក្រៅពីទស្សនៈមួយចំនួន ដែលជាមូលដ្ឋានទ្រឹស្តីនៃគោលវិធីសិស្សមជ្ឈមណ្ឌលបានរៀបរាប់ខាងលើនូវមានទស្សនៈរបស់ទស្សនវិទូឬគរុកោសល្យជាច្រើនផ្សេងៗទៀត ដែលនិយាយពីគោលវិធីសិស្សមជ្ឈមណ្ឌលដូចជា៖

- **លោក** Albert Einstein(**១៨៧៩-១៩៥៥**) ដែលជារូបវិទូជនជាតិអាឡឺម៉ង់បាននិយាយថា″ ខួរក្បាលរបស់ខ្ញុំមិនពូកែទេ តែពូកែប្រើខួរក្បាល ″។ ពាក្យមួយឃ្លានេះមានន័យថាមនុស្សណាក៏អាចឈ្លាសវៃបានដែរ ឲ្យតែគេចេះប្រើខួរក្បាលឲ្យធ្វើការ។ ភាពឈ្លាសវៃរបស់មនុស្ស គឺជាអំណោយពីធម្មជាតិ បើអាចនឹងមានមនុស្សដែលមានខួរក្បាលមិនល្អពីកំណើតដោយមូលហេតុនៃការប្រព្រឹត្តខុសឆ្គងរបស់ស្ត្រីជាម្តាយនៅពេលមានផ្ទៃពោះ ប៉ុន្តែបើជាករណីធម្មតាមនុស្សមានខួរក្បាលប៉ុនគ្នាដែលអាចនឹងវិវត្តទៅរកភាពឈ្លាសវៃដូចៗគ្នា។ ខួរក្បាលដូចជាសាច់ដុំដូច្នោះដែរ បើសាច់ដុំដែលត្រូវបានប្រើប្រាស់ជាអចិន្ត្រៃយ៍គឺជាសាច់ដុំដែលពូកែផ្ទុយទៅវិញ ប្រសិនបើយើងទុកវាចោលមិនបានប្រើប្រាស់មិនឲ្យវាធ្វើលំហាត់ទេ នោះវានឹងចុះខ្សោយ។ ខួរក្បាលដែលមិនត្រូវបានប្រើប្រាស់ឲ្យអស់ពីសមត្ថភាព មិនឲ្យធ្វើការខ្លាំងមិនឲ្យវាធ្វើលំហាត់វាក៏មិនពូកែដែរ។ លំហាត់សម្រាប់ខួរក្បាល គឺកិច្ចការដែលពិបាកកិច្ចការដែលតម្រូវឲ្យមានការគិត។ គរុកោសល្យវិទូសម័យទំនើបបានបង្ហាញនូវគោលវិធីដែលជួយឲ្យគ្រូបង្រៀនប្រើប្រាស់នូវវិធីដែលជួយឲ្យសិស្សរៀន

កាន់តែសកម្ម រៀនដោយធ្វើសកម្មភាពទាំងរាងកាយ ទាំងខួរក្បាល។ គ្រូបង្រៀនគប្បីស្រាវជ្រាវរកវិធីថ្មីៗ ដែលជួយសិស្សឲ្យកាន់តែឈ្លាសវៃ ដោយប្រើប្រាស់ខួរក្បាលរបស់គេតាមវិធីរៀនដែលកាន់តែសកម្ម។

- **លោក សូក្រាត(៤៦៩-៣៩៩មុន គ.ស)** ជាទស្សនវិទូជនជាតិក្រិច ហើយក៏ជាជនទី១ដែលបានលើកឡើងពីវិធីសាស្ត្រនៃការផ្តល់ និងការទទួលចំណេះដឹងរបស់មនុស្ស គឺត្រូវតែផ្តើមចេញពីការត្រិះរិះពិចារណា និងបង្កើតដោយខ្លួនឯង។ ពាក្យមួយឃ្លាដែលល្បីល្បាញរបស់លោកគឺ "ម្តាយខ្ញុំជាឆ្មប សម្រាប់បង្កើតកូន ចំណែកខ្ញុំជាឆ្មបសម្រាប់បង្កើតគំនិត"។ ផ្អែកតាមគំនិតនេះ លោកប្លាតុងក៏បានដាក់ចេញនូវវិធីពីរយ៉ាងដើម្បីទទួលបាននូវចំណេះដឹង៖

- **វិធីចំអក បែបសូក្រាត៖** តាមរយៈការប្រើប្រាស់សំណួរ សិស្សអាចរកឃើញដោយខ្លួនឯងនូវអ្វីដែលគេមិនទាន់ចេះ ព្រមទាំងរកឃើញ នូវអ្វីៗដែលគេចេះហើយ(សម្រាលគំនិត) ក៏អាចឲ្យគេស្រាវជ្រាវបន្ថែមទៀតដោយខ្លួនឯងផងដែរ។ ផ្អែកលើគំនិតនេះ ក្នុងការបង្រៀន គ្រូមិនត្រូវផ្តល់ចំណេះដឹង ឬខ្លឹមសារមានស្រាប់ឲ្យសិស្សទេ ផ្ទុយទៅវិញ គ្រូត្រូវបង្កើតជាបញ្ហា ដើម្បីឲ្យសិស្សចេះដោះស្រាយរកខ្លឹមសារដោយខ្លួនឯងទើបប្រសើរ។

- **វិធីត្រិះរិះតាមបញ្ញា៖** តាមវិធីនេះ ការបង្រៀន គឺជាការធ្វើឲ្យសិស្សសម្រាលគំនិតដើម្បីបង្កើតបានចំណេះដឹងដែលមាននៅក្នុងខួរក្បាលរបស់មនុស្សម្នាក់ៗតាំងពីមិនទាន់ចូលសាលារៀន។ វិធីនេះបានរួមចំណែកយ៉ាងធំធេង ក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល តាមសាលារៀនៃនាពេលបច្ចុប្បន្ន។

- **លោក ប្លាតុង(៤២៧-៣៤៨មុន គ.ស)** បានលើកឡើងថា " ការអប់រំគឺជាការធ្វើឲ្យរស់ឡើងវិញនូវសច្ចភាព សោភ័ណភាព និងកុសល"។ នេះមានន័យថាការបង្រៀន គឺជាការជួយសិស្សឲ្យបង្កើតឡើងវិញនូវចំណេះដឹងដែលមានស្រាប់ពីមុន។ សិល្បៈគរុកោសល្យ គឺជាសិល្បៈនៃការចោទសួរ គ្រូចេះបង្រៀន គឺគ្រូចេះសួរ។ ហេតុនេះការបង្រៀនមិនមែនជាការ នាំមកនូវអ្វីៗឲ្យសិស្សដោយផ្ទាល់នោះទេ ប៉ុន្តែសិស្សត្រូវបង្ហាញឲ្យឃើញនូវអ្វីៗដែលគេមានរួចហើយផងដែរ។

- **លោក ខុង ជឺ(៥៥១-៤៧៥មុន គ.ស)** បានពោលថា " បើចង់ចេះតែមិនមានឆន្ទៈនោះ គឺមិនរីកបញ្ញានោះទេ"។ បើចង់យល់ច្បាស់ តែមិនប្រឹងប្រែងយកចិត្តទុកដាក់នោះ ក៏មិនដុះគំនិតដែរ។ ទន្ទឹមនឹង

នេះ លោកក៏បានកំណត់ថា ក្នុងលំនាំនៃការបង្រៀនគ្រូមិនត្រឹមតែធ្វើឲ្យសិស្សសប្បាយនោះទេ តែត្រូវធ្វើឲ្យសិស្សចូលចិត្តរៀនជាមួយផងដែរ។

- **លោក ហ្សង់ ហ្សាក់រូសូ(១៧១២-១៧៧៨)** ជាគរុកោសល្យវិទូបារាំង ដែលបានយកចិត្តទុកដាក់ដល់ការអភិវឌ្ឍបញ្ញា និងចរិតម្ចាស់ការរបស់សិស្សក្នុងការរៀនសូត្រតាមចិត្តចង់បានរបស់គេ។
- **លោក ចន ឡក (១៦៣០-១៧០៤)** ជាគរុកោសល្យវិទូជនជាតិអង់គ្លេសដែលបានផ្តល់ទស្សនៈពាក់ព័ន្ធនឹងគោលវិធីសិស្សមជ្ឈមណ្ឌលថា " គ្រូត្រូវផ្តល់សេរីភាពដល់សិស្សក្នុងការគិត ព្រោះគ្រូ ឬឪពុកម្តាយគ្រាន់តែជាអ្នកអប់រំបណ្តោះអាសន្នសម្រាប់ជួយកុមារឲ្យឈានដល់ស្វ័យអភិវឌ្ឍប៉ុណ្ណោះ "។
- **លោក ចន ដេវី (១៨៥៩-១៩៥២)** ជាគរុវិទូជនជាតិអាមេរិកក៏បានបង្ហាញពីទស្សនៈអប់រំគោលវិធីសិស្សមជ្ឈមណ្ឌលដ៏មានតម្លៃដូចជា៖

- សាលារៀន គឺជាបរិស្ថានអប់រំ ដែលត្រូវឆ្លើយតបទៅនឹងតម្រូវការរបស់កុមារ
- សាលារៀន ត្រូវប្រើគោលការណ៍គរុកោសល្យ ដែលតម្រូវឲ្យសិស្សបង្កើតចំណេះដឹងដោយខ្លួនឯង។

គោលការណ៍អប់រំទាំងពីរនេះទាមទារឲ្យគ្រូ៖

- គោរពភាពម្ចាស់ការរបស់សិស្ស ដោយត្រូវឲ្យសិស្សអនុវត្តផ្ទាល់ និងត្រូវបំផុសសិស្សឲ្យមានចំណូលចិត្តក្នុងការរៀនសូត្រ។
- ត្រូវគិតគូរពីចំណេះដឹងដែលមានស្រាប់របស់សិស្ស។
- វត្ថុពិតប្រាកដមួយដែលសិស្សបានប្រាស្រ័យផ្ទាល់នាំមកនូវពាក្យសម្តីច្រើនជាងការដែលសិស្សស្តាប់គេនិយាយ។
- ចំណង់ចំណូលចិត្តរបស់សិស្សគឺជាកម្លាំងចលករដែលជម្រុញឲ្យសិស្សមានទង្វើ។
- ត្រូវទុកសេរីភាពឲ្យសិស្សក្នុងការអប់រំ ព្រោះសេរីភាពនេះគឺជាសេរីភាពក្នុងក្របខណ្ឌនៃសង្គមប្រជាធិបតេយ្យ។

- **លោក កាល់ រ៉ូជ័រ(១៩០២-១៩៨៧)** ជាចិត្តវិទូជនជាតិអាមេរិក និងជាគ្រូពេទ្យផងដែរ ហើយលោកបានបង្ហាញពីទ្រឹស្តីនៃការរៀនសូត្រនៅក្នុងសៀវភៅមួយដែលមានចំណងជើងថាសេរីភាពនៃការ(Freedom

to learn 1969) ដែលនិយាយអំពីសេរីភាពរបស់សិស្សក្នុងការសិក្សារៀនសូត្រ(ការគិត ធ្វើសកម្មភាព តម្លាភាព យុត្តិធម៌ ឱកាស) និងគោលការណ៍នៃការរៀនទាំង៧ (Potential , Target , Change , Practice , Context , Engagement & Agency) ដើម្បីណែនាំដល់ការរៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌលរបស់សិស្សនៅក្នុងសម័យបច្ចេកវិទ្យា។ បន្ថែមលើសពីនេះទៀតលោកក៏បានបញ្ចេញទស្សនៈថា៖

- ការរៀនសូត្រ ត្រូវបានសម្របសម្រួលនៅពេលដែលសិស្សចូលរួមទទួលខុសត្រូវនៅក្នុងដំណើរការនៃការរៀនសូត្រនេះ។ មានន័យថានៅពេលដែលគាត់បានជ្រើសរើសទិសដៅដោយផ្ទាល់ខ្លួនរបស់គាត់ហើយនោះ វានឹងជួយឲ្យគាត់អាចស្វែងរកឃើញនូវធនធានសិក្សាស្គាល់ពីបញ្ហាផ្ទាល់ខ្លួន និងអាចធ្វើការសម្រេចចិត្តផ្ទាល់ក្នុងការធ្វើសកម្មភាពអ្វីមួយ នោះការសិក្សារៀនសូត្រនឹងត្រូវបានពង្រីកបន្ថែម។
- គ្រូត្រូវទុកពេលឲ្យសិស្សពិចារណាដោយខ្លួនឯង ដើម្បីរកចម្លើយតាមបែបកសាងចំណេះដឹងផ្ទាល់ខ្លួន។
- សិស្សត្រូវរកឲ្យឃើញនូវចំណេះដឹងដែលមានលក្ខណៈរស់រវើក និងមានលក្ខណៈវិទ្យាសាស្ត្រ។
- សិស្សត្រូវមានទំនាក់ទំនងគ្នា ដោយមិនចាំបាច់មានអ្នកដឹកនាំដោយចេះសម្របសម្រួលគ្នាហ៊ានសម្តែងចេញដោយឥតលាក់លៀមនូវអ្វីៗដែលខ្លួនចង់បាន។
- សិស្សត្រូវចេះស្តាប់មតិគ្នាទៅវិញទៅមកចេះការពារមតិខ្លួន និងគោរពអ្នកដទៃតាមលក្ខណៈប្រជាធិបតេយ្យ។
- លោក Arthur Wright comb (១៩១២-១៩៩៩) ជាចិត្តវិទូជនជាតិអាមេរិកបានមានប្រសាសន៍ថា៖
- ចំពោះមនុស្សដែលអាចធ្វើការងារមួយបានពេលខ្លះគេមិនចង់ធ្វើទេ ព្រោះគេមិនពេញចិត្តនឹងធ្វើតែគេបែរជាចង់ធ្វើការងារផ្សេងៗទៅវិញ។
- បើសិស្សមើលឃើញថា ចំណេះដឹងមានទំនាក់ទំនងដល់ផលប្រយោជន៍ដល់ជីវភាពរស់នៅរបស់គេនោះគ្រូបង្រៀនប្រាកដជាទទួលបានជោគជ័យហើយ។ តាមគំនិតនេះពេលចាប់ផ្តើមមេរៀនគ្រូត្រូវតែប្រឹងឲ្យអស់ពីលទ្ធភាពដើម្បីធ្វើឲ្យសិស្សមើលឃើញថាអ្វី ដែលគេត្រូវទទួលយកពិតជាមានប្រយោជន៍ចំពោះរូបគេហេតុនេះគេត្រូវខិតខំប្រឹងប្រែងស្វែងយល់និងទទួលយកឲ្យបាន(ចាន់ រដ្ឋសុផា, ២០០៤)។

• បើសរុបជារួមបណ្តាទស្សនៈរបស់អ្នកប្រាជ្ញល្បីៗដូចដែលបានរៀបរាប់ខាងលើ សុទ្ធតែបង្ហាញឲ្យឃើញពីការតម្លៃខ្ពស់ទៅលើសមត្ថភាពរបស់សិស្សក្នុងលំនាំនៃការបង្រៀនដែលមសនអត្ថិភាពជាយូរមកហើយ។ ទស្សនៈទាំងអស់នេះហើយដែលជាមូលដ្ឋានគ្រឹះ ក្នុងការធ្វើឲ្យមានការលេចឡើងនូវគោលវិធីអីសិស្សមជ្ឈមណ្ឌលដែលត្រូវបានក្រសួងអប់រំយកចិត្តទុកដាក់ និងដាក់ឲ្យអនុវត្តនៅក្នុងកម្មវិធីអប់រំនាពេលបច្ចុប្បន្ននេះ។

## ២.២.៣ វិធីសាស្ត្ររៀន និងបង្រៀននានាតាំងគោលវិធីសិស្សមជ្ឈមណ្ឌល

ដើម្បីសម្រេចបាននូវការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលឲ្យមានប្រសិទ្ធភាពគ្រូបង្រៀនម្នាក់ៗ ត្រូវមានគុណសម្បត្តិ និងសមត្ថភាពគរុកោសល្យគ្រប់គ្រាន់ខាងផ្នែកចិត្ត គរុកោសល្យ បច្ចេកទេស វិធីសាស្ត្របង្រៀន និងខាងផ្នែកគ្រប់គ្រងវិន័យសិស្សព្រមទាំងបានឆ្លងកាត់វគ្គបណ្តុះបណ្តាលវិក្រឹតការគ្រូបង្រៀន វគ្គសិក្ខាសាលា និងថ្នាក់និទស្សន៍លើផ្នែកវិធីសាស្ត្របង្រៀន និងធ្វើទំនើបកម្មលើវិធីសាស្ត្របង្រៀនតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌលជាមុនសិន។ វិធីសាស្ត្របង្រៀនជាពាក្យមួយសម្រាប់សម្គាល់វិទ្យាសាស្ត្រ ដែលសិក្សាអំពីវិធី និងបច្ចេកទេសមានន័យថាវិធីសាស្ត្របង្រៀនមានមុខងាររកឲ្យឃើញពីវិធី វិធីបង្រៀន និងបច្ចេកទេសឲ្យកាន់តែងាយស្រួលជាងមុន។ វិធីសាស្ត្របង្រៀនត្រូវបានកែប្រែ ផ្លាស់ប្តូរជានិច្ច ឥតឈប់ឈរពីសម័យកាលមួយទៅសម័យកាលមួយទៀតហើយសព្វថ្ងៃនេះ វិធីសាស្ត្របង្រៀនតាមបែបសិស្សមជ្ឈមណ្ឌល ជាវិធីមួយដែលកំពុងពេញនិយម និងទទួលបានការចាប់អារម្មណ៍ជាខ្លាំង តាមរយៈលទ្ធផលសិក្សារបស់សិស្ស។ វិធីនេះជាវិធីដែលសិស្សមានសកម្មភាពក្លៀវក្លា និងចាត់ទុកសិស្សជាធំ សិស្សមានឱកាសរៀនសូត្រស្វែងយល់ដោយខ្លួនឯងបានច្រើនបំផុត ដើម្បីទទួលបានចំណេះដឹងរឹងមាំ ហើយសិស្សទៀតសោតមានសមត្ថភាពគ្រប់គ្រាន់ តាមលក្ខណៈវិទ្យាសាស្ត្រ មានបំណិនស្តាប់ និយាយ អាន សរសេរ គិត វិភាគ ចេះត្រិះរិះពិចារណា។ ជាការពិតណាស់មានអង្គការភីសខ័រប្រចាំប្រទេសកម្ពុជាបានបង្ហាញពីរបាយការណ៍សមិទ្ធផលដែលសម្រេចបានក្នុងឆ្នាំ២០១៦ លើគោលដៅទី១ស្តីពីបង្កើនវិធីសាស្ត្របង្រៀនថា បង្រៀននឹងបង្កើនចំណេះដឹងភាសាអង់គ្លេស និងអនុវត្តវិធីសាស្ត្របង្រៀនតាមបែបសិស្សមជ្ឈមណ្ឌល និងគោលដៅទី២ស្តីពីការបង្កើនភាព

ជោគជ័យដល់សិស្ស ដោយបង្កើនចំណេះដឹងរបស់សិស្សតាមរយៈ ការចូលរួមសកម្មភាពសិក្សានៅក្នុងថ្នាក់ (អង្គការភីសខ័រ,២០១៦)។

**វិធីបង្រៀនតាមបែបសហការ**

វិធីបង្រៀនតាមបែបសហការ ជាវិធីបង្រៀនមួយដែលមជ្ឈដ្ឋានអ្នកអប់រំ ជាពិសេសគ្រូបង្រៀនត្រូវបាននឹងកំពុងប្រើប្រាស់នៅក្នុងការបង្រៀន និងរៀន។ តាមការសិក្សាស្រាវជ្រាវពីវិធីបង្រៀនតាមបែបសហការ គឺជាវិធីបង្រៀនមួយដែលសិស្សត្រូវចូលរួមធ្វើសកម្មភាពដោយបង្កើតកិច្ចសហប្រតិបត្តិការ និងធ្វើការងារជាក្រុមឈានទៅរកការសម្រេចចិត្តលើលទ្ធផលពិភាក្សាប្តូរយោបល់របស់សិស្សម្នាក់ៗ សំដៅជួយឲ្យផលប្រយោជន៍ក្រុមបានសម្រេចហើយវិធីបង្រៀនតាមបែបសហការនេះ ជួយឲ្យសិស្សមានទម្លាប់ចូលចិត្តពិភាក្សាប្តូរយោបល់គ្នាឲ្យពួកគាត់ធ្វើការងារជាក្រុមរួមគ្នា ដើម្បីឈានទៅរកនូវដំណោះស្រាយមួយសមហេតុសមផល។ ហើយគ្រូមានតួនាទីជាអ្នកដឹកនាំ សម្របសម្រួល ហើយអាចវាយតម្លៃសិស្សម្នាក់ៗក្នុងថ្នាក់រៀនបានយ៉ាងពិតប្រាកដ។

ការសិក្សាតាមបែបសហការមានមូលដ្ឋានសំខាន់ចំនួន៣គឺ

- កំណត់គោលដៅរបស់ការងារតាមក្រុមឲ្យបានច្បាស់លាស់
- សិស្សត្រូវចូលរួមយ៉ាងសកម្មក្នុងការបញ្ចេញមតិយោបល់ដើម្បីឲ្យការងារក្រុមសម្រេចបាន
- ជោគជ័យដែលសម្រេចបាននៅក្នុងក្រុម គឺជាជោគជ័យរបស់សមាជិកក្រុមម្នាក់ៗ។

ធាតុសំខាន់ៗទាំង៥នៃវិធីសហការគឺ៖

- ជួយគ្នាទៅវិញទៅមកក្នុងលក្ខខណ្ឌវិជ្ជមាន
- មានអន្តរកម្មចំពោះមុខគ្នាយ៉ាងសកម្ម
- មានការទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗ
- មានបំណិនសង្គម ការប្រាស្រ័យទាក់ទងគ្នាល្អ
- ការជ្រើសរើសក្រុមការងារតាមចំណូលចិត្ត។

### វិធីអនុមានរួម

វិធីអនុមានរួម ជាការរៀបចំសកម្មភាពរៀនសូត្រពីការលម្អិតទៅរក រូបមន្ត ពោលគឺវាជាការបង្រៀនពីបំណែកតូចៗទៅរកចំណុចរួម ឬបង្រៀនពីឧទាហរណ៍ទៅរករូបមន្ត គោលការច្បាស់មួយ ឬការសរុបសេចក្តីដោយផ្តល់ឱកាសឲ្យសិស្សធ្វើការសង្កេតសាកល្បងប្រៀបធៀប ហើយពិចារណាស្រាវជ្រាវរកអង្គក្រមដែលដូចគ្នា ឬខុសគ្នាពីឧទាហរណ៍ផ្សេងៗ ដើម្បីសរុបជាសេចក្តីរួម( មាឃ សារី ,២០០២ )។

### វិធីអនុមានញែក

វិធីអនុមានញែក ជាការបង្រៀនដែលចាប់ផ្តើមពីច្បាប់រួមឬគោលការណ៍ផ្សេងៗ រួចឲ្យសិស្សរកមូលហេតុមកធ្វើការពិសោធ ដើម្បីបណ្តុះបណ្តាលសិស្សឲ្យក្លាយជាមនុស្សមានហេតុផលមិនជឿអ្វីងាយៗ រហូតដល់សិស្សធ្វើការសាកល្បងអ្វីមួយរកការពិតសិន មុននឹងជឿ( មាឃ សារី ,២០០២ )។

### វិធីដោះស្រាយបញ្ហា

វិធីដោះស្រាយបញ្ហាក៏ជាផ្នែកមួយនៃវិធីសាស្រ្តបង្រៀនតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌលដែរ ដោយសារវិធីនេះ សិស្សជាអ្នកអនុវត្ត ដោះស្រាយលំហាត់ ស្រាយបញ្ជាក់រូបមន្ត ទ្រឹស្តីបទដោយផ្ទាល់ហើយវិធីនេះ អាចប្រើប្រាស់បាននូវគ្រប់មុខវិជ្ជា គ្រប់កម្រិតថ្នាក់ គ្រប់ភូមិសិក្សា។ ក្នុងការអនុវត្តដោះស្រាយ វិធីនេះមាន៥ជំហានធំៗគឺ៖

- ការរកឲ្យឃើញនូវបញ្ហា
- កំណត់បញ្ហាដែលត្រូវដោះស្រាយ
- ផ្តុំ និងរៀបចំតាមលំដាប់ថ្នាក់ និងរៀបចំយ៉ាងជាក់លាក់នូវសម្មតិកម្ម
- ទទួល ឬច្រានចូល ការស្វាបស្ទង់ ឬការសាកល្បងសម្មតិកម្ម
- រៀបចំយ៉ាងជាក់លាក់ វាយតម្លៃ និងធ្វើការសន្និដ្ឋាន។

## ២.៣ វិធីសាស្រ្តបង្រៀនភាសាអង់គ្លេស

គោលដៅធំបំផុតនៃការបង្រៀន និងរៀនគឺធ្វើឲ្យអ្នកសិក្សាទទួលបានលទ្ធផលល្អហើយដើម្បីសម្រេចគោលបំណងនេះ ការការបង្រៀន និងរៀនត្រូវពឹងផ្អែកជាចម្បងទៅលើវិធីសាស្រ្តបង្រៀន។ បើគ្រូប្រើបាន

សមស្របនោះការបង្រៀន និងរៀននឹងទទួលបានលទ្ធផលល្អ។ យើងដឹងហើយថា ពុំមានវិធីសាស្ត្រណាល្អបំផុតដាច់គេនោះទេ ពោលវិធីសាស្ត្រណាក៏មានចំណុចល្អរបស់វាដែរ។ អ្វីដែលសំខាន់ត្រង់ថា អ្នកប្រើប្រាស់ត្រូវចេះច្នៃប្រឌិតយកមកប្រើប្រាស់ឲ្យបានសមស្របនឹងពេលវេលា និងកាលៈទេសៈរបស់ខ្លួន ជាពិសេសគប្បីយកចិត្តទុកដាក់ទៅលើវិធីសាស្ត្រដែលទំនើបមានលក្ខណៈបច្ចុប្បន្នភាព និងប្រសិទ្ធភាព (ថៅ លិន, ២០១១)។ Elena Taralunga TAMURA(2006) បានលើកឡើងថា វិធីសាស្ត្របង្រៀនភាសាអង់គ្លេស តែងតែមានទំនាក់ទំនងទៅនឹងបញ្ហាប្រឈមចំនួនបីគឺ៖ (១) តើត្រូវបង្រៀនអ្វី? មានន័យថាមានចំនួននៃចំណេះដឹង ជំនាញ និងទម្លាប់ ដែលសិស្សចាំបាច់ត្រូវតែមានក្នុងដំណើរការរៀនភាសា។ (២) តើវត្ថុបំណងនៃការបង្រៀននេះជាអ្វី? នៅពេលដែលគ្រូប្រាកដច្បាស់ពីវត្ថុបំណងនៃការបង្រៀនរបស់ពួកគាត់គាត់នឹងមានភាពងាយស្រួលក្នុងការដើរទៅដល់គោលដៅ។ (៣) តើបង្រៀនដោយវិធីណា? មានន័យថា គ្រូត្រូវជ្រើសរើសវិធីសាស្ត្រ ម៉ូដែល តិចនិក ណាមួយដើម្បីឲ្យសម្រេចបានតម្រូវការបញ្ចប់ចុងក្រោយ។

ចំពោះការបង្រៀនភាសាអង់គ្លេស គ្រូត្រូវផ្សារភ្ជាប់ទៅនឹងទ្រឹស្តី និងវិធីសាស្ត្រផ្សេងៗគ្នាជាច្រើនដើម្បីឲ្យការបង្រៀនរបស់ខ្លួនទទួលបានលទ្ធផលល្អ។ ហើយការធ្វើឲ្យសិស្សមានសកម្មភាពច្រើន នោះការសិក្សារបស់ពួកគេក៏ទទួលបាននូវលទ្ធផលផងដែរ ក្នុងនោះគោលវិធីសិស្សមជ្ឈមណ្ឌល ក៏បានចូលរួមចំណែក អាចឲ្យសិស្សទទួលបានជោគជ័យផងដែរ។

## ២.៤ គោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនភាសាអង់គ្លេស

ក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល សកម្មភាពសិស្ស និងសកម្មភាពគ្រូត្រូវផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធមិនអាចខ្វះបាន។

តួនាទីសំខាន់របស់សិស្សរួមមាន៖

- ឆ្លើយនឹងសំណួរគ្រូជាបុគ្គលឬជាក្រុមដោយផ្ទាល់មាត់ឬដោយសរសេរ
- ដោះស្រាយបញ្ហាដែលគ្រូដាក់ឲ្យ(ជាបុគ្គល ឬក្រុម)
- ពិភាក្សាផ្លាស់ប្តូរយោបល់ក្នុងក្រុមដើម្បីរកចម្លើយ
- កត់ត្រាចម្លើយសម្រាប់យកមករាយការណ៍

- សួរគ្រូ ឬសួរសិស្សគ្នាឯងឲ្យជួយពន្យល់បន្ថែម
- ជួយពន្យល់មិត្តភក្តិក្នុងក្រុមឬពន្យល់សមូហភាពសិស្សទាំងមូល
- ត្រិះរិះពិចារណាដើម្បីត្រៀមឆ្លើយ
- អានឯកសារ
- ពិនិត្យ និងប្រើប្រាស់សម្ភារឧបទេស
- ឡើងរាយការណ៍ឬឡើងសរសេរលើក្ដារខៀន
- ឡើងសង្ខេបមេរៀន

**តួនាទីសំខាន់ៗរបស់គ្រូមាន៖**

- បង្កលក្ខណៈឲ្យសិស្សមានសកម្មភាព ឬចូលរួមក្នុងការសិក្សាដោយរីករាយ
- បង្កឲ្យសិស្សមានទំនាក់ទំនងជាក់លាក់ និងសកម្មភាពប្រកបដោយអត្ថន័យត្រឹមត្រូវដែលជាគន្លឹះនាំឲ្យសិស្សយល់ និងមានបទពិសោធន៍ច្បាស់លាស់
- ឲ្យសិស្សមានការអភិវឌ្ឍពេញលេញលើបំណិនគំនិត ការស្វែងយល់ពីសង្គម និងឥរិយាបថ។
- ផ្ដល់ការសិក្សាប្រកបដោយការពន្យល់ត្រឹមត្រូវ ចេះស្រាវជ្រាវច្នៃប្រឌិត។
- អភិវឌ្ឍន៍ និងពង្រឹងគំនិត គោរពស្រឡាញ់ខ្លួនឯង ហើយជានាឲ្យសិស្សមានចំណង់ចំណូលចិត្តឬទទួលបានជោគជ័យក្នុងការសិក្សា។
- ដាក់បញ្ហាឲ្យសិស្សឆ្លើយផ្ទាល់មាត់ដោយសរសេរ ឬពិភាក្សាតាមក្រុម
- ជួយណែនាំពន្យល់ពីរបៀបរបបអនុវត្តការងារផ្សេងៗ
- ដាក់បទបញ្ហាសម្រាប់សិស្សអនុវត្ត
- សម្របសម្រួលសកម្មភាពសិស្ស
- បំផុសគំនិតណែនាំបន្ថែម
- បូកសរុបបកស្រាយបន្ថែម និងធ្វើសំយោគខ្លឹមសារ។

## ២.៥ ការរៀបចំសិស្ស

រាល់ការរៀន និងការបង្រៀន លោកគ្រូអ្នកគ្រូអាចរៀបចំសកម្មភាពសិស្សជាក្រុមធំ ក្រុមតូច ដៃគូ បុគ្គលទៅតាមលទ្ធភាពជាក់ស្តែង និងខ្លឹមសារមេរៀននីមួយៗដែលបានកំណត់ទុក។ សកម្មភាពទាំងនេះប្រព្រឹត្តទៅនៅគ្រប់ទីកន្លែងទាំងនៅក្នុងថ្នាក់ ក្រៅថ្នាក់ និងក្នុងសហគមន៍។ សកម្មភាពនីមួយៗ គ្រូត្រូវកំណត់រយៈពេល ខ្លឹមសារ និងការណែនាំឲ្យបានច្បាស់លាស់ ដើម្បីឲ្យសិស្សងាយស្រួលក្នុងការបំពេញកិច្ចការ។ គេចែករូបភាពនៃការសិក្សាជាបួនផ្នែក:

▪ **ការងារក្រុមធំ៖** ក្រុមថ្នាក់ទាំងមូលជាធម្មតាការងារនេះតម្រូវឲ្យសិស្សក្នុងថ្នាក់ទាំងអស់ធ្វើសកម្មភាពរួមគ្នា។

▪ **ការងារក្រុមតូច៖** ក្នុងពេលបង្រៀនគ្រូគប្បីរៀបចំចែកសិស្សជាក្រុមតូចៗមានសមាជិកពី៤ ទៅ ៦ នាក់ក្នុងមួយក្រុមៗ ដោយមានសិស្សពូកែលាយជាមួយសិស្សខ្សោយ។ ការរៀបចំក្រុមតូចៗមានច្រើនវិធីទៅតាមខ្លឹមសារ ឬកិច្ចការដែលត្រូវដាក់ឲ្យដូចជា:

- រៀបចំសិស្សតាមក្រុមដោយបែងចែកទៅតាមសិស្សពូកែលាយជាមួយសិស្សរៀនយឺតដើម្បីឲ្យសិស្សពូកែជួយសិស្សរៀនយឺត សិស្សពូកែពង្រឹងសមត្ថភាពខ្លួនឯង សិស្សរៀនយឺតពិនិត្យសង្កេត និងធ្វើតាមសិស្សពូកែ និងសិស្សរៀនយឺតអាចពង្រឹងនិងអភិវឌ្ឍសមត្ថភាពខ្លួនឯង ហើយនឹងឈានទៅពូកែដែរ។

- រៀបចំសិស្សប្រុស សិស្សស្រី ដើម្បីឲ្យសិស្សងាយស្រួលក្នុងការពិភាក្សាបញ្ចេញចំណេះដឹងមានស្រាប់ដោយមិនខ្មាសអៀន។

- រៀបចំក្រុមសិស្សទៅតាម ការស្ម័គ្រចិត្តដែលគេចូលចិត្តនឹងជ្រើសរើសដោយខ្លួនឯង ដោយត្រូវដាក់កិច្ចការដូចៗគ្នា ទៅតាមក្រុមនីមួយៗតែគ្រូក៏ត្រូវកំណត់ឲ្យមានសិស្សពូកែតាមក្រុមនីមួយៗដែរ។

▪ **ការងារដៃគូ៖** ជាទូទៅការងារជាដៃគូ គឺតម្រូវឲ្យសិស្សចាប់ដៃគូពីរៗនាក់ សម្រាប់ធ្វើសកម្មភាព។ ពេលខ្លះគ្រូផ្តល់លទ្ធភាពឲ្យសិស្សជ្រើសរើសដៃគូរដោយសេរី និងស្ម័គ្រចិត្ត។ ការងារជាដៃគូ សិស្សច្រើនធ្វើសកម្មភាពជាច្រើនដូចជា ដើរតួរសន្ទនាផ្លាស់ប្តូរការពន្យល់ ប្តូរកិច្ចការគ្នាកែ សួរគ្នាទៅវិញទៅមក ដាក់លំហាត់ពិភាក្សាគ្នាទៅវិញទៅមក។

▪ **ការងារបុគ្គល៖** ជាការងាររបស់សិស្សម្នាក់ៗដែលត្រូវបានគេប្រគល់ឲ្យ ហើយសិស្សត្រូវបំពេញកិច្ចការដោយខ្លួនឯងផ្ទាល់ ដោយប្រើប្រាស់ចំណេះដឹងដែលបានពីគ្រូ គ្រួសារ និងសហគមន៍ដោយជឿជាក់លើសមត្ថភាពចំណេះដឹងរបស់ខ្លួន។

## ២.៦ របៀបសិក្សា

• **ការស្រាវជ្រាវ៖** ជារបៀបសិក្សាដែលតម្រូវឲ្យសិស្សប្រើប្រាស់ប្រភពឯកសារ និងព័ត៌មានដើម្បីយល់បញ្ញត្តិពាក្យគន្លឹះ ឬបញ្ហាផ្សេងៗ។ ការស្រាវជ្រាវអាចអនុវត្តជាក្រុមធំ ក្រុមតូច ជាដៃគូ ឬជាបុគ្គលនៅក្នុងថ្នាក់ ក្នុងបណ្ណាល័យ ឬក្នុងសហគមន៍។

• **ការពិភាក្សា៖** ជាសកម្មភាពតម្រូវឲ្យសិស្សក្នុងក្រុមវែកញែកបញ្ចេញគំនិតផ្ទាល់ ប្តូរយោបល់ដើម្បីដោះស្រាយបញ្ហា។

• **សម្ភាសន៍៖** ជាការសាកសួរបុគ្គល ឬក្រុមណាមួយផ្ទាល់ដើម្បីប្រមូលព័ត៌មាន។ សកម្មភាពសម្ភាសន៍អាចឲ្យសិស្សធ្វើជាបុគ្គល ឬក្រុមនៅក្នុងថ្នាក់រៀន ឬតាមសាធារណៈ។

## ២.៧ តួនាទីគ្រូបង្រៀនក្នុងការបង្រៀនបែបអប់រំគ្លេស

យោងតាមការសិក្សាស្រាវជ្រាវរបស់លោក មាឃ សារី , ២០០២ ដើម្បីឲ្យការអនុវត្តការបង្រៀន និងរៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌលប្រកបដោយប្រសិទ្ធភាពបានល្អនោះ គឺគ្រូត្រូវស្គាល់ពីតួនាទី និងភារកិច្ចរបស់ខ្លួនឲ្យបានច្បាស់លាស់ និងត្រូវចាត់ទុកសិស្សជាកត្តាសំខាន់ ពោលគឺគ្រូត្រូវផ្តល់ឱកាសឲ្យសិស្សទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួនដោយផ្អែកលើតម្រូវការ និងការយល់ដឹងរបស់ខ្លួន។ គ្រូមានតួនាទីគោលសម្រាប់អនុវត្តចំនួន៤គឺ ជាអ្នកធ្វើផែនការជាអ្នកសម្របសម្រួល ជាអ្នកដឹកនាំ និងជាអ្នកត្រួតពិនិត្យតាមដាន និងវាយតម្លៃ។

### ២.៧.១ តួនាទីជាអ្នកធ្វើផែនការ

តួនាទីជាអ្នកធ្វើផែនការ គ្រូត្រូវរៀបចំជាមុននូវផែនការចំនួន៣ គឺផែនការមុនពេលបង្រៀន ផែនការពេលបង្រៀន និងផែនការក្រោយពេលបង្រៀន។ មុនពេលបង្រៀនគ្រូត្រូវត្រៀមរៀបចំកិច្ចតែងការបង្រៀនតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល ត្រូវកំណត់វត្ថុបំណងច្បាស់លាស់ សម្ភារឧបទេស សំណួរសម្រាប់

ពិភាក្សាដែលស្របទៅនឹងខ្លឹមសារមេរៀន កំណត់រយៈពេលសម្រាប់ការធ្វើសកម្មភាពរបស់សិស្ស ទៅតាមជំហាននីមួយៗក្នុងពេលដំណើរការបង្រៀន និងកំណត់តួនាទីរបស់សិស្ស ថាតើសិស្សត្រូវធ្វើសកម្មភាពអ្វីខ្លះក្នុងពេលរៀន។ គ្រូត្រូវស្រាវជ្រាវឯកសារនានាទាក់ទងនឹងមេរៀនដែលត្រូវបង្រៀនរិះរកវិធីសាស្ត្រថ្មីៗ ល្អៗប្លែកៗត្រៀមបម្រុងទុកពន្យល់សិស្សឲ្យយល់ច្បាស់នូវអ្វីដែលថ្មី ដូចជា និយមន័យ ឬអត្ថន័យជាដើម។

### ២.៧.២ តួនាទីជាអ្នកសម្របសម្រួល

តួនាទីជាអ្នកសម្របសម្រួលគ្រូត្រូវចេះរៀបចំសកម្មភាពសិស្សចូលរួមក្នុងការសិក្សាដោយខ្លួនគេផ្ទាល់គ្មានការបង្ខិតបង្ខំពីគ្រូ ពោលគឺចូលរួមដោយរីករាយ។ មុនពេលដាក់កិច្ចការឲ្យសិស្សធ្វើគ្រូត្រូវធ្វើការណែនាំពន្យល់ពីរបៀប ឬលំនាំក្នុងការធ្វើសកម្មភាពនីមួយៗឲ្យបានច្បាស់លាស់ និងទុកឱកាសឲ្យសិស្សបានគិតពិចារណា និងពិភាក្សាផ្លាស់ប្តូរគ្នាសិន។ ទំនាក់ទំនង និងការសហការគ្នារវាងគ្រូ និងសិស្សនៅក្នុងថ្នាក់រៀន គឺជាសកម្មភាពដែលមិនអាចខ្វះបាន ព្រោះសកម្មភាពទាំងនេះធ្វើក្នុងគោលបំណងឲ្យចេះជួយគ្នា សហការគ្នា លើកទឹកចិត្តគ្នាជាពិសេសជួយសិស្សឲ្យកាន់តែមានភាពសកម្មក្នុងការសិក្សា ហើយគ្រូក៏អាចមានឱកាសជួយដល់សិស្សខ្សោយផងដែរ។

### ២.៧.៣ តួនាទីជាអ្នកដឹកនាំ

សម្រាប់តួនាទីនេះ គ្រូត្រូវតែណែនាំសិស្សឲ្យយល់ពីវត្ថុបំណងនៃមេរៀន ខ្លឹមសារមេរៀន និងសកម្មភាពដែលពួកគេកំពុងអនុវត្ត ដើម្បីឲ្យពួកគេអាចគ្រប់គ្រងពេលវេលា និងសកម្មភាពរបស់ខ្លួនបានស្គាល់ច្បាស់ពីទីតាំងពិតប្រាកដ និងដឹងពីតម្រូវការរបស់ពួកគេបានដោយខ្លួនគេផ្ទាល់។ គ្រូបង្រៀនត្រូវបង្ហាញពីអ្វីដែលថ្មីចេះធ្វើឲ្យសិស្សចាប់អារម្មណ៍ និងផ្តោតការគិតទៅលើអ្វីដែលគ្រូពន្យល់ ដោយប្រើសម្តីច្បាស់ៗ ខ្លីៗ និងត្រូវកំណត់គោលដៅ ឬវត្ថុបំណង និងអ្វីៗដែលយើងចង់បានឲ្យជាក់លាក់។ គ្រូត្រូវលើកទឹក និងជម្រុញឲ្យសិស្សធ្វើការងារជាក្រុម និងផ្តល់ឱកាសដល់សិស្សក្នុងការបញ្ចេញមតិយោបល់ដោយចំហ និងចេះគិតពិចារណា រកហេតុផល ចេះស្តាប់ ចេះចូលរួម ចេះទទួលយក ចេះចែករំលែក ចេះជ្រើសរើស ចេះសម្រេចចិត្តប្រកបដោយទំនួលខុសត្រូវ និងចេះដោះស្រាយបញ្ហាដោយប្រើមធ្យោបាយសមស្របទាំងនៅក្នុងសាលា និងក្រៅសាលា។ ជាងនេះទៅទៀត សិស្សត្រូវបានទទួលនូវសេរីភាពពេញលេញ និងរីកចម្រើន

ទាំងបំណិនគិត បំណិនវិភាគ និងបំណិនក្នុងការវាយតម្លៃតាមរយៈបទពិសោធន៍ ការសង្កេតជាក់ស្តែង និងការអនុវត្តផ្ទាល់ ដើម្បីឲ្យសិស្សម្នាក់ៗអាចទាញយកបាននូវបញ្ញត្តិ ឬចំណេះដឹងថ្មីៗ ជាបន្តបន្ទាប់។ អ្វីដែលពិសេសនោះគឺ គ្រូត្រូវធ្វើយ៉ាងណាឲ្យសិស្សគ្រប់ៗរូប មានសេចក្តីព្យាយាមក្នុងការបញ្ចេញនូវសក្តានុពលរបស់ខ្លួនក្នុងការយកបាននូវលទ្ធផលសិក្សាដ៏គាប់ប្រសើរ និងជួយដឹកនាំការត្រិះរិះពិចារណារបស់សិស្សដោយធ្វើការសរសើរ ហើយលើកទឹកចិត្តសិស្សជាប្រចាំ ព្រោះសកម្មភាពទាំងនេះអាចជួយសិស្ស ឲ្យមានសេចក្តីក្លាហាន និងបន្តខិតខំសិក្សាកាន់តែខ្លាំង។

### ២.៧.៤ តួនាទីជាអ្នកត្រួតពិនិត្យតាមដាន និងវាយតម្លៃ

សម្រាប់តួនាទីនេះ គឺពេលកំពុងបង្រៀន គឺគ្រូត្រូវដើរត្រួតពិនិត្យតាមដាន នូវរាល់សកម្មភាពរបស់សិស្សនៅតាមក្រុមនីមួយៗក្នុងពេលដែលគ្រូដាក់កិច្ចការឬការងារឲ្យធ្វើដើម្បីចាត់ចែង ត្រួតពិនិត្យ និងធ្វើការវាយតម្លៃចំពោះសកម្មភាព និងការរីកចម្រើននៃការសិក្សារបស់សិស្ស។ លើសពីនេះទៅទៀត គ្រូគ្រាន់តែធ្វើការសង្កេតមើលដោយមិនបញ្ចេញសកម្មភាព ឬមិនផ្តល់នូវជំនួយអ្វីទាំងអស់ ដោយទុកពេលឲ្យសិស្សបានគិត ពិចារណា និងធ្វើសកម្ម ភាពដោយខ្លួនគេឲ្យបានច្រើន ហើយសមស្របតាមការកំណត់របស់គ្រូដែរ។ ក្រោយពេលបង្រៀនចប់ គ្រូក៏ត្រូវធ្វើតេស្តវាយតម្លៃពីសមត្ថភាពរបស់សិស្សដែលបានអនុវត្តនៅក្នុងម៉ោងបង្រៀនរបស់ខ្លួន ដើម្បីអាចដឹងបានថា តើសិស្សទទួលបានចំណេះដឹងប៉ុណ្ណា និងត្រូវការអ្វីបន្ថែមទៀត។

## ២.៨ បញ្ហាប្រឈមនៅក្នុងការអនុវត្តកម្មវិធីសិស្សមជ្ឈមណ្ឌល

ចាប់តាំងពីការដួលរលំនៃរបបដឹកនាំរបស់សហភាពសូវៀត គ្រូបង្រៀន និងសិស្សបានប្រឈមមុខនឹងវិធីថ្មីនៃការគិត ដែលធ្វើឲ្យសិស្សមានការលំបាកក្នុងការយល់ដឹងពីរបៀបការលើកកម្ពស់ការរៀន ប្រកបដោយប្រសិទ្ធភាព។ មិនតែប៉ុណ្ណោះ នៅក្នុងការផ្តល់ការអប់រំតាមបែបសិស្សមជ្ឈមណ្ឌលគ្រូបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចជាទំហំថ្នាក់បង្រៀនធំ កង្វះសម្ភារឧបទេសសម្រាប់បម្រើឲ្យការបង្រៀន និងរៀនរបស់សិស្ស( de la Sabloniere et al.,2009 )។ទន្ទឹមនឹងនោះ Urwick and Junaidu ( 1991 ) បានបង្ហាញថា អ្នកស្រាវជ្រាវជាច្រើនបានរកឃើញថាកង្វះធនធានជាបញ្ហាសម្រាប់ការអនុវត្តការសិក្សាតាម

បែបគោលវិធីសិស្សមជ្ឈមណ្ឌល ព្រោះថាសៀវភៅនិងសម្ភារឧបទេសផ្សេងៗទៀតវាមានសារៈសំខាន់នៅក្នុងការធ្វើឲ្យការបង្រៀន និងរៀនរបស់សិស្សមានលក្ខណៈសហការឬត្រូវគ្នា។ បញ្ហាចម្បងដែលត្រូវបារម្ភខ្លាំងនោះគឺ ហេដ្ឋារចនាសម្ព័ន្ធ ទំហំថ្នាក់ សម្ភារបង្រៀន និងសមត្ថភាពរបស់គ្រូ (Jessop and Penny , 1998)។ ដោយសារបញ្ហាប្រឈមទាំងនេះ គ្រូបានបរាជ័យក្នុងការធ្វើផែនការបង្រៀនតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល បរាជ័យក្នុងការទាក់ទាញចំណាប់អារម្មណ៍សិស្សក្នុងថ្នាក់រៀន និងបរាជ័យក្នុងការធ្វើឲ្យសិស្សចូលរួមទាំងការគិត និងការដោះស្រាយបញ្ហានៅក្នុងថ្នាក់រៀន ( Chiphiko and Shawa , 2014 )។

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១ ដែនកំណត់ និងវិសាលភាព

ការចុះសិក្សាតាមទីកន្លែងដែលបានជ្រើសរើសនេះ គឺធ្វើឡើងចាប់ពីថ្ងៃទី១៤ ខែកក្កដា រហូតដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ គឺធ្វើនៅវិទ្យាល័យដែលបានគ្រោងទុក។

## ៣.២ ការជ្រើសរើសភាគសំណាក

ភាគសំណាកសម្រាប់ការសិក្សាស្រាវជ្រាវនេះមាន នាយកសាលាចំនួន១០នាក់ លោកគ្រូ-អ្នកគ្រូក្នុងចន្លោះពី១-៦ នាក់ក្នុងមួយវិទ្យាល័យដែលជ្រើសរើសចេញពីលោកគ្រូ-អ្នកគ្រូ ដែលកំពុងបង្រៀនភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ សិស្សថ្នាក់ទី១១ ចំនួន ១៤៨នាក់ ក្នុងនោះស្រី៨០នាក់។ សរុបរួមមានលោកគ្រូ-អ្នកគ្រូដែលបានចូលរួមក្នុងការសិក្សាមានចំនួន៨នាក់ ដែលក្នុងនោះមានអ្នកគ្រូ ចំនួន៣នាក់ ហើយដែលកំពុងបម្រើការនៅសាលាចំនួន៣ក្នុងខេត្តតាកែវ។ វិទ្យាល័យទាំង៣នោះ រួមមានវិទ្យាល័យ សុខ អាន ព្រៃសណ្តែក វិទ្យាល័យ សុខ អាន ថ្នល់បំបែក និងវិទ្យាល័យ សុខ អាន ខ្វាវ។

### ៣.២.១ ព័ត៌មានផ្ទាល់ខ្លួនរបស់គណៈគ្រប់គ្រងដែលចូលរួមក្នុងការស្រាវជ្រាវ

ផ្នែកនេះបង្ហាញពីព័ត៌មានទូទៅរបស់គណៈគ្រប់គ្រងដែលបានចូលរួមក្នុងគម្រោងសិក្សាស្រាវជ្រាវនេះ។ ព័ត៌មានទាំងនេះរួមមាន ភេទ សមាសភាពគណៈគ្រប់គ្រង តាមក្រុម អាយ ដែលមកពីសាលាផ្សេងៗគ្នា ព្រម ទាំងបទពិសោធន៍ការងារជានាយក នាយករង ជាដើម។

**តារាងទី 1៖ បំណែងចែកសមាសភាពរបស់គណៈគ្រប់គ្រងតាមវិទ្យាល័យ**

| កម្រិតសិក្សាខ្ពស់បំផុតរបស់គណៈគ្រប់គ្រង | ភេទ | | សរុប |
|---|---|---|---|
| | ប្រុស | ស្រី | |
| ទាបជាងបរិញ្ញាបត្រ | ០២ | ០០ | ០២ |
| កម្រិតបរិញ្ញាបត្រ | ០៦ | ០១ | ០៧ |

| | | | |
|---|---|---|---|
| ខ្ពស់ជាងបរិញ្ញាបត្រ | ០១ | ០០ | ០១ |
| សរុប | ០៩ | ០១ | ១០ |
| ភាគរយ | ៩០% | ១០% | ១០០% |

តារាងទី1 នេះបង្ហាញថាសមាសភាព គណៈគ្រប់គ្រង ដែលបានចូលរួមក្នុងការសិក្សានេះមានបុរស ៩០% និងស្ត្រី ១០%។ បើយើងក្រឡេកមើលទៅលើការសិក្សារបស់ពួកគាត់វិញ យើងសង្កេតឃើញថាគណៈគ្រប់គ្រង ដែលមានកម្រិតសិក្សាចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅមាន ៧៨% នៃចំនួនគណៈគ្រប់គ្រង ដែលបានចូលរួមសម្ភាសន៍នូវកម្រងសំណួរការសិក្សាស្រាវជ្រាវនេះដែលក្នុងនោះមានចំនួន១នាក់ មានកម្រិតសិក្សាក្រោយឧត្តម សិក្សា។

**តារាងទី 2៖ បទពិសោធន៍ការងាររបស់គណៈគ្រប់គ្រង តាមវិទ្យាល័យ**

| បទពិសោធន៍ការងារខ្ពស់បំផុតរបស់គណៈគ្រប់គ្រង | ភេទ | | សរុប |
|---|---|---|---|
| | ប្រុស | ស្រី | |
| តិចជាង៣ឆ្នាំ | ០០ | ០០ | ០០ |
| ពី៣ ដល់ ៥ឆ្នាំ | ០០ | ០១ | ០១ |
| ចាប់ពី៦ឆ្នាំឡើងទៅ | ០៩ | ០០ | ០៩ |
| សរុប | ០៩ | ០១ | ១០ |
| ភាគរយ | ៩០% | ១០% | ១០០% |

តារាងទី2 នេះបង្ហាញថាសមាសភាព គណៈគ្រប់គ្រង ដែលបានចូលរួមក្នុងការសិក្សានេះ មានចំនួន១០នាក់ ដែលមានបទពិសោធន៍ការងារជាគណៈគ្រប់គ្រងចាប់ពី០៣ឆ្នាំឡើងទៅមានដល់ ១០០% នៃចំនួន គណៈគ្រប់គ្រង ដែលបានចូលរួមសម្ភាសន៍នូវកម្រងសំណួរការសិក្សាស្រាវជ្រាវនេះ ដែលក្នុងនោះមាន ចំនួន១នាក់ មានបទពិសោធន៍កាងារជាគណៈគ្រប់គ្រងច្រើនជាងគេរហូតដល់ ២៥ឆ្នាំ។

### ៣.២.២ ព័ត៌មានផ្ទាល់ខ្លួនរបស់ លោកគ្រូ-អ្នកគ្រូ ដែលចូលរួមក្នុងការស្រាវជ្រាវ

ផ្នែកនេះបង្ហាញពី ព័ត៌មានទូទៅរបស់លោកគ្រូ-អ្នកគ្រូដែលបានចូលរួមក្នុងគម្រោងសិក្សាស្រាវជ្រាវនេះ។ ព័ត៌មានទាំងនេះរួមមាន ភេទ សមាសភាពលោកគ្រូ-អ្នកគ្រូតាមក្រុម អាយុ ដែលមកពីសាលាផ្សេងៗគ្នា ព្រមទាំងបទពិសោធន៍ការងារក្នុងការបង្រៀនជាដើម។

**តារាងទី 3៖ ព័ត៌មានទាក់ទងនឹងកម្រិតសិក្សារបស់លោកគ្រូ-អ្នកគ្រូ**

| កម្រិតសិក្សាខ្ពស់បំផុតរបស់លោកគ្រូ-អ្នកគ្រូ | ភេទ | | សរុប |
|---|---|---|---|
| | ប្រុស | ស្រី | |
| ទាបជាងបរិញ្ញាបត្រ | ០០ | ០០ | ០០ |
| កម្រិតបរិញ្ញាបត្រ | ០៥ | ០៣ | ០៨ |
| ខ្ពស់ជាងបរិញ្ញាបត្រ | ០០ | ០០ | ០០ |
| សរុប | ០៥ | ០៣ | ០៨ |
| ភាគរយ | ៦២,៥០% | ៣៧,៥០% | ១០០% |

តារាងទី3 នេះបង្ហាញថាសមាសភាព លោកគ្រូ - អ្នកគ្រូ ដែលបានចូលរួមក្នុងការសិក្សានេះមាន បុរស ៦២,៥០% និងស្ត្រី ៣៧,៥០%។ បើយើងក្រឡេកមើលទៅលើការសិក្សារបស់ពួកគាត់វិញ យើងសង្កេតឃើញថា លោកគ្រូ - អ្នកគ្រូ ដែលមានកម្រិតសិក្សាចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅមាន ១០០% នៃចំនួន លោកគ្រូ- អ្នកគ្រូ ដែលបានចូលរួមបំពេញនូវកម្រងសំណួរការសិក្សាស្រាវជ្រាវនេះ។

**តារាងទី 4៖ បំណែងចែកសមាសភាពរបស់លោកគ្រូ - អ្នកគ្រូ តាមវិទ្យាល័យ**

| វិទ្យាល័យ | ភេទ | | សរុប |
|---|---|---|---|
| | ប្រុស | ស្រី | |
| វិទ្យាល័យ សុខ អាន ព្រៃសណ្តែក | ០៤ | ០១ | ០៥ |
| វិទ្យាល័យ សុខ អាន ថ្នល់បំបែក | ០០ | ០២ | ០២ |

| | | | |
|---|---|---|---|
| វិទ្យាល័យ សុខ អាន ខ្វាវ | ០១ | ០០ | ០១ |
| សរុប | ០៥ | ០៣ | ០៨ |

តារាងទី4 នេះបង្ហាញថា ចំនួនលោកគ្រូ - អ្នកគ្រូ ដែលត្រូវបានជ្រើសរើសឱ្យចូលរួមក្នុងការសិក្សាមានចំនួនលើសខ្វះគ្នាបន្តិចបន្តួចតាមវិទ្យាល័យនីមួយៗ។ ក្នុងចំណោមលោកគ្រូ-អ្នកគ្រូទាំង៨នាក់នេះត្រូវបានជ្រើសរើសដើម្បីសុំការអនុញ្ញាតចូលសង្កេតដោយផ្ទាល់ទៅលើការបង្រៀន និងរៀនរបស់គាត់ទាក់ទងទៅនឹងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស។

### ៣.២.៣ ព័ត៌មានផ្ទាល់ខ្លួនរបស់ សិស្សានុសិស្ស ដែលចូលរួមក្នុងការស្រាវជ្រាវ

**តារាងទី 5៖ បំណែងចែកសមាសភាពរបស់សិស្សានុសិស្ស ថ្នាក់ទី១១ តាមវិទ្យាល័យ**

| វិទ្យាល័យ | ភេទ | | សរុប |
|---|---|---|---|
| | ប្រុស | ស្រី | |
| វិទ្យាល័យ សុខ អាន ព្រៃសណ្ដែក | ២១ | ២៨ | ៤៩ |
| វិទ្យាល័យ សុខ អាន ថ្នល់បំបែក | ២៤ | ៣១ | ៥៥ |
| វិទ្យាល័យ សុខ អាន ខ្វាវ | ២៣ | ២១ | ៤៤ |
| សរុប | ៦៨ | ៨០ | ១៤៨ |
| ភាគរយ | ៤៥,៩៥% | ៥៤,០៥% | ១០០% |

តារាងទី5 នេះបង្ហាញថាចំនួនសិស្សានុសិស្សថ្នាក់ទី១១ ដែលត្រូវបានជ្រើសរើសឱ្យចូលរួមក្នុងការសិក្សាមានចំនួន១៤៨នាក់ ក្នុងនោះដែរមានសិស្សស្រី ៨០នាក់ និងសិស្សប្រុស ៦៨នាក់។ បើយើងក្រឡេក មើលតាមតារាងទី5 សិស្សថ្នាក់ទី១១ មានតែវិទ្យាល័យ សុខ អាន ថ្នល់បំបែកទេ ដែលមានសិស្សច្រើនជាងគេ និងវិទ្យាល័យ សុខ អាន ខ្វាវ មានសិស្សតិចជាងគេ។

## ៣.៣ ឧបករណ៍ស្រាវជ្រាវ

កម្រងសំណួរត្រូវបានរៀបចំបង្កើតឡើង និងធ្វើជាឧបករណ៍សម្រាប់ធ្វើការស្រាវជ្រាវដែលមានលក្ខណៈសំណួរទម្រង់បិទ សំណួរទម្រង់បើក និងសំណួរវាស់កម្រិត (ដាក់ពិន្ទុ) សម្រាប់ជូនលោកគ្រូ អ្នកគ្រូ

និងសិស្ស បំពេញ ហើយក៏មានកម្រងសំណួរសម្រាប់សម្ភាសន៍លោកនាយកសាលាផងដែរ។

**វិធីបង្កើតកម្រងសំណួរ**

ការបង្កើតកម្រងសំណួរ គឺប្រើប្រាស់ឯកសារពាក់ព័ន្ធរបស់ក្រសួង មន្ទីរ និងការិយាល័យអប់រំ យុវជន និងកីឡា ជាភាសាខ្មែរ និងការសិក្សាស្រាវជ្រាវពីឯកសារភាសាខ្មែរ និងជាភាសាបរទេសដែលជាស្នាដៃស្រាវជ្រាវដើម្បីប្រៀបធៀបខ្លឹមសារ។

**លក្ខណៈទម្រង់កម្រងសំណួរ**

កម្រងសំណួរនេះ ចែកចេញជាពីរផ្នែកធំៗគឺៈ

**ផ្នែកទី១** : រៀបរាប់ពីស្ថានភាពភាគសំណាក ដែលរៀបរាប់ពីភេទ អាយុ កម្រិតវប្បធម៌ និងបទពិសោធន៍បង្រៀន។

**ផ្នែកទី២** : រៀបរាប់ពីការចង់ដឹងរបស់អ្នកស្រាវជ្រាវទៅលើការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលពីភាគសំណាកដែលខ្លឹមសារត្រូវបានបែងចែកជាបីគោលគំនិតសំខាន់ គឺការត្រៀមលក្ខណៈមុនពេលបង្រៀនដំណើរ ការបង្រៀន និងវង្វាយតម្លៃចំណេះដឹងរបស់សិស្ស និងសកម្មភាពបង្រៀន និងរៀនរបស់ គ្រូ និងសិស្សសម្រាប់ អនុវត្តរួមគ្នា។

## ៣.៤ នីតិវិធី ឬដំណើរការប្រមូលទិន្នន័យ

ក្រោយពីកម្រងសំណួរបានឆ្លងកាត់គ្រូដឹកនាំដែលគាត់បានអនុម័តយល់ព្រមឱ្យធ្វើការសម្ភាសន៍អ្នកស្រាវជ្រាវក៏ធ្វើលិខិតស្នើលោកនាយកវិទ្យាស្ថានជាតិអប់រំ ដើម្បីចុះប្រមូលទិន្នន័យនៅតាមសាលារៀននីមួយៗដូចដែលបានកំណត់។

ក្រោយពីទទួលបានលិខិតស្នើហើយ ជាដំបូងអ្នកស្រាវជ្រាវនឹងចុះជួបជាមួយថ្នាក់ដឹកនាំនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដើម្បីសុំការសហការ និងសាកសួរព័ត៌មានបន្ថែមអំពីទីតាំង ដែលបានកំណត់ទុកសម្រាប់ការសិក្សាស្រាវជ្រាវនេះ។ បន្ទាប់ពីបានកំណត់ទីកន្លែងសម្រាប់ការសិក្សាស្រាវជ្រាវហើយ ក៏បានជួបមន្ត្រី ការិយាល័យនៅមន្ទីរអប់រំ យុវជន និងកីឡា ដោយបានរៀបចំចុះទៅមើលសាលាដែលបានជ្រើសរើសសម្រាប់ការស្រាវជ្រាវនេះ។ បន្ទាប់មកទៀត បានជួបនឹងគណៈគ្រប់គ្រងសាលា និងលោកគ្រូ-អ្នកគ្រូ

នៅតាមសាលា នីមួយៗដើម្បីជម្រាបពួកគាត់ពីគោលបំណងនៃការចុះសិក្សានេះ។ មួយវិញទៀត អ្នកសិក្សាស្រាវជ្រាវក៏បានស្នើសុំគណៈគ្រប់គ្រង និងលោកគ្រូ-អ្នកគ្រូ ក្នុងការជួយសម្រួលដល់ដំណើរការប្រមូលទិន្នន័យនេះ។

បន្ទាប់ពីបានសុំការសហការពីគណៈគ្រប់គ្រងសាលាដើម្បីឱ្យលោកគ្រូ-អ្នកគ្រូ និងសិស្សចូលរួមជាគំរូជ្រើសរើស (ឬភាគសំណាក) សម្រាប់ការជួយបំពេញកម្រងសំណួររួចមក ក៏បានជូនសន្លឹកកម្រងសំណួរដល់លោកគ្រូ-អ្នកគ្រូ ហើយស្នើសុំឱ្យពួកគាត់ជួយបំពេញចម្លើយទៅតាមសំណួរដែលមាន។ ការបំពេញកម្រងសំណួរ នេះមានរយៈពេល ៤៥នាទី ហើយក្រោយពីការបំពេញចម្លើយរួចរាល់ក៏បានប្រមូលសន្លឹកសំណួរទាំងអស់ និងពិនិត្យភាពរៀបរយរបស់កម្រងសំណួរដែលមានចម្លើយរបស់លោកគ្រូ-អ្នកគ្រូ និងសិស្សសម្រាប់យកមកវិភាគ ទិន្នន័យ។

ការប្រមូលទិន្នន័យនេះនឹងអាចឱ្យអ្នកស្រាវជ្រាវប្រមូលបានព័ត៌មាន ដ៏មានប្រយោជន៍សម្រាប់ការសិក្សា ស្វែងយល់បន្ថែមអំពីការអនុវត្តគោលវិធីសាស្ត្រមជ្ឈមណ្ឌលរបស់លោកគ្រូ- អ្នកគ្រូនៅតាមសាលានីមួយៗ និងដើម្បីវាស់ស្ទង់អំពីប្រសិទ្ធិភាពនៃការគ្រប់គ្រងបង្រៀន និងរៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌលរបស់លោកគ្រូ-អ្នកគ្រូផងដែរ។

## ៣.៥ ការវិភាគទិន្នន័យ

ទិន្នន័យដែលទទួលបានសំណាកគំរូដែលបានជ្រើសរើស នឹងធ្វើការវិភាគដោយផ្តោតលើវិធីសាស្ត្របរិមាណវិស័យជាសំខាន់ វិធីសាស្ត្រគុណវិស័យ និងប្រើកម្មវិធីវិភាគទិន្នន័យស្ថិតិ SPSS និង Excel 2010។ ការវិភាគនេះនឹងផ្តោតទៅលើលទ្ធផលស្ថិតិដូចខាងក្រោម៖

លទ្ធផលពីការវិភាគបែបស្ថិតិពណ៌នា ទៅលើព័ត៌មានទូទៅរបស់លោកគ្រូ- អ្នកគ្រូដូចជាព័ត៌មានទាក់ទងនឹងចំនួនអ្នកដែលបានចូលរួមក្នុងការសិក្សា ភេទ កម្រិតនៃការសិក្សា បទពិសោធន៍ ការងារជាដើម។ ទិន្នន័យទាំងនេះ នឹងត្រូវរៀបចំជាតារាងស្ថិតិផ្សេងៗដូចជាតារាងបំណែងចែកប្រេកង់ជាដើម ដើម្បីបកស្រាយលទ្ធផលនៃការសិក្សា។ ចំពោះកម្រិតនៃការវាយតម្លៃពីការអនុវត្តគោលវិធីសាស្ត្រសិស្សមជ្ឈមណ្ឌលរបស់លោកគ្រូ-អ្នកគ្រូក្នុងវិទ្យាល័យទាំងនោះនឹងត្រូវបកស្រាយដោយ ការគណនាតម្លៃមធ្យមតាងឱ្យពិន្ទុក្នុងការ

អនុវត្តគោល វិធីនេះ។ លទ្ធផលទាំងអស់ត្រូវបានរៀបចំជាក្រាបស្ថិតិដើម្បីងាយស្រួលក្នុងការបកស្រាយ។ ចំពោះលទ្ធផល នៃប្រៀបធៀបកម្រិត នៃការវាយតម្លៃការអនុវត្តគោលវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល ដោយផ្អែកលើតំបន់វាងទី ប្រជុំជន និងជនបទ។

# ជំពូកទី៤

# លទ្ធផល

# និងការពិភាក្សា

# ជំពូក ៤

# លទ្ធផល និងការពិភាក្សា

ក្នុងជំពូក ៤ នេះ អ្នកស្រាវជ្រាវ បង្ហាញពីលទ្ធផលដែលទទួលបានពីការស្រាវដោយលផ្អែកលើកម្រង សំណួរដែលបំពេញដោយសិស្សានុសិស្សចំនួន ១៤៨ (មួយរយសែសិបប្រាំបី) នាក់គត់ និងការសម្ភាសន៍ ដែលបានធ្វើឡើងជាមួយនាយក នាយិការ និងនាយករង នាយិការងសរុបចំនួន ១០ (ដប់) នាក់គត់។ លទ្ធផលដែលទទួលបានតាមរយៈការស្រាវជ្រាវនេះ មានដូចខាងក្រោម៖

## ៤.១ ការសម្ភាសន៍ជាមួយនាយក នាយិកា នាយករង នាយិការរង

ការសម្ភាសន៍នេះ អ្នកស្រាវជ្រាវបានជ្រើសរើសបីវិទ្យាល័យតាមការណែនាំរបស់សាស្ត្រាចារ្យដឹកនាំ និងសាស្ត្រាចារ្យដឹកនាំរង ដើម្បីធ្វើការស្រាវជ្រាវ។ វិទ្យាល័យទាំងបីនោះគឺ

១. វិទ្យាល័យ សុខ អាន ព្រៃសណ្តែក

២. វិទ្យាល័យ សុខ អាន ថ្នល់បំបែក

៣. វិទ្យាល័យ សុខ អាន ខ្វាវ

**តារាងបង្ហាញចំនួននាយក/រង នាយិការ/រង**

| ល.រ | ឈ្មោះសាលា | ចំនួនសរុប | ប្រុស | ស្រី | កម្រិតសិក្សា | | |
|---|---|---|---|---|---|---|---|
| | | | | | ទាបជាងបរិ | បរិ | ខ្ពស់ជាងបរិ |
| ១ | វិទ្យាល័យ សុខ អាន ព្រៃសណ្តែក | ៤ | ៣ | ១ | ១ | ២ | ១ |
| ២ | វិទ្យាល័យ សុខ អាន ថ្នល់បំបែក | ៣ | ៣ | 0 | 0 | ៣ | 0 |
| ៣ | វិទ្យាល័យ សុខ អាន ខ្វាវ | ៣ | ៣ | 0 | ១ | ២ | 0 |

**តារាងបង្ហាញពីបទពិសោធន៍ការងារ**

| ល.រ | ឈ្មោះសាលា | បទពិសោធន៍ជានាយក | បទពិសោធន៍បង្រៀន | ផ្សេងៗ |
|---|---|---|---|---|
| ១ | វិទ្យាល័យ សុខ អាន ព្រៃសណ្តែក | ០៥ | ២៥ | |
| ២ | វិទ្យាល័យ សុខ អាន ព្រៃសណ្តែក | ១១ | ២៤ | |

| | | | | |
|---|---|---|---|---|
| ៣ | វិទ្យាល័យ សុខ អាន ព្រៃសណ្តែក | ១០ | ៣៤ | |
| ៤ | វិទ្យាល័យ សុខ អាន ព្រៃសណ្តែក | ០៦ | ៣០ | |
| ៥ | វិទ្យាល័យ សុខ អាន ថ្នល់បំបែក | ១៨ | ២៩ | |
| ៦ | វិទ្យាល័យ សុខ អាន ថ្នល់បំបែក | ០៩ | ២៦ | |
| ៧ | វិទ្យាល័យ សុខ អាន ថ្នល់បំបែក | ០៩ | ២៧ | |
| ៨ | វិទ្យាល័យ សុខ អាន ខ្វាវ | ២៥ | ៣៤ | |
| ៩ | វិទ្យាល័យ សុខ អាន ខ្វាវ | ១៥ | ៣៤ | |
| ១០ | វិទ្យាល័យ សុខ អាន ខ្វាវ | ០៦ | ២០ | |

## ៤.២ សម្ភារឧបទេស

### ១. តើការបង្រៀន និងរៀនដោយប្រើប្រាស់សម្ភារឧបទេសមានស្ថានភាពយ៉ាងដូចម្តេច?

តាមរយៈសំណួរខាងលើ  អ្នកស្រាវជ្រាវបានធ្វើការសម្ភាសជាមួយគណៈគ្រប់គ្រងសាលាហើយអ្នកស្រាវជ្រាវបានជ្រើសរើសយកសាលាចំនួន៣(បី) គឺ វិទ្យាល័យ សុខ អាន ព្រៃសណ្តែក វិទ្យាល័យ សុខ អានថ្នល់បំបែក និង វិទ្យាល័យ សុខ អានខ្វាវ ហើយលោកនាយិកា នឹង នាយករងនៅវិទ្យាល័យ សុខ អាន ព្រៃសណ្តែក បានផ្តល់ចម្លើយទៅនឹងសំណួរនេះថា ការបង្រៀន និងរៀនដោយប្រើប្រាស់សម្ភារឧបទេស គឺធ្វើឱ្យសិស្សងាយយល់ឆាប់ចាប់បាន មានភាពច្បាស់លាស់ មានសមត្ថភាពពិតប្រាកដនិងច្បាស់។

ចំណែកឯលោកនាយក នឹងនាយករងនៅវិទ្យាល័យ សុខ អាន ថ្នល់បំបែក បានមានប្រសាសន៍ថាការបង្រៀន និងរៀនដោយប្រើប្រាស់សម្ភារឧបទេស គឺធ្វើឱ្យគ្រូមិនសូវហត់ក្នុងការពន្យល់(ងាយពន្យល់) សិស្សឆាប់យល់ ឆាប់ចាប់ខ្លឹមសារមេរៀនបាន។

ក្នុងនោះដែរលោកនាយក និងនាយករងនៅវិទ្យាល័យ សុខ អាន ខ្វាវ ក៏បានមានប្រសាសន៍មិនខុសគ្នាប៉ុន្មានដែរ  គឺពួកគាត់បានឆ្លើយថាការបង្រៀន និងរៀនដោយប្រើប្រាស់សម្ភារឧបទេស គឺធ្វើឱ្យគ្រូងាយស្រួលក្នុងការបង្រៀន ហើយសិស្សឆាប់យល់។

សរុបមកតាមការឆ្លើយរបស់គណៈគ្រប់គ្រងនៅវិទ្យាល័យទាំង៣(បី) ឃើញថាចម្លើយដែលពួកគាត់ផ្តល់ គឺមិនសូវជាខុសគ្នាប៉ុន្មានទេ គឺការបង្រៀន និងរៀនដោយប្រើប្រាស់សម្ភារឧបទេស គឺធ្វើឱ្យគ្រូងាយពន្យល់ សិស្សឆាប់យល់ ធ្វើឱ្យសិស្សមានសមត្ថភាពពេញលេញ សិស្សឆាប់ចាប់បានខ្លឹមសារមេរៀនបានច្បាស់លាស់ ដូចនេះការបង្រៀន និងរៀនដោយប្រើប្រាស់សម្ភារឧបទេស គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់សិស្សានុសិស្ស ក៏ដូចជាលោកគ្រូអ្នកគ្រូផងដែរ។

**២. តើការប្រើប្រាស់សម្ភារឧបទេសបានជួយអ្វីខ្លះដល់ការរៀនសូត្ររបស់សិស្ស និងការបង្រៀនរបស់គ្រូ?**

តាមរយៈសំណួរខាងលើ អ្នកស្រាវជ្រាវបានធ្វើការសម្ភាសជាមួយគណៈគ្រប់គ្រងសាលាហើយអ្នកស្រាវជ្រាវបានជ្រើសរើសយកសាលាចំនួន៣(បី) គឺ វិទ្យាល័យ សុខ អាន ព្រៃសណ្តែក វិទ្យាល័យ សុខ អានថ្នល់បំបែក និង វិទ្យាល័យ សុខ អានខ្វាវ ហើយលោកនាយិកា នឹង នាយករងនៅវិទ្យាល័យ សុខ អាន ព្រៃសណ្តែក បានផ្តល់ចម្លើយទៅនឹងសំណួរនេះថា ការប្រើប្រាស់សម្ភារឧបទេសបានជួយដល់ការរៀនសូត្ររបស់សិស្ស និងការបង្រៀនរបស់គ្រូ គឺសិស្សឆាប់ចេះ យល់ច្បាស់ គ្រូងាយស្រួលពន្យល់ ជួយដល់ការបង្រៀន។

ចំណែកឯលោកនាយក នឹង នាយករងនៅវិទ្យាល័យ សុខ អាន ថ្នល់បំបែក បានមានប្រសាសន៍ថា ការប្រើប្រាស់សម្ភារឧបទេសបានជួយដល់ការរៀនសូត្ររបស់សិស្ស និងការបង្រៀនរបស់គ្រូ គឺសិស្សឆាប់យល់ ចំណេញពេលវេលាក្នុងការបង្រៀន និងរៀន។

ក្នុងនោះដែរលោកនាយក និងនាយករងនៅវិទ្យាល័យ សុខ អាន ខ្វាវ ក៏បានមានប្រសាសន៍មិនខុសគ្នាប៉ុន្មានដែរ គឺពួកគាត់បានឆ្លើយថាការប្រើប្រាស់សម្ភារឧបទេសបានជួយដល់ការរៀនសូត្ររបស់សិស្ស និងការបង្រៀនរបស់គ្រូ គឺសិស្សឆាប់ចាប់បានពីអត្ថន័យ និងខ្លឹមសារមេរៀន ងាយយល់មេរៀន ហើយអាចយល់បានក្នុងរយៈពេលខ្លី និងបង្រៀនបានលឿន។

សរុបមកតាមការឆ្លើយរបស់គណៈគ្រប់គ្រងនៅវិទ្យាល័យទាំង៣(បី) ឃើញថាចម្លើយដែលពួកគាត់ផ្តល់ គឺមិនសូវជាខុសគ្នាប៉ុន្មានទេ គឺការប្រើប្រាស់សម្ភារឧបទេសបានជួយដល់ការរៀនសូត្ររបស់សិស្ស និងការបង្រៀនរបស់គ្រូ គឺសិស្សឆាប់ចេះ យល់ច្បាស់ គ្រូងាយស្រួលពន្យល់ ជួយដល់ការបង្រៀន សិស្សឆាប់

ចាប់បានពីអត្ថន័យ និងខ្លឹមសារមេរៀន ងាយយល់មេរៀន ហើយអាចយល់បានក្នុងរយៈពេលខ្លី និង បង្រៀនបានលឿនទៀតផង។

**៣. តើលោកគ្រូ អ្នកគ្រូភាសាអង់គ្លេសបង្រៀនថ្នាក់ទី១១ គាត់បានទិញសម្ភារអ្វីខ្លះ?**

តាមរយៈសំណួរខាងលើ អ្នកស្រាវជ្រាវបានធ្វើការសម្ភាសជាមួយគណៈគ្រប់គ្រងសាលាហើយអ្នកស្រាវជ្រាវបានជ្រើសរើសយកសាលាចំនួន៣(បី) គឺ វិទ្យាល័យ សុខ អាន ព្រៃសណ្តែក វិទ្យាល័យ សុខ អានថ្នល់បំបែក និង វិទ្យាល័យ សុខ អានខ្វាវ ហើយលោកនាយិកា នឹង នាយករងនៅវិទ្យាល័យ សុខ អាន ព្រៃសណ្តែក បានផ្តល់ចម្លើយទៅនឹងសំណួរនេះថា លោកគ្រូ អ្នកគ្រូភាសាអង់គ្លេសបង្រៀនថ្នាក់ទី១១ គាត់បានទិញសម្ភារមួយចំនួនគឺ ផ្ទាំងរូបភាព ពាក្យស្លោក រូបមន្ត(ទម្រង់) ជាដើម។

ចំណែកឯលោកនាយក នឹងនាយករងនៅវិទ្យាល័យ សុខ អានថ្នល់បំបែកបានមានប្រសាសន៍ថា លោកគ្រូ អ្នកគ្រូភាសាអង់គ្លេសបង្រៀនថ្នាក់ទី១១ គាត់បានទិញរូបភាព ហើយឱ្យសិស្សសរសេរឈ្មោះរូបភាពជាភាសាអង់គ្លេស។

ក្នុងនោះដែរលោកនាយក និងនាយករងនៅវិទ្យាល័យ សុខ អានខ្វាវក៏បានមានប្រសាសន៍ គឺពួកគាត់បានឆ្លើយថា លោកគ្រូ អ្នកគ្រូភាសាអង់គ្លេសបង្រៀនថ្នាក់ទី១១ គាត់បានទិញឧបករណ៍ចាក់សម្លេងឱ្យសិស្សស្តាប់។

សរុបមកតាមការឆ្លើយរបស់គណៈគ្រប់គ្រងនៅវិទ្យាល័យទាំង៣(បី) ឃើញថាចម្លើយដែលពួកគាត់ផ្តល់ គឺមិនសូវជាខុសគ្នាប៉ុន្មានទេ គឺលោកគ្រូ អ្នកគ្រូភាសាអង់គ្លេសបង្រៀនថ្នាក់ទី១១ គាត់បានទិញសម្ភារមួយចំនួនគឺ ផ្ទាំងរូបភាព ពាក្យស្លោក រូបមន្ត(ទម្រង់) រូបភាព ហើយឱ្យសិស្សសរសេរឈ្មោះរូបភាពជាភាសាអង់គ្លេស និងលោកគ្រូ អ្នកគ្រូភាសាអង់គ្លេសបង្រៀនថ្នាក់ទី១១ គាត់បានទិញឧបករណ៍ចាក់សម្លេងឱ្យសិស្សស្តាប់ផងដែរ។

**៤ . តើលោក/លោកស្រីបានត្រួតពិនិត្យចំពោះការរៀបចំសម្ភារឧបទេសដែលមានប្រសិទ្ធភាព និងកិច្ចតែងការបង្រៀនភាសាអង់គ្លេសរបស់គ្រូប្រចាំថ្ងៃដែរឬទេ ?**

| សាលា | មិនដែលសោះ | ធ្វើម្តងម្កាល | ញឹកញាប់ | ញឹកញាប់ខ្លាំង | ធ្វើជាប្រចាំ |
|---|---|---|---|---|---|
| ១. វិទ្យាល័យ សុខ អាន ព្រៃសណ្តែក | 0 | 0 | ៤ | 0 | 0 |
| ២. វិទ្យាល័យ សុខ អាន ថ្នល់បំបែក | 0 | 0 | ៣ | 0 | 0 |
| ៣. វិទ្យាល័យ សុខ អាន ខ្វាវ | 0 | ៣ | 0 | 0 | 0 |

តាមរយៈសំណួរខាងលើ អ្នកស្រាវជ្រាវបានធ្វើការសម្ភាសជាមួយគណៈគ្រប់គ្រងសាលា ហើយអ្នកស្រាវជ្រាវបានជ្រើសរើសយកសាលាចំនួន៣(បី) គឺ វិទ្យាល័យ សុខ អាន ព្រៃសណ្តែក វិទ្យាល័យ សុខ អានថ្នល់បំបែក និងវិទ្យាល័យ សុខ អានខ្វាវ បើក្រឡេកមើលតាមតារាងនេះ សង្កេតឃើញថា លោកនាយិកា នឹង នាយករងនៅវិទ្យាល័យ សុខ អាន ព្រៃសណ្តែក បានផ្តល់ចម្លើយទៅនឹងសំណួរនេះថាពួកគាត់បានត្រួតពិនិត្យចំពោះការរៀបចំសម្ភារឧបទេសដែលមានប្រសិទ្ធភាព និងកិច្ចតែងការបង្រៀនភាសាអង់គ្លេសរបស់គ្រូប្រចាំថ្ងៃជាញឹកញាប់ណាស់។

នេះជាការអនុវត្តតាមគោលការណ៍សិស្សមជ្ឈមណ្ឌល។ បើយើងប្រៀបធៀបសាលាទាំងបីឃើញថា សាលាពីរដែលនៅទីប្រជុំជន មានការអនុវត្តបានល្អប្រសើរជាងសលាមួយនៅតំបន់ដាច់ស្រយ៉ាល។

ចំណែកឯលោកនាយក នឹង នាយករងនៅវិទ្យាល័យ សុខ អានថ្នល់បំបែកបានមានប្រសាសន៍ថាពួកគាត់បានត្រួតពិនិត្យចំពោះការរៀបចំសម្ភារឧបទេសដែលមានប្រសិទ្ធភាព និងកិច្ចតែងការបង្រៀនភាសាអង់គ្លេសរបស់គ្រូប្រចាំថ្ងៃជាញឹកញាប់ដូចគ្នាដែរ។

ក្នុងនោះដែរលោកនាយក និងនាយករងនៅវិទ្យាល័យ សុខ អានខ្វាវក៏បានមានប្រសាសន៍ គឺពួកគាត់បានឆ្លើយថាពួកគាត់បានត្រួតពិនិត្យចំពោះការរៀបចំសម្ភារឧបទេសដែលមានប្រសិទ្ធភាព និងកិច្ចតែងការបង្រៀនភាសាអង់គ្លេសរបស់គ្រូប្រចាំថ្ងៃ ម្តងម្កាលដែរ។

សរុបមកតាមការឆ្លើយរបស់គណៈគ្រប់គ្រងនៅវិទ្យាល័យទាំង៣(បី) ឃើញថាចម្លើយដែលពួកគាត់ផ្តល់ គឺភាគច្រើនពួកគាត់បានត្រួតពិនិត្យចំពោះការរៀបចំសម្ភារឧបទេសដែលមានប្រសិទ្ធភាព និងកិច្ចតែងការបង្រៀនភាសាអង់គ្លេសរបស់គ្រូប្រចាំថ្ងៃជាញឹកញាប់ ដោយឡែកមានតែនៅវិទ្យាល័យ សុខ

អានខ្វាវប៉ុណ្ណោះ ដែលពួកគាត់បានត្រួតពិនិត្យចំពោះការរៀបចំសម្ភារឧបទេសដែលមានប្រសិទ្ធភាព និង កិច្ចតែងការបង្រៀនភាសាអង់គ្លេសរបស់គ្រូប្រចាំថ្ងៃម្តងម្កាលដែរ។

## ៤.៣ កិច្ចតែងការបង្រៀន

ក្នុងផ្នែកកិច្ចតែងការបង្រៀននេះ អ្នកស្រាវជ្រាវបានប្រើប្រាស់សំណួរសម្ភាសន៍ចំនួន ២ ដូចខាងក្រោម និងទទួលបានចម្លើយដូចតទៅ៖

**១.តើលោកគ្រូ អ្នកគ្រូសាលារបស់លោក/លោកស្រីមានកិច្ចតែងការបង្រៀនដែរឬទេក្នុងពេលបង្រៀនសិស្ស?**

| ល.រ | ឈ្មោះសាលា | មានកិច្ចតែងការ | គ្មានកិច្ចតែងការ |
|---|---|---|---|
| ១ | វិទ្យាល័យ សុខ អាន ព្រៃសណ្តែក | ១ | 0 |
| ២ | វិទ្យាល័យ សុខ អាន ព្រៃសណ្តែក | ១ | 0 |
| ៣ | វិទ្យាល័យ សុខ អាន ព្រៃសណ្តែក | ១ | 0 |
| ៤ | វិទ្យាល័យ សុខ អាន ព្រៃសណ្តែក | ១ | 0 |
| ៥ | វិទ្យាល័យ សុខ អាន ថ្នល់បំបែក | ១ | 0 |
| ៦ | វិទ្យាល័យ សុខ អាន ថ្នល់បំបែក | ១ | 0 |
| ៧ | វិទ្យាល័យ សុខ អាន ថ្នល់បំបែក | ១ | 0 |
| ៨ | វិទ្យាល័យ សុខ អាន ខ្វាវ | ១ | 0 |
| ៩ | វិទ្យាល័យ សុខ អាន ខ្វាវ | ១ | 0 |
| ១០ | វិទ្យាល័យ សុខ អាន ខ្វាវ | ១ | 0 |

តាមរយៈសំណួរខាងលើ អ្នកស្រាវជ្រាវបានធ្វើការសម្ភាសជាមួយគណៈគ្រប់គ្រងសាលាហើយអ្នកស្រាវជ្រាវបានជ្រើសរើសយកសាលាចំនួន៣(បី) គឺ វិទ្យាល័យ សុខ អាន ព្រៃសណ្តែក វិទ្យាល័យ សុខ អានថ្នល់បំបែក និង វិទ្យាល័យ សុខ អានខ្វាវ បើក្រឡេកមើលតាមតារាងនេះ សង្កេតឃើញថា លោកស្រីនាយិកា នឹងនាយក-នាយករងនៅសាលាទាំង៣(បី)គឺបានផ្តល់ចម្លើយដូចៗគ្នា គឺពួកគាត់មានប្រសាសន៍ថាលោកគ្រូ អ្នកគ្រូសាលារបស់លោក/លោកស្រី គឺសុទ្ធតែមានកិច្ចតែងការបង្រៀនក្នុងពេលបង្រៀនសិស្ស។

២.តើលោក/លោកស្រីធ្លាប់បានត្រួតពិនិត្យ ឬចុះទិដ្ឋការលើកិច្ចតែងការបង្រៀនលើមុខវិជ្ជាប៉ុន្មានដងហើយក្នុងឆ្នាំសិក្សា២០១៩-២០២០នេះ?

| ចុះទិដ្ឋការ (ត្រួតពិនិត្យ) | | | | |
|---|---|---|---|---|
| ឈ្មោះសាលា | ០ ដង | ១ ដង | ២ ដង | ៣ ដងឡើងទៅ |
| វិទ្យាល័យ សុខ អាន ព្រៃសណ្តែក | | | | √ |
| វិទ្យាល័យ សុខ អាន ថ្នល់បំបែក | | | √ | |
| វិទ្យាល័យ សុខ អាន ខ្វាវ | | | √ | |

តាមរយៈសំណួរខាងលើ អ្នកស្រាវជ្រាវបានធ្វើការសម្ភាសជាមួយគណៈគ្រប់គ្រងសាលាហើយអ្នកស្រាវជ្រាវបានជ្រើសរើសយកសាលាចំនួន៣(បី) គឺ វិទ្យាល័យ សុខ អាន ព្រៃសណ្តែក វិទ្យាល័យ សុខ អានថ្នល់បំបែក និង វិទ្យាល័យ សុខអានខ្វាវ បើក្រឡេកមើលតាមតារាងនេះ សង្កេតឃើញថា លោកស្រីនាយិកា នឹង នាយករងនៅវិទ្យាល័យ សុខ អាន ព្រៃសណ្តែក បានផ្តល់ចម្លើយទៅនឹងសំណួរនេះថា ពួកគាត់បានត្រួតពិនិត្យ ឬចុះទិដ្ឋការលើកិច្ចតែងការបង្រៀនលើមុខវិជ្ជារហូតដល់ទៅ៣ដងឬលើសពី៣ដងឯណោះក្នុងឆ្នាំសិក្សា២០១៩-២០២០នេះ។

ចំណែកឯលោកនាយក នឹង នាយករងនៅវិទ្យាល័យ សុខ អានថ្នល់បំបែកនិងលោកនាយក នឹង នាយករងនៅវិទ្យាល័យ សុខ អាន ខ្វាវ បានមានប្រសាសន៍ដូចគ្នាថាពួកគាត់បានត្រួតពិនិត្យ ឬចុះទិដ្ឋការលើកិច្ចតែងការបង្រៀនលើមុខវិជ្ជារហូតដល់ទៅ២ដងក្នុងឆ្នាំសិក្សា២០១៩-២០២០នេះ។

សរុបមកតាមការឆ្លើយរបស់គណៈគ្រប់គ្រងនៅវិទ្យាល័យទាំង៣(បី) ឃើញថាចម្លើយដែលពួកគាត់ផ្តល់ គឺពួកគាត់សុទ្ធតែបានត្រួតពិនិត្យ ឬចុះទិដ្ឋការលើកិច្ចតែងការបង្រៀនលើមុខវិជ្ជារហូតដល់ទៅ២ដង ៣ដងឬលើសពី៣ដងក៏មានដែរក្នុងឆ្នាំសិក្សា២០១៩-២០២០នេះ។

### ៤.៤ អធិការកិច្ច

នៅក្នុងការធ្វើអធិការកិច្ចនេះ អ្នកស្រាវជ្រាវបានប្រើប្រាស់សំណួរសម្ភាសន៍ចំនួន ៣ ដូចខាងក្រោម និងទទួលបានចម្លើយដូចតទៅៈ

**១.តើលោក/លោកស្រីយល់យ៉ាងដូចម្តេចចំពោះស្ថានភាពនៃការចុះអធិការកិច្ចមើលការបង្រៀន និងរៀនរបស់សិស្ស?**

តាមរយៈសំណួរខាងលើ អ្នកស្រាវជ្រាវបានធ្វើការសម្ភាសជាមួយគណៈគ្រប់គ្រងសាលាហើយអ្នកស្រាវជ្រាវបានជ្រើសរើសយកសាលាចំនួន៣(បី) គឺ វិទ្យាល័យ សុខ អាន ព្រៃសណ្តែក វិទ្យាល័យ សុខ អានថ្នល់បំបែក និង វិទ្យាល័យ សុខ អានខ្វាវ ហើយលោកស្រីនាយិកា នឹង នាយករងនៅវិទ្យាល័យ សុខ អាន ព្រៃសណ្តែក បានផ្តល់ចម្លើយទៅនឹងសំណួរនេះថា ចំពោះស្ថានភាពនៃការចុះអធិការកិច្ចមើលការបង្រៀន និងរៀនរបស់សិស្ស គឺអាចជួយពង្រឹងសមត្ថភាពរបស់គ្រូ គ្រូនិងសិស្សមានទំនាក់ទំនងគ្នាបានល្អ ហើយធ្វើឱ្យមានការត្រៀមក្នុងការបង្រៀន និងរៀនបានល្អ។

ចំណែកឯលោកនាយក និង នាយករងនៅវិទ្យាល័យ សុខ អានថ្នល់បំបែកបានមានប្រសាសន៍ថា ចំពោះស្ថានភាពនៃការចុះអធិការកិច្ចមើលការបង្រៀន និងរៀនរបស់សិស្ស គឺធ្វើឱ្យមានការយកចិត្តទុកដាក់លើការបង្រៀន និងរៀនលើមុខវិជ្ជានេះ។

ក្នុងនោះដែរលោកនាយក និងនាយករងនៅវិទ្យាល័យ សុខ អាន ខ្វាវ ក៏បានមានប្រសាសន៍មិនខុសគ្នាប៉ុន្មានដែរ គឺពួកគាត់បានឆ្លើយថា ចំពោះស្ថានភាពនៃការចុះអធិការកិច្ចមើលការបង្រៀន និងរៀនរបស់សិស្ស គឺធ្វើឱ្យសិស្សមានការយកចិត្តទុកដាក់លើការបង្រៀន និងរៀនលើមុខវិជ្ជានេះបានខ្ពស់ហើយបានជួយកែលម្អនៅចំណុចខ្វះខាតរបស់គ្រូ និងសិស្ស។

សរុបមកតាមការឆ្លើយរបស់គណៈគ្រប់គ្រងនៅវិទ្យាល័យទាំង៣(បី) ឃើញថាចម្លើយដែលពួកគាត់ផ្តល់ គឺមិនសូវជាខុសគ្នាប៉ុន្មានទេ គឺចំពោះស្ថានភាពនៃការចុះអធិការកិច្ចមើលការបង្រៀន និងរៀនរបស់សិស្ស គឺអាចជួយពង្រឹងសមត្ថភាពរបស់គ្រូ គ្រូនិងសិស្សមានទំនាក់ទំនងគ្នាបានល្អ ធ្វើឱ្យមានការត្រៀមក្នុងការបង្រៀន និងរៀនបានល្អ សិស្សមានការយកចិត្តទុកដាក់លើការបង្រៀន និងរៀនលើមុខវិជ្ជានេះបានខ្ពស់ ហើយបានជួយកែលម្អនៅចំណុចខ្វះខាតរបស់គ្រូ និងសិស្ស។

**២. តើលោក/លោកស្រីយល់ថាការចុះអធិការកិច្ចបានជួយអ្វីខ្លះ ដល់គ្រូ និងសិស្ស?**

តាមរយៈសំណួរខាងលើ អ្នកស្រាវជ្រាវបានធ្វើការសម្ភាសជាមួយគណៈគ្រប់គ្រងសាលាហើយអ្នកស្រាវជ្រាវបានជ្រើសរើសយកសាលាចំនួន៣(បី) គឺ វិទ្យាល័យ សុខ អាន ព្រៃសណ្ដែក វិទ្យាល័យ សុខ អានថ្នល់បំបែក និង វិទ្យាល័យ សុខ អានខ្វាវ ហើយលោកស្រីនាយិកា នឹង នាយករងនៅវិទ្យាល័យ សុខ អាន ព្រៃសណ្ដែក បានផ្ដល់ចម្លើយទៅនឹងសំណួរនេះថា ការចុះអធិការកិច្ច បានធ្វើឱ្យការបង្រៀន និងរៀនទទួលបានជោគជ័យតាមវត្ថុបំណង និងទទួលបានលទ្ធផលល្អ។

ចំណែកឯលោកនាយក នឹងនាយករងនៅវិទ្យាល័យ សុខ អាន ថ្នល់បំបែក បានមានប្រសាសន៍ថា ការចុះអធិការកិច្ច គឺអាចជួយបំពេញបន្ថែមលើចំណុចខ្វះខាត និងកែលម្អដល់លោកគ្រូ និងសិស្សផងដែរ។

ក្នុងនោះដែរលោកនាយក និងនាយករងនៅវិទ្យាល័យ សុខ អានខ្វាវក៏បានមានប្រសាសន៍ដែរថា ការចុះអធិការកិច្ច គឺជួយគ្រូឱ្យប្រើប្រាស់វិធីសាស្ត្របានត្រឹមត្រូវតាមមេរៀននីមួយៗ សិស្សចេះបង្កើតក្រុមសិក្សាគ្រូបង្រៀនចេះប្រើប្រាស់សម្ភារឧបទេស ចេះកំណត់វត្ថុបំណងមេរៀនហើយគឺអាចជួយបំពេញលើចំណុចខ្វះខាតក្នុងការបង្រៀន និងរៀន។

សរុបមកតាមការឆ្លើយរបស់គណៈគ្រប់គ្រងនៅវិទ្យាល័យទាំង៣(បី) ឃើញថាចម្លើយដែលពួកគាត់ផ្ដល់ គឺមិនសូវជាខុសគ្នាប៉ុន្មានទេ គឺការចុះអធិការកិច្ច គឺជួយគ្រូឱ្យប្រើប្រាស់ វិធីសាស្ត្របានត្រឹមត្រូវតាមមេរៀននីមួយៗ សិស្សចេះបង្កើតក្រុមសិក្សា គ្រូបង្រៀនចេះប្រើប្រាស់សម្ភារឧបទេស ចេះកំណត់វត្ថុបំណងមេរៀន ហើយគឺអាចជួយបំពេញបន្ថែមលើចំណុចខ្វះខាត ក្នុងការបង្រៀន និងរៀន និងកែលម្អដល់លោកគ្រូ និងសិស្ស ការចុះអធិការកិច្ច បានធ្វើឱ្យការបង្រៀន និងរៀន ទទួលបានជោគជ័យតាមវត្ថុបំណង និងទទួលបានលទ្ធផលល្អ។

**៣. តើលោក/លោកស្រីយល់ថាវិធីសាស្ត្របង្រៀនដែលគាត់ប្រើប្រាស់នៅមានចំណុចខ្វះខាតដែរឬទេ? បើមានចំណុចខ្វះខាត តើមានចំណុចអ្វីខ្លះ ?**

តាមរយៈសំណួរខាងលើ អ្នកស្រាវជ្រាវបានធ្វើការសម្ភាសជាមួយគណៈគ្រប់គ្រងសាលាហើយអ្នកស្រាវជ្រាវបានជ្រើសរើសយកសាលាចំនួន៣(បី) គឺ វិទ្យាល័យ សុខ អាន ព្រៃសណ្ដែក វិទ្យាល័យ សុខ

អានថ្នល់បំបែក និង វិទ្យាល័យ សុខ អានខ្វាវ ហើយលោកស្រីនាយិកា នឹង នាយករងនៅវិទ្យាល័យ សុខ អាន ព្រៃសណ្តែក បានផ្តល់ចម្លើយទៅនឹងសំណួរនេះថា វិធីសាស្រ្តបង្រៀន ដែលគាត់ប្រើប្រាស់នៅមានចំណុចខ្វះខាត គឺសម្ភារឧបទេស នៅមានកម្រិត មិនទាន់គ្រប់គ្រាន់( នៅខ្វះខាត )។

ចំណែកឯលោកនាយក នឹងនាយករងនៅវិទ្យាល័យ សុខ អានថ្នល់បំបែកបានមានប្រសាសន៍ថា វិធីសាស្រ្តបង្រៀនដែលគាត់ប្រើប្រាស់នៅមានចំណុចខ្វះខាត គឺពួកគាត់អាន ឬនិយាយញាប់ធ្វើឱ្យសិស្សមានការពិបាកស្តាប់។

ក្នុងនោះដែរលោកនាយក និងនាយករងនៅវិទ្យាល័យ សុខ អាន ខ្វាវ ក៏បានមានប្រសាសន៍ដែរថាវិធីសាស្រ្តបង្រៀន ដែលគាត់ប្រើប្រាស់នៅមានចំណុចខ្វះខាត គឺចំណុចមេរៀនខ្លះ គ្រូប្រើវិធីសាស្រ្តគ្រូមជ្ឈមណ្ឌល។

សរុបមកតាមការឆ្លើយរបស់គណៈគ្រប់គ្រងនៅវិទ្យាល័យទាំង៣(បី) ឃើញថាចម្លើយដែលពួកគាត់ផ្តល់ គឺមិនសូវជាខុសគ្នាប៉ុន្មានទេ គឺវិធីសាស្រ្តបង្រៀនដែលគាត់ប្រើប្រាស់គឺសុទ្ធតែនៅមានចំណុចខ្វះខាត គឺសម្ភារឧប ទេស នៅមានកម្រិតមិនទាន់គ្រប់គ្រាន់(នៅខ្វះខាត) ពួកគាត់អានឬនិយាយញាប់ធ្វើឱ្យសិស្សមានការពិបាកស្តាប់ហើយចំណុចមេរៀនខ្លះ គ្រូប្រើវិធីសាស្រ្តគ្រូមជ្ឈមណ្ឌល។

## ៤.៥ សកម្មភាពពេលកំពុងបង្រៀន

នៅក្នុងចំនុចសកម្មភាពពេលកំពុងបង្រៀននេះ អ្នកស្រាវជ្រាវបានប្រើប្រាស់សំណួរសម្ភាសន៍ចំនួន ៥ ដូចខាងក្រោម និងទទួលបានចម្លើយដូចតទៅ៖

**១. តើនៅក្នុងថ្នាក់រៀនរបស់សាលាមានសិស្សថ្នាក់ទី១១ ចំនួនប៉ុន្មាននាក់ក្នុងមួយថ្នាក់ៗ ?**

តាមរយៈសំណួរខាងលើ អ្នកស្រាវជ្រាវបានធ្វើការសម្ភាសជាមួយគណៈគ្រប់គ្រងសាលាហើយអ្នកស្រាវជ្រាវបានជ្រើសរើសយកសាលាចំនួន៣(បី) គឺ វិទ្យាល័យ សុខ អាន ព្រៃសណ្តែក វិទ្យាល័យ សុខ អានថ្នល់បំបែក និង វិទ្យាល័យ សុខ អានខ្វាវ ហើយលោកស្រីនាយិកា នឹង នាយករងនៅវិទ្យាល័យ សុខ អាន ព្រៃសណ្តែក បានផ្តល់ចម្លើយទៅនឹងសំណួរនេះថា នៅក្នុងថ្នាក់រៀនរបស់សាលាមានសិស្សថ្នាក់ទី ១១ ចំនួន៤០(សែសិប)នាក់ជាមធ្យម ក្នុងមួយថ្នាក់ៗ។

ចំណែកឯលោកនាយក នឹង នាយករងនៅវិទ្យាល័យ សុខ អានថ្នល់បំបែកបានមានប្រសាសន៍ថា នៅក្នុងថ្នាក់រៀនរបស់សាលាមានសិស្សថ្នាក់ទី១១ ចំនួនចាប់ពី៤០(សែសិប)នាក់ ទៅ៤៥(សែសិបប្រាំ)នាក់ ក្នុងមួយថ្នាក់ៗ។

ក្នុងនោះដែរលោកនាយក និងនាយករងនៅវិទ្យាល័យ សុខ អានខ្វាវក៏បានមានប្រសាសន៍ដែរថា នៅក្នុងថ្នាក់រៀនរបស់សាលាមានសិស្សថ្នាក់ទី១១ ចំនួន៤៧(សែសិបប្រាំពីរ)នាក់ ក្នុងមួយថ្នាក់ៗ។

សរុបមកតាមការឆ្លើយរបស់គណៈគ្រប់គ្រងនៅវិទ្យាល័យទាំង៣(បី) ឃើញថាចម្លើយដែលពួកគាត់ផ្តល់ គឺមិនសូវជាខុសគ្នាប៉ុន្មានទេ នៅក្នុងថ្នាក់រៀនរបស់សាលាមានសិស្សថ្នាក់ទី១១ ចំនួន៤០(សែសិប)នាក់ជាមធ្យមហើយសាលាខ្លះមានសិស្សថ្នាក់ទី១១ហួតទៅដល់៤៧(សែសិបប្រាំពីរ)នាក់ ក្នុងមួយថ្នាក់ៗ។

**២. តាមយោបល់របស់លោក/លោកស្រី តើលោកគ្រូ អ្នកគ្រូបង្រៀន គួរកែលម្អនៅត្រង់ចំណុចណាខ្លះ ដើម្បីឱ្យសិស្សងាយយល់ខ្លឹមសារមេរៀន ?**

តាមរយៈសំណួរខាងលើ អ្នកស្រាវជ្រាវបានធ្វើការសម្ភាសជាមួយគណៈគ្រប់គ្រងសាលាហើយអ្នកស្រាវជ្រាវបានជ្រើសរើសយកសាលាចំនួន៣(បី) គឺ វិទ្យាល័យ សុខ អាន ព្រៃសណ្តែក វិទ្យាល័យ សុខ អានថ្នល់បំបែក និង វិទ្យាល័យ សុខ អានខ្វាវ ហើយលោកស្រីនាយិកា នឹង នាយករងនៅវិទ្យាល័យ សុខ អាន ព្រៃសណ្តែក បានផ្តល់ចម្លើយទៅនឹងសំណួរនេះថា តាមយោបល់របស់ពួកគាត់លោកគ្រូ អ្នកគ្រូបង្រៀន គួរតែអនុវត្តការបង្រៀនគោលវិធីសិស្សមជ្ឈមណ្ឌលជាប្រចាំ និងមានសម្ភារឧបទេសគ្រប់គ្រាន់។

ចំណែកឯលោកនាយក នឹង នាយករងនៅវិទ្យាល័យ សុខ អានថ្នល់បំបែកបានមានប្រសាសន៍ថាតាមយោបល់របស់ពួកគាត់លោកគ្រូ អ្នកគ្រូបង្រៀនគួរតែអានឱ្យច្បាស់ ហើយយឺតដើម្បីឱ្យសិស្សងាយយល់នូវពាក្យ និងពន្យល់ដោយមានឧទាហរណ៍ច្រើន។

ក្នុងនោះដែរលោកនាយក និងនាយករងនៅវិទ្យាល័យ សុខ អាន ខ្វាវ ក៏បានមានប្រសាសន៍ដែរថាតាមយោបល់របស់ពួកគាត់លោកគ្រូ អ្នកគ្រូបង្រៀន គួរតែកំណត់វត្ថុបំណងមេរៀនឱ្យបានច្បាស់លាស់ អានឱ្យបានច្រើនសារ និងត្រូវចេះសង្ខេបខ្លឹមសារមេរៀន។

សរុបមកតាមការឆ្លើយរបស់គណៈគ្រប់គ្រងនៅវិទ្យាល័យទាំង៣(បី) ឃើញថាចម្លើយដែលពួកគាត់ផ្តល់ គឺតាមយោបល់របស់ពួកគាត់លោកគ្រូ អ្នកគ្រូបង្រៀន គួរតែអនុវត្តការបង្រៀនគោលវិធីសិស្សមជ្ឈមណ្ឌលជាប្រចាំ និងមានសម្ភារឧបទេសគ្រប់គ្រាន់ អានឱ្យច្បាស់ ហើយយឺតដើម្បីឱ្យសិស្សងាយយល់នូវពាក្យ និងពន្យល់ដោយមានឧទាហរណ៍ច្រើន និងកំណត់វត្ថុបំណងមេរៀនឱ្យបានច្បាស់លាស់ អានឱ្យបានច្រើនសារ និងត្រូវចេះសង្ខេបខ្លឹមសារមេរៀន។

**៣. តើលោក/លោកស្រីត្រូវធ្វើដូចម្តេចដើម្បីជួយជម្រុញលោកគ្រូអ្នកគ្រូឱ្យអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅថ្នាក់ទី១១ កាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ ?**

តាមរយៈសំណួរខាងលើ អ្នកស្រាវជ្រាវបានធ្វើការសម្ភាសជាមួយគណៈគ្រប់គ្រងសាលាហើយអ្នកស្រាវជ្រាវបានជ្រើសរើសយកសាលាចំនួន៣(បី) គឺ វិទ្យាល័យ សុខ អាន ព្រៃសណ្តែក វិទ្យាល័យ សុខ អានថ្នល់បំបែក និង វិទ្យាល័យ សុខ អានខ្វាវ ហើយលោកស្រីនាយិកា នឹង នាយករងនៅវិទ្យាល័យ សុខ អាន ព្រៃសណ្តែក បានផ្តល់ចម្លើយទៅនឹងសំណួរនេះថា ដើម្បីជួយជម្រុញលោកគ្រូ អ្នកគ្រូឱ្យអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅថ្នាក់ទី១១ កាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ គឺត្រូវប្រជុំក្រុមបច្ចេកទេសជាប្រចាំ។

ចំណែកឯលោកនាយក នឹង នាយករងនៅវិទ្យាល័យ សុខ អានថ្នល់បំបែកបានមានប្រសាសន៍ថា ដើម្បីជួយជម្រុញលោកគ្រូ អ្នកគ្រូឱ្យអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅថ្នាក់ទី១១ កាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ គឺត្រូវចុះតាមដាន សង្កេតការបង្រៀន និងរៀនឱ្យបានញឹកញាប់។

ក្នុងនោះដែរលោកនាយក និងនាយករងនៅវិទ្យាល័យ សុខ អាន ខ្វាវ ក៏បានមានប្រសាសន៍ដែរថា ដើម្បីជួយជម្រុញលោកគ្រូ អ្នកគ្រូឱ្យអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅថ្នាក់ទី១១ កាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ គឺត្រូវយកចិត្តទុកដាក់ក្នុងការបង្រៀន ចេះជម្រុញ និងបែងចែកក្រុមពិភាក្សា ហើយត្រូវរៀបចំមេរៀនទៅតាមគោលវិធីសិស្សមជ្ឈមណ្ឌលឱ្យបានត្រឹមត្រូវ។

សរុបមកតាមការឆ្លើយរបស់គណៈគ្រប់គ្រងនៅវិទ្យាល័យទាំង៣(បី) ឃើញថាចម្លើយដែលពួកគាត់ផ្តល់គឺ ដើម្បីជួយជម្រុញលោកគ្រូ អ្នកគ្រូឱ្យអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅថ្នាក់ទី១១ កាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ គឺត្រូវប្រជុំក្រុមបច្ចេកទេសជាប្រចាំ ត្រូវចុះតាមដាន សង្កេតការបង្រៀន និងរៀនឱ្យបានញឹកញាប់ និងត្រូវយកចិត្តទុកដាក់ក្នុងការបង្រៀនចេះជម្រុញ និងបែងចែកក្រុមពិភាក្សាហើយត្រូវរៀបចំមេរៀនទៅតាមគោលវិធីសិស្សមជ្ឈមណ្ឌលឱ្យបានត្រឹមត្រូវ។

**៤. តើលោក/លោកស្រីយល់ថាការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅថ្នាក់ទី១១ មានគុណសម្បត្តិ និងគុណវិបត្តិយ៉ាងដូចម្ដេចខ្លះ ?**

តាមរយៈសំណួរខាងលើ អ្នកស្រាវជ្រាវបានធ្វើការសម្ភាសជាមួយគណៈគ្រប់គ្រងសាលាហើយអ្នកស្រាវជ្រាវបានជ្រើសរើសយកសាលាចំនួន៣(បី) គឺ វិទ្យាល័យ សុខ អាន ព្រៃសណ្ដែក វិទ្យាល័យ សុខ អានថ្នល់បំបែក និង វិទ្យាល័យ សុខ អានខ្វាវ ហើយលោកស្រីនាយិកា នឹង នាយករងនៅវិទ្យាល័យ សុខ អាន ព្រៃសណ្ដែក បានផ្ដល់ចម្លើយទៅនឹងសំណួរនេះថា ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅថ្នាក់ទី១១ មានគុណសម្បត្តិគឺ មានចំណេះដឹងទូលំទូលាយ ទំនាក់ទំនងល្អរវាងគ្រូ និងសិស្ស ធ្វើឱ្យងាយយល់ ឆាប់ចាប់មេរៀនបាន ងាយស្រួលបង្រៀន និងមានទំនាក់ទំនងល្អរវាងជាតិ និងអន្តរជាតិ។ ក្នុងនោះដែរការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅថ្នាក់ទី១១ ក៏មានគុណវិបត្តិដែរគឺ សិស្សមួយចំនួនសមត្ថភាពនៅមានកម្រិត(នៅខ្សោយ) ខ្វះការចូលរួម ហើយសិស្សមួយចំនួនមិនទាន់សកម្ម ដោយពឹងផ្អែកទៅលើមិត្តភក្តិ។

ចំណែកឯលោកនាយក នឹង នាយករងនៅវិទ្យាល័យ សុខ អានថ្នល់បំបែកបានមានប្រសាសន៍ថា ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅថ្នាក់ទី១១ មានគុណសម្បត្តិគឺ សិស្សចេះស្រាវជ្រាវ ចេះបញ្ចេញមតិយោបល់ ចេះកែលម្អចម្លើយ និងបានប្រើសកម្មភាពច្រើន។ ក្នុងនោះដែរការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅថ្នាក់ទី១១ ក៏មានគុណវិបត្តិដែរគឺ មិនបានពិចារណាគ្រប់សំណួរ ហើយសិស្សខ្លះសមត្ថភាពនៅមានកម្រិត។

ហើយលោកនាយក និងនាយករងនៅវិទ្យាល័យ សុខ អានខ្វាវក៏បានមានប្រសាសន៍ដែរថាការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅថ្នាក់ទី១១ មានគុណសម្បត្តិគឺធ្វើឱ្យសិស្សឆាប់ចាប់បាននូវខ្លឹមសារមេរៀន ឆាប់ចេះអាន និងសរសេរ សិស្សរៀនឆាប់ចេះ យកចិត្តទុកដាក់ក្នុងការរៀនសូត្រ និងធ្វើឱ្យការបង្រៀនប្រព្រឹត្តទៅដោយរលូន។ ក្នុងនោះដែរការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅថ្នាក់ទី១១ ក៏មានគុណវិបត្តិដែរគឺ សិស្សខ្វះនូវឯកសារមេរៀន ជាពិសេសសៀវភៅសិក្សាគោល(ផ្នែកអង់គ្លេស) ធ្វើឱ្យមានការពិបាករៀន។

សរុបមកតាមការឆ្លើយរបស់គណៈគ្រប់គ្រងនៅវិទ្យាល័យទាំង៣(បី)ឃើញថាចម្លើយដែលពួកគាត់ផ្តល់គឺការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅថ្នាក់ទី១១ មានគុណសម្បត្តិមួយចំនួនគឺ សិស្សចេះស្រាវជ្រាវ ចេះបញ្ចេញមតិយោបល់ ចេះកែលម្អចម្លើយ និងបានប្រើសកម្មភាពច្រើនធ្វើឱ្យសិស្សឆាប់ចាប់បាននូវខ្លឹមសារមេរៀន ឆាប់ចេះអាន និងសរសេរ សិស្សរៀនឆាប់ចេះ យកចិត្តទុកដាក់ក្នុងការរៀនសូត្រ និងធ្វើឱ្យការបង្រៀនប្រព្រឹត្តទៅដោយរលូន មានចំណេះដឹងទូលំទូលាយ ទំនាក់ទំនងល្អរវាងគ្រូ និងសិស្ស ធ្វើឱ្យងាយយល់ ឆាប់ចាប់មេរៀនបាន ងាយស្រួលបង្រៀន និងមានទំនាក់ទំនងល្អរវាងជាតិ និងអន្តរជាតិ។ ហើយក្នុងនោះដែរការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅថ្នាក់ទី១១ ក៏មានគុណវិបត្តិមួយចំនួនដែរគឺ សិស្សមួយចំនួនសមត្ថភាពនៅមានកម្រិត(នៅខ្សោយ) ខ្វះការចូលរួម ហើយសិស្សមួយចំនួនមិនទាន់សកម្ម ដោយពឹងផ្អែកទៅលើមិត្តភក្តិ មិនបានពិចារណាគ្រប់សំណួរ សិស្សខ្វះនូវឯកសារមេរៀន ជាពិសេសសៀវភៅសិក្សាគោល (ផ្នែកអង់គ្លេស) ធ្វើឱ្យមានការពិបាករៀន។

**៥. តើលោក/លោកស្រីមានសំណូមពរអ្វីខ្លះ ដើម្បីឱ្យស្ថានភាពនៃការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅថ្នាក់ទី១១ នៅក្នុងសាលារបស់លោក/លោកស្រីកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ ?**

តាមរយៈសំណួរខាងលើ អ្នកស្រាវជ្រាវបានធ្វើការសម្ភាសជាមួយគណៈគ្រប់គ្រងសាលាហើយអ្នកស្រាវជ្រាវបានជ្រើសរើសយកសាលាចំនួន៣(បី) គឺ វិទ្យាល័យ សុខ អាន ព្រៃសណ្តែក វិទ្យាល័យ សុខ

អានថ្នល់បំបែក និង វិទ្យាល័យ សុខ អានខ្វាវ ហើយលោកស្រីនាយិកា នឹង នាយករងនៅវិទ្យាល័យ សុខ អាន ព្រៃសណ្តែក បានផ្តល់ចម្លើយទៅនឹងសំណួរនេះថា ដើម្បីឱ្យស្ថានភាពនៃការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅថ្នាក់ទី១១ នៅក្នុងសាលារបស់ពួកគាត់ កាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ គឺគាត់ចង់ឱ្យមានការបើកសិក្ខាសិលា ពង្រឹងសមត្ថភាពគ្រូ ហើយនិងមានការប្រជុំក្នុងសាលាឱ្យបានញឹកញាប់។

ចំណែកឯលោកនាយក នឹង នាយករងនៅវិទ្យាល័យ សុខ អានថ្នល់បំបែកបានមានប្រសាសន៍ថា ដើម្បីឱ្យស្ថានភាពនៃការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅថ្នាក់ទី១១ នៅក្នុងសាលារបស់ពួកគាត់ កាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ គឺគាត់ចង់ឱ្យមានការបណ្តុះបណ្តាលបន្ថែម និងឧបត្ថម្ភបន្ថែមនូវសម្ភារឧបទេស ក្នុងការបង្រៀន។

ហើយលោកនាយក និងនាយករងនៅវិទ្យាល័យ សុខ អានខ្វាវក៏បានមានប្រសាសន៍ដែរថា ដើម្បីឱ្យស្ថានភាពនៃការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅថ្នាក់ទី ១១ នៅក្នុងសាលារបស់ពួកគាត់ កាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ គឺគាត់ចង់ផ្តល់នូវសៀវភៅសិក្សាគោល និងសម្ភារឧបទេសដល់សិស្សានុសិស្ស និងវិទ្យាល័យឱ្យបានទាន់ពេលវេលា។

សរុបមកតាមការឆ្លើយរបស់គណៈគ្រប់គ្រងនៅវិទ្យាល័យទាំង៣(បី)ឃើញថាចម្លើយដែលពួកគាត់ផ្តល់គឺ ដើម្បីឱ្យស្ថានភាពនៃការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅថ្នាក់ទី១១ នៅក្នុងសាលារបស់ពួកគាត់ កាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ គឺគាត់ចង់ឱ្យមានការបើកសិក្ខាសិលា ពង្រឹងសមត្ថភាពគ្រូ ហើយនិងមានការប្រជុំក្នុងសាលាឱ្យបានញឹកញាប់ មានការបណ្តុះបណ្តាលបន្ថែម និងឧបត្ថម្ភបន្ថែមនូវសម្ភារឧបទេស ក្នុងការបង្រៀន និងផ្តល់នូវសៀវភៅសិក្សាគោលដល់សិស្សានុសិស្ស និងវិទ្យាល័យឱ្យបានទាន់ពេលវេលា។

## ៤.៦ ការសម្ភាសន៍ជាមួយគ្រូបង្រៀនភាសាអង់គ្លេស

អ្នកស្រាវជ្រាវបានធ្វើការសម្ភាសន៍លោកគ្រូអ្នកគ្រូបង្រៀនភាសាអង់គ្លេសទាំងបីសាលាទាក់ទងនឹងប្រធានបទដែលបានជ្រើសរើស ហើយលទ្ធផលទទួលបានដូចខាងក្រោម៖

### ៤.៦.១ ស្ថិតិលោកគ្រូអ្នកបង្រៀនភាសាអង់គ្លេស

| ល.រ | ឈ្មោះសាលា | ភេទ | អាយុ | ឃុំ | កម្រិតវប្បធម៌ | បទពិសោធន៍បង្រៀន |
|---|---|---|---|---|---|---|
| ១ | វិទ្យាល័យ សុខ អានព្រៃសណ្តែក | ប្រុស | ៥២ | ព្រៃស្លឹក | បរិញ្ញាបត្រ | លើសពី ០៦ឆ្នាំ |
| ២ | វិទ្យាល័យ សុខ អានព្រៃសណ្តែក | ប្រុស | ៤២ | ព្រៃស្លឹក | បរិញ្ញាបត្រ | លើសពី ០៦ឆ្នាំ |
| ៣ | វិទ្យាល័យ សុខ អានព្រៃសណ្តែក | ស្រី | ៣៦ | ព្រៃស្លឹក | បរិញ្ញាបត្រ | លើសពី ០៦ឆ្នាំ |
| ៤ | វិទ្យាល័យ សុខ អានព្រៃសណ្តែក | ប្រុស | ៣៨ | ព្រៃស្លឹក | បរិញ្ញាបត្រ | លើសពី ០៦ឆ្នាំ |
| ១០ | សិស្សចេះអនុវត្តបានដោយមានអ្នកជួយ (សិស្សមិត្តភក្តិ) | ០៧ | ១៩ | ១៨ | ០៨ | ០៣ |
| ១១ | សិស្សជាអ្នកស្វែងយល់ ឡើងសរសេររូបមន្ត ខ្លឹមសារសំខាន់ៗ និងដោះស្រាយលំហាត់ | ០៦ | ១៤ | ២៣ | ១០ | ០២ |

| ល.រ | ការអនុវត្តសកម្មភាពបង្រៀន និងរៀនភាសាអង់គ្លេស ថ្នាក់ទី១១ (សកម្មភាពគ្រូ និង សកម្មភាពសិស្ស | កម្រិតនៃការអនុវត្ត | | | | |
|---|---|---|---|---|---|---|
| | | 5 | 4 | 3 | 2 | 1 |
| | | ញឹកញាប់បំផុត | ញឹកញាប់ | មធ្យម | តិចតួច | អត់ដែលសោះ |
| **១. សកម្មភាពគ្រូ** | | | | | | |
| ១ | គ្រូប្រើផ្ទាំងរូបភាពរំឭកមេរៀនលើកមុន | ០០ | ០៥ | ១០ | ១៦ | ១៣ |
| ២ | គ្រូធ្វើលំហាត់គំរូឱ្យសិស្សមើល | ០៤ | ១៦ | ២២ | ០២ | ០០ |
| ៣ | គ្រូណែនាំសិស្សឱ្យធ្វើការងារតាមក្រុម | ០៣ | ១០ | ២៦ | ០៥ | ០០ |
| ៤ | គ្រូពន្យល់ធ្វើអត្ថាធិប្បាយ និងពណ៌នា | ០៨ | ១៧ | ១៥ | ០៤ | ០០ |
| ៥ | គ្រូចោទបញ្ហាៗ ឬដោះស្រាយតែម្នាក់ឯង | ០០ | ០៣ | ០៧ | ២៧ | ០៧ |
| ៦ | គ្រូគូរ សរសេរ ឬស្រាយបំភ្លឺចម្លើយលើក្តារខៀន | ១២ | ១៦ | ១៤ | ០១ | ០១ |
| ៧ | គ្រូមិនអើពើចំពោះតួនាទីរបស់សិស្ស | ០២ | ០៣ | ១០ | ១០ | ១៩ |
| ៨ | គ្រូយកចិត្តទុកដាក់ទៅលើតួនាទីរបស់សិស្ស | ០៦ | ១៧ | ១៩ | ០២ | ០០ |
| ៩ | គ្រូប្រើវិធីឱ្យសិស្សចងចាំខ្លឹមសារមេរៀន | ០៩ | ១៨ | ១៦ | ០១ | ០០ |
| ១០ | គ្រូជួយជំរុញឱ្យសិស្សធ្វើការស្រាវជ្រាវដោយខ្លួនឯង | ១៤ | ១៧ | ០៧ | ០៥ | ០១ |
| ១១ | គ្រូលើកទឹកចិត្តឬស្តីបន្ទោសសិស្សពីកត្តាក្រៅខ្លួន | ០៨ | ១៤ | ១១ | ០៩ | ០២ |
| ១២ | គ្រូបំផុសគំនិតសិស្សឱ្យចង់រៀនយកស្នាដៃ | ១០ | ១៥ | ១៥ | ០៣ | ០១ |
| ១៣ | គ្រូសង្កត់ធ្ងន់លើការងារក្រុមតូចឬធំ | ០២ | ០៥ | ១៨ | ១៤ | ០៥ |
| ១៤ | គ្រូសង្កត់ធ្ងន់លើសកម្មភាពសិស្សម្នាក់ៗ | ០៣ | ០៩ | ១៧ | ១០ | ០៥ |
| ១៥ | គ្រូជំរុញសិស្សឱ្យកសាងបទពិសោធន៍ថ្មីៗ | ០៧ | ១៣ | ១៤ | ០៧ | ០៣ |

| | | | | | | |
|---|---|---|---|---|---|---|
| ១៦ | គ្រូផ្ដល់បទពិសោធន៍ថ្មីតិចតួចណាស់ | ០១ | ១២ | ១៣ | ១៨ | ០០ |
| ១៧ | គ្រូសង្កត់ធ្ងន់ទៅលើការយល់ដឹងលើមុខវិជ្ជា | ០៦ | ១៣ | ២២ | ០២ | ០១ |
| ១៨ | គ្រូបញ្ជ្រាបសីលធម៌លើមុខវិជ្ជាសិស្ស | ០៤ | ១២ | ១៩ | ០៩ | ០០ |
| ១៩ | គ្រូទម្លាប់សិស្សឱ្យក្លាហានក្នុងការនិយាយ | ១៤ | ១៨ | ០៧ | ០៣ | ០២ |
| ២០ | គ្រូសរសេររូបមន្ត ខ្លឹមសារសំខាន់ៗមេរៀន | ២១ | ២០ | ០០ | ០១ | ០២ |

| | | | | | | |
|---|---|---|---|---|---|---|
| **២. សកម្មភាពសិស្ស** | | | | | | |
| ១ | សិស្សធ្វើលំហាត់តាមក្រុម ឬជាដៃគូ | ០៥ | ០២ | ១០ | ១១ | ១៦ |
| ២ | សិស្សពិភាក្សាដោះស្រាយបញ្ហាតាមក្រុម | ០៤ | ០៦ | ២៤ | ១០ | ០០ |
| ៣ | សិស្សឡើងសរសេរចម្លើយតាមក្រុមខ្លួន | ១១ | ២៣ | ០៧ | ០៣ | ០០ |
| ៤ | សិស្សស្ដាប់ កត់ត្រា ឆ្លើយ ឬថាតាមគ្រូ | ១៣ | ២៣ | ០៧ | ០១ | ០០ |
| ៥ | សិស្សពិភាក្សាជាក្រុមយកយោបល់ឯកភាព | ០៣ | ១២ | ២២ | ០៧ | ០០ |
| ៦ | សិស្សមិនបានត្រៀមខ្លឹមសារជាមុនទេ | ០០ | ០៣ | ១៩ | ២១ | ០១ |
| ៧ | សិស្សបានត្រៀមខ្លឹមសារមេរៀមសម្រាប់ឆ្លើយ | ១០ | ១៧ | ១៤ | ០៣ | ០០ |
| ៨ | សិស្សទទួលចំណេះដឹងតាមការផ្ទេរចំណេះដឹងរបស់គ្រូ | ០៤ | ១៨ | ១៩ | ០២ | ០១ |
| ៩ | សិស្សយល់ដឹងដោយធ្វើសកម្មភាពរៀនដោយខ្លួនឯង | ០១ | ១៣ | ២៤ | ០៦ | ០០ |
| ១០ | សិស្សចេះអនុវត្តបានដោយមានអ្នកជួយ (សិស្ស មិត្តភក្តិ) | ០១ | ១៥ | ២៣ | ០៥ | ០០ |
| ១១ | សិស្សជាអ្នកស្វែងយល់ ឡើងសរសេររូបមន្ត ខ្លឹមសារសំខាន់ៗ និងដោះស្រាយលំហាត់ | ០១ | ០៧ | ១៤ | ២១ | ០១ |

តាមយោបល់របស់ប្អូនៗ តើគ្រូបង្រៀនរបស់ប្អូនៗគួរកែលម្អនៅត្រង់ចំណុចណាខ្លះ ដើម្បីឱ្យប្អូនៗដែលជាសិស្សានុសិស្ស ងាយយល់ខ្លឹមសារមេរៀន? ឆាប់យល់រូបមន្ត ឆាប់ចាំខ្លឹមសារមេរៀន? អាចអនុវត្តលំហាត់បាន?

**វិទ្យាល័យ សុខ អាន ព្រៃសណ្តែក**

នៅក្នុងផ្នែកនេះ អ្នកស្រាវជ្រាវ បានចុះធ្វើការសម្ភាសន៍ និងឱ្យប្អូនៗជាសិស្សានុសិស្សនៅវិទ្យាល័យ សុខ អាន ព្រៃសណ្តែក ឆ្លើយកម្រងសំណួរ ហើយអ្នកស្រាវជ្រាវ បានកំណត់យកសិស្សចំនួន៤៩នាក់ចំពោះវិទ្យាល័យ សុខ អាន ព្រៃសណ្តែក ហើយតាមរយៈសំណួរខាងលើ ប្អូនៗជាសិស្សានុសិស្សនៅវិទ្យាល័យ សុខ អាន ព្រៃសណ្តែកបានឆ្លើយថា តាមយោបល់របស់ប្អូនៗ គ្រូបង្រៀនរបស់ប្អូនៗគួរកែលម្អនៅត្រង់ចំណុចមួយចំនួន ដើម្បីឱ្យប្អូនៗដែលជាសិស្សានុសិស្ស ងាយយល់ខ្លឹមសារមេរៀន ឆាប់យល់រូបមន្ត ឆាប់ចាំខ្លឹមសារមេរៀន អាចអនុវត្តលំហាត់បាន គឺគួរតែពន្យល់ឱ្យបានច្រើន ប្រាប់រូបមន្ត ឱ្យច្បាស់ យឺតៗ ផ្តល់រូបភាពឱ្យច្បាស់ និងផ្តល់លំហាត់ថ្មីៗ ឱ្យសិស្សអនុវត្តបានច្រើន ឧស្សាហរណ៍រំលឹកមេរៀន មានឧទាហរណ៍ច្រើន និងអនុវត្តលំហាត់ ផ្តល់ដំបូន្មានល្អៗ និងណែនាំសិស្សខ្សោយ ខិតខំសិក្សាស្រាវជ្រាវបន្ថែម គ្រូបង្រៀនមកបង្រៀនឱ្យទៀងទាត់ពេលវេលា និងទាន់ម៉ោងសិក្សា យកចិត្តទុកដាក់លើសិស្ស ហើយមិនរើសអើងលើសិស្សចំពោះគ្រប់សិស្ស(សិស្សមិនរៀនគួរជាដើម) លើកទឹកចិត្តសិស្ស និងជួយជម្រុញឱ្យសិស្សខិតខំរៀនសូត្រ។

**វិទ្យាល័យ សុខ អាន ថ្នល់បំបែក**

នៅក្នុងផ្នែកនេះ អ្នកស្រាវជ្រាវ បានចុះធ្វើការសម្ភាសន៍ និងឱ្យប្អូនៗជាសិស្សានុសិស្សនៅវិទ្យាល័យ សុខ អាន ថ្នល់បំបែក ឆ្លើយកម្រងសំណួរ ហើយអ្នកស្រាវជ្រាវ បានកំណត់យកសិស្សចំនួន៥៥នាក់ចំពោះវិទ្យាល័យ សុខ អាន ថ្នល់បំបែក ហើយតាមរយៈសំណួរខាងលើ ប្អូនៗជាសិស្សានុសិស្សនៅវិទ្យាល័យ សុខ អាន ថ្នល់បំបែកបានឆ្លើយថាតាមយោបល់របស់ប្អូនៗ គ្រូបង្រៀនរបស់ប្អូនៗគួរកែលម្អនៅត្រង់ចំណុចមួយចំនួនដើម្បីឱ្យប្អូនៗដែលជាសិស្សានុសិស្ស ងាយយល់ខ្លឹមសារមេរៀន ឆាប់យល់រូបមន្ត ឆាប់ចាំខ្លឹមសារមេរៀន អាចអនុវត្តលំហាត់បាន គឺគួរតែហៅសួរឱ្យញឹកញាប់ ឱ្យសិស្សឡើងដោះស្រាយឱ្យញឹកញាប់ ហើយដាក់សំណួរឱ្យច្រើន កុំរៀនលឿនពេក(យឺតបន្តិច) ឧស្សាហ៍រំលឹកមេរៀន និងរូបមន្ត យកចិត្តទុកដាក់ក្នុងការបង្រៀន និងសិស្សខ្សោយ ចង់ឱ្យគ្រូមានវិធីសាស្ត្របង្រៀនឱ្យច្រើន វិធីងាយយល់ដាក់ការងារពីតូចទៅធំ ឱ្យយល់រូបមន្តឱ្យបានច្រើន ពន្យល់ឱ្យច្រើន លំហាត់ច្រើន បានកែលំហាត់ច្រើន ប្រាប់

គន្លឹះចាំរូបមន្ត មានឧទាហរណ៍ច្រើន ចង់ឱ្យសិស្សបានឡើងធ្វើលំហាត់ញឹកញាប់ រំលឹកមេរៀនចាស់ៗ មុនចាប់ផ្តើមមេរៀនថ្មី និងចង់ឱ្យយកចិត្តទុកដាក់លើសិស្សស្មើរៗគ្នា។

**វិទ្យាល័យ សុខ អាន ខ្វាវ**

នៅក្នុងផ្នែកនេះ អ្នកស្រាវជ្រាវ បានចុះធ្វើការសម្ភាសន៍ និងឱ្យប្អូនៗជាសិស្សានុសិស្សនៅវិទ្យាល័យ សុខ អាន ខ្វាវ ឆ្លើយកម្រងសំណួរ ហើយអ្នកស្រាវជ្រាវ បានកំណត់យកសិស្សចំនួន៤៤នាក់ ចំពោះវិទ្យាល័យ សុខ អាន ខ្វាវ ហើយតាមរយៈសំណួរខាងលើ ប្អូនៗជាសិស្សានុសិស្សនៅវិទ្យាល័យ សុខ អាន ខ្វាវ បានឆ្លើយថាតាមយោបល់របស់ប្អូនៗ គ្រូបង្រៀនរបស់ប្អូនៗគួរកែលម្អនៅត្រង់ចំណុចមួយចំនួន ដើម្បីឱ្យប្អូនៗដែលជាសិស្សានុសិស្ស ងាយយល់ខ្លឹមសារមេរៀន ឆាប់យល់រូបមន្ត ឆាប់ចាំខ្លឹមសារមេរៀន អាចអនុវត្តលំហាត់បាន គឺគ្រូបង្រៀនគួរតែយកចិត្តទុកដាក់ក្នុងការបង្រៀន ពន្យល់ឱ្យបានច្រើន និងច្បាស់ មួយៗ និងពន្យល់ខ្លឹមសារឱ្យបានច្បាស់ ឱ្យសិស្សអានឱ្យបានច្រើន ប្រាប់រូបមន្ត មានការអនុវត្ត ហើយឱ្យឡើងធ្វើលំហាត់ឱ្យញឹកញាប់ បង្រៀនឱ្យទៀងទាត់ ស្លៀកពាក្យឱ្យបានសមរម្យ និងទាន់ពេលវេលា ឧស្សាហ៍រំលឹកមេរៀន ដាក់លំហាត់ឱ្យច្រើន បង្ហាញរូបមន្តឱ្យច្បាស់ ហើយបន្ថែមរូបភាពបើអាច។

**សំណូមពរផ្សេងៗ៖** ( សម្ភារឧបទេស ហ្វឹត ក្រដាសតាកុង ផ្ទាំងរូបភាព ស្លាយ )

**វិទ្យាល័យ សុខ អាន ព្រៃសណ្តែក**

នៅក្នុងផ្នែកនេះ អ្នកស្រាវជ្រាវ បានចុះធ្វើការសម្ភាសន៍ និងឱ្យប្អូនៗជាសិស្សានុសិស្សនៅវិទ្យាល័យ សុខ អាន ព្រៃសណ្តែក ឆ្លើយកម្រងសំណួរ ហើយអ្នកស្រាវជ្រាវ បានកំណត់យកសិស្សចំនួន៤៩នាក់ ចំពោះវិទ្យាល័យ សុខ អាន ព្រៃសណ្តែក ហើយតាមរយៈសំណួរខាងលើ ប្អូនៗជាសិស្សានុសិស្សនៅវិទ្យាល័យ សុខ អាន ព្រៃសណ្តែកបានឆ្លើយថា ប្អូនៗចង់សំណូមពរផ្តល់ហ្វឹតសរសេរ ស្លាយបញ្ចាំងរូបភាពមេរៀន ក្រដាសកាតុងសម្រាប់សរសេររូបមន្ត ជួយជួសជុលបន្ទប់ទឹកនឹងមានទឹកគ្រប់គ្រាន់ ហើយមានបន្ទប់ទឹកស្អាត បង្រៀនឱ្យទៀង អនុវត្តលំហាត់ ឫសំណួរលើក្តារខៀន មានបន្ទប់ពិសោធ និងមានសម្ភារឧបទេសឱ្យគ្រប់គ្រាន់ ផ្ទាំងរូបភាព អំបោស និង ប្រដាប់កើបសម្រាម កន្លែងចោលសម្រាមត្រឹមត្រូវ ដាំដើមឈើបន្ថែម

ជុំវិញបរិវេណសាលា រៀបចំទីសក្ការៈសម្មាសម្ពុទ្ធ និងចង់ឱ្យលោកគ្រូអ្នកគ្រូពន្យល់ឱ្យច្បាស់ និងមានឧទាហរណ៍បញ្ជាក់ឱ្យបានច្រើន។

**វិទ្យាល័យ សុខ អាន ថ្នល់បំបែក**

នៅក្នុងផ្នែកនេះ អ្នកស្រាវជ្រាវ បានចុះធ្វើការសម្ភាសន៍ និងឱ្យប្អូនៗជាសិស្សានុសិស្សនៅវិទ្យាល័យ សុខ អាន ថ្នល់បំបែក ឆ្លើយកម្រងសំណួរ ហើយអ្នកស្រាវជ្រាវ បានកំណត់យកសិស្សចំនួន៥៥នាក់ចំពោះវិទ្យាល័យ សុខ អាន ថ្នល់បំបែក ហើយតាមរយៈសំណួរខាងលើ ប្អូនៗជាសិស្សានុសិស្សនៅវិទ្យាល័យ សុខ អាន ថ្នល់បំបែកបានសំណូមពរ ចង់ឱ្យមានហ្វឹត ក្រដាសកាតុង គ្រប់គ្រាន់សម្រាប់សរសេររូបមន្ត ចង់ឱ្យមានសម្ភារឧបទេសគ្រប់គ្រាន់ ចង់បានស្លាយ ផ្ទាំងរូបភាពប្រវត្តិសាស្ត្រឱ្យបានច្រើន ចង់ឱ្យមានឧបករណ៍ស្រាវជ្រាវរៀនសូត្របន្ថែមទៀត ហើយពន្យល់ឱ្យច្បាស់ៗ យឺតៗ និងយកចិត្តទុកដាក់។

**វិទ្យាល័យ សុខ អាន ខ្វាវ**

នៅក្នុងផ្នែកនេះ អ្នកស្រាវជ្រាវ បានចុះធ្វើការសម្ភាសន៍ និងឱ្យប្អូនៗជាសិស្សានុសិស្សនៅវិទ្យាល័យ សុខ អាន ខ្វាវ ឆ្លើយកម្រងសំណួរ ហើយអ្នកស្រាវជ្រាវ បានកំណត់យកសិស្សចំនួន៤៤នាក់ ចំពោះវិទ្យាល័យ សុខ អាន ខ្វាវ ហើយតាមរយៈសំណួរខាងលើ ប្អូនៗជាសិស្សានុសិស្សនៅវិទ្យាល័យ សុខ អាន ខ្វាវបានសំណូមពរចង់ឱ្យមានកង្ហារតាមថ្នាក់នីមួយៗ ហ្វឹត ស្លាយ ចង់មានបន្ទប់ពិសោធន៍ បន្ទប់កុំព្យូទ័រ បណ្ណាល័យ សម្ភារៈបន្ថែម ដូចជា ក្រដាសកាតុង ផ្ទាំងរូបភាពឱ្យបានច្រើន ចង់ឱ្យយកចិត្តទុកដាក់លើសិស្ស ពង្រឹងផ្នែកសិល្បៈ បន្ទប់សិក្សាឱ្យបានច្រើន និងអគារសិក្សាជាដើម។

### ៤.៦.៣ ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលនៃការបង្រៀនភាសាអង់គ្លេស

### ក. ស្ថានភាពនៃការអនុវត្ត

M តាងឱ្យតម្លៃមធ្យមនៃកម្រិតនៃការវាយតម្លៃទៅលើការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងវិទ្យាល័យនានា ដែលតម្លៃ M ស្ថិតនៅចន្លោះពី 1 ដល់ 5 ដែលបានបង្ហាញដូចខាងក្រោម ៖

- បើ $1 \leq M \leq 2.50$ មានន័យថាការអនុវត្តមានកម្រិតខ្សោយ
- បើ $2.51 \leq M \leq 3.50$ មានន័យថាការអនុវត្តមានកម្រិតមធ្យម

- បើ 3.51 ≤ M ≤ 4.50 មានន័យថាការអនុវត្តមានកម្រិតល្អបង្គួរ

- បើ 4.51 ≤ M ≤ 5.00 មានន័យថាការអនុវត្តមានកម្រិតល្អ

- *SD* តាងឱ្យគម្លាតស្តង់ដារ

- n តាងឱ្យទំហំនៃគំរូសំណាកក្នុងការសិក្សា

តារាងលទ្ធផលវិភាគពីការវាយតម្លៃការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនភាសាអង់គ្លេស

| ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនអង់គ្លេសថ្នាក់ទី១១ របស់លោកគ្រូ-អ្នកគ្រូនៅខេត្តតាកែវ | n = 156 | | កម្រិត | លំដាប់ |
|---|---|---|---|---|
| | M | SD | | |
| ១. ការត្រៀមលក្ខណៈមុនពេលបង្រៀន | 3.95 | 0.186 | ល្អបង្គួរ | ១ |
| ២. លក្ខណៈទូទៅនៃការបង្រៀន | 3.86 | 0.385 | ល្អបង្គួរ | ២ |
| ៣. វង្វាយតម្លៃ | 3.82 | 0.390 | ល្អបង្គួរ | ៣ |
| ៤. ដំណើរការបង្រៀន (សកម្មភាពគ្រូ សកម្មភាពសិស្ស) | 3.85 | 0.387 | ល្អបង្គួរ | ៤ |
| សរុប ការអនុវត្តសិស្សមជ្ឈមណ្ឌល | 3.87 | 1.348 | ល្អបង្គួរ | |

នៅក្នុងផ្នែកការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ(ថ្នាក់ទី១១)នេះ អ្នកស្រាវជ្រាវបានចុះប្រមូលទិន្នន័យនៅតាមសាលាទាំងបី គឺវិទ្យាល័យសុខ អាន ព្រៃស្លោក វិទ្យាល័យសុខ អានថ្នល់បំបែក និងវិទ្យាល័យសុខ អានខ្វាវ ហើយតាមរយៈការប្រមូលទិន្នន័យរបស់អ្នកស្រាវជ្រាវឃើញថាៈ គ្រូបង្រៀនភាសាអង់គ្លេសថ្នាក់ទី១១ បានអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបានល្អ ហើយលោកគ្រូ-អ្នកគ្រូបានឆ្លើយតាមកម្រងសំណួរថាពួកគាត់បានត្រៀមសម្ភារឧបទ្ទេសគ្រប់គ្រាន់ និងកិច្ចតែងការបង្រៀនគ្រប់ៗគ្នា និងនៅមានចន្លោះខ្វះខាតបន្តិចបន្តួចដែលត្រូវបំពេញបន្ថែម។

## ខ. ភាពផ្សេងគ្នានៃការអនុវត្តនៅទីប្រជុំជន និង ជនបទ

| ល.រ | ឈ្មោះសាលា | តំបន់ | | ភាគរយ ទីប្រជុំជន | ភាគរយ ជនបទ |
|---|---|---|---|---|---|
| | | ទីប្រជុំជន | ជនបទ | | |
| ១ | វិ.ស.អ ព្រៃសណ្តែក | ✓ | | ៧៧.៣៧% | |
| ២ | វិ.ស.អ ថ្នល់បំបែក | ✓ | | ៧៤.៣៦% | |
| ៣ | វិ.ស.អ ខ្វាវ | | ✓ | | ៥៦.២៧% |
| សរុប | | | | ៧៥.៨៧% | ៥៦.២៧% |

តាមរយៈតារាងខាងលើ អ្នកស្រាវជ្រាវអាចបង្ហាញបានថាៈ វិទ្យាល័យ សុខ អាន ព្រៃសណ្តែកអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបាន៧៧.៣៧%។ តាមរយៈតារាងខាងលើ អ្នកស្រាវជ្រាវអាចបង្ហាញបានថា វិទ្យាល័យ សុខ អាន ព្រៃសណ្តែកអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបានល្អ។

តាមរយៈតារាងខាងលើ អ្នកស្រាវជ្រាវអាចបង្ហាញបានថា វិទ្យាល័យ សុខ អាន ថ្នល់បំបែក អនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបាន៧៤.៣៦%។ តាមរយៈតារាងខាងលើ អ្នកស្រាវជ្រាវអាចបង្ហាញបានថា វិទ្យាល័យ សុខ អាន ថ្នល់បំបែក អនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបានល្អបង្គួរ។

តាមរយៈតារាងខាងលើ អ្នកស្រាវជ្រាវអាចបង្ហាញបានថា វិទ្យាល័យ សុខ អាន ខ្វាវ អនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបាន៥៦.២៧%។ តាមរយៈតារាងខាងលើ អ្នកស្រាវជ្រាវអាចបង្ហាញបានថា វិទ្យាល័យ សុខ អាន ខ្វាវ អនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបានមធ្យម។

សរុបមក តាមរយៈតារាងរបស់វិទ្យាល័យទាំងបីខាងលើ ឃើញថាការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ(ថ្នាក់ទី១១) គឺនៅតាមទីប្រជុំជនបានអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនភាសាអង់គ្លេសបាន (៧៥.៨៧%) ល្អជាងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនភាសាអង់គ្លេសនៅតាមទីជនបទ (៥៦.២៧%)។

## ខ. ភាពផ្សេងគ្នានៃការអនុវត្ត

### ក. វិទ្យាល័យ សុខ អាន ព្រៃសណ្ដែក



ក្រាបទី ២៖ **វិទ្យាល័យ សុខ អាន ព្រៃសណ្ដែក**

តាមរយៈក្រាបខាងលើបង្ហាញថា អប្បបរមា: ១.០០ អតិបរមា: ៣.៧៥ មធ្យម: ២.៦២ និងគម្លាតស្តង់ដា ០.៥៦។ ដោយអ្នកស្រាវជ្រាវសង្កេតឃើញថាគម្លាតស្តង់ដាមានកម្រិតទាបទើបអ្នកស្រាវជ្រាវសន្និដ្ឋានថាលទ្ធផលនេះ គឺអនុវត្តបានត្រឹមត្រូវ និងល្អ។

### ខ. វិទ្យាល័យ សុខ អាន ថ្នល់បំបែក



ក្រាបទី ៣៖ **វិទ្យាល័យ សុខ អាន ថ្នល់បំបែក**

តាមរយៈក្រាបខាងលើបង្ហាញថា អប្បបរមា: ២.០០ អតិបរមា: ៤.៥០ មធ្យម: ៣.២២ និងគម្លាតស្តង់ដា ០.៤៥។ ដោយអ្នកស្រាវជ្រាវសង្កេតឃើញថាគម្លាតស្តង់ដាមានកម្រិតទាបទើបអ្នកស្រាវជ្រាវសន្និ ដ្ឋានថាលទ្ធផលនេះ គឺអនុវត្តបានត្រឹមត្រូវ និងល្អ។

**<u>គ.វិទ្យាល័យ សុខ អាន ខ្វារ</u>**




តាមរយៈក្រាបខាងលើបង្ហាញថា អប្បបរមា: ១.៥ អតិបរមា: ៣.៦៧ មធ្យម: ២.៣៤ និងគម្លាតស្តង់ដា ០.៤៦។ ដោយអ្នកស្រាវជ្រាវសង្កេតឃើញថាគម្លាតស្តង់ដាមានកម្រិតទាបទើបអ្នកស្រាវជ្រាវសន្និដ្ឋានថាលទ្ធផលនេះ គឺអនុវត្តបានត្រឹមត្រូវ និងល្អ។

# ជំពូកទី៥
# សេចក្ដីសន្និដ្ឋាន
# និងសំណូមពរ

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយខាងលើ យើងអាចទាញសេចក្តីសន្និដ្ឋានបានថាការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១១) របស់លោកគ្រូអ្នកគ្រូក្នុងខេត្តតាកែវ អនុវត្តបានល្អ គឺលោកគ្រូ អ្នកគ្រូ សិស្ស គណៈគ្រប់គ្រងនៅក្នុងខេត្តតាកែវបានធ្វើការវាយតម្លៃដូចៗគ្នាថា ពួកគាត់បានចំណាយពេលច្រើនក្នុងការត្រៀមលក្ខណៈមុនពេលបង្រៀនក៏ដូចជាលក្ខណៈទូទៅនៃការបង្រៀន និងការវាយតម្លៃ។មូលហេតុដែលនាំឱ្យការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនភាសាអង់គ្លេស នៅមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១១) របស់លោកគ្រូអ្នកគ្រូក្នុងខេត្តតាកែវ អនុវត្តបានល្អ គឺមុនពេលបង្រៀនលោកគ្រូ-អ្នកគ្រូបានត្រៀមសម្ភារឧបទេសមួយចំនួន ដើម្បីឱ្យសិស្សងាយយល់មេរៀន ងាយស្រួលក្នុងការសង្ខេមខ្លឹមសារមេរៀន រូបមន្ត ពាក្យស្លោកចំណុចសំខាន់ផ្សេងៗទៀតនៃមេរៀន និងមុនពេលបង្រៀនលោកគ្រូអ្នកគ្រូបានប្រាប់ពីវត្ថុបំណងច្បាស់លាស់ដើម្បីឱ្យសិស្សយល់ និងដឹងកាន់តែច្បាស់។ ហើយពេលបង្រៀនផ្ទាល់លោកគ្រូ អ្នកគ្រូបានដាក់ជាបញ្ហា សំណួរ និងលំហាត់ឱ្យសិស្សដោះស្រាយ និងបានបែងចែកសិស្សដើម្បីឱ្យពិភាក្សាជាក្រុមៗ គឺធ្វើយ៉ាងណាឱ្យសិស្សងាយយល់បានធ្វើសកម្មភាពច្រើន បានបញ្ចេញមតិយោបល់ សិស្សចេះដោះស្រាយបញ្ហាដោយខ្លួនឯង និងជាក្រុម ចេះជួយគ្នាដោយមានការពន្យល់ និងពិនិត្យពីគ្រូខ្លះៗនូវចំណុចណាដែលសិស្សមិនទាន់យល់ច្បាស់ ដើម្បីឱ្យសិស្សងាយយល់ និងឆាប់ចាប់បាននូវខ្លឹមសារមេរៀន។ ហើយអំឡុងពេលបង្រៀននិងរៀនផ្ទាល់នេះដែរលោកគ្រូអ្នកគ្រូបានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះសិស្ស គឺបានដាក់ចោទជាបញ្ហា សំណួរ និងលំហាត់ ដើម្បីឱ្យសិស្សចេះដោះស្រាយ តាមរយៈការពន្យល់ ណែនាំ ការធ្វើអធិប្បាយ ធ្វើគម្រូឱ្យសិស្សមើល ពន្យល់ទ្រឹស្តី រូបមន្ត ពាក្យស្លោក ខ្លឹមសារមេរៀន ដោយបំផុសគំនិត បញ្ជ្រាបការយល់ដឹងលើមុខវិជ្ជា យល់ដឹងពីគន្លឹះសំខាន់ៗនៃមេរៀន ឱ្យសិស្សក្លាហាន ហ៊ាននិយាយ ហ៊ានសួរ ហ៊ានបកស្រាយ ហើយបានឱ្យសិស្សធ្វើការងារជាក្រុម ជាដៃគូរ ឡើងសរសេរចម្លើយ ឱ្យសិស្សកត់ត្រា ស្តាប់ ឆ្លើយឬថាតាមគ្រូ ឱ្យសិស្សយល់ដឹងចេះធ្វើ

សកម្មភាពរៀនដោយខ្លួនឯង ធ្វើឱ្យយល់ដឹងពីតួនាទី និងបានបញ្ជ្រាបសីលធម៌ ក្នុងការរស់នៅឱ្យបានយល់កាន់តែច្បាស់។ ប៉ុន្តែក្នុងសកម្មភាពបង្រៀនផ្ទាល់ឃើញថាក៏នៅមានចំណុចខ្វះខាតបន្តិចបន្តួចគឺសិស្សមួយចំនួនសមត្ថភាពនៅមានកម្រិត កង្វះខាតសម្ភារឧបទេស នៅក្នុងដំណើរការបង្រៀន និងរៀន និងគ្រប់គ្រងពេលវេលាមិនបានសមស្រប។ សិស្សមួយចំនួនមានចំណេះដឹងតិច សមត្ថភាពនៅខ្សោយមកពីកត្តាខ្លួនឯង គ្រួសារ និងសង្គម ហើយពួកគេមិនសូវយកចិត្តទុកដាក់លើការសិក្សា មិនយល់ពីសារៈប្រយោជន៍នៃការសិក្សា ចំណែកឯពេលវេលាក្នុងការបង្រៀនតិច(នៅសល់តិច) ការប្រើប្រាស់ក្នុងដំណាក់កាលផ្សេងៗទៀតច្រើន គ្រូបង្រៀនអនុវត្តសកម្មភាពច្រើនជាងសិស្ស ពិសេសគឺមកពីកង្វះខាតសម្ភារឧបទេស និងថវិកាមួយចំនួនធ្លាក់មិនទាន់ពេលវេលា។ លើសពីនេះការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១១) ក្នុងខេត្តតាកែវ យើងសង្កេតឃើញថាលោកគ្រូ-អ្នកគ្រូនៅតាមទីប្រជុំជនបានអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនភាសាអង់គ្លេសបានល្អជាងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនភាសាអង់គ្លេសនៅតាមទីជនបទ។

សរុបមកលោកគ្រូអ្នកគ្រូ ក្នុងខេត្តតាកែវ អនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១១) គឺអនុវត្តបានល្អ (៦៦.០៧%)។

## ៥.២ សំណូមពរ

ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល ក្នុងការបង្រៀនពិតជាមានសារៈសំខាន់ណាស់ សម្រាប់គ្រូ និងសិស្សក្នុងការបង្រៀន និងរៀនហើយក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ នៅកម្ពុជាក្រសួងអប់រំ យុវជន និងកីឡា បានខិតខំយ៉ាងខ្លាំងក្នុងការអភិវឌ្ឍធនធានមនុស្ស ដើម្បីចូលរួមចំណែកដល់ការអភិវឌ្ឍប្រទេសជាតិក៏ដូចជាសកលលោកផងដែរដោយបានដាក់ចេញនូវគោលការណ៍គោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាច្រើន។ក្រសួងអប់រំយុវជន និងកីឡាបានផ្លាស់ប្តូរប្រព័ន្ធអប់រំពីការអប់រំដោយការបង្រៀនដោយគ្រូមកជាការបង្រៀនដោយសិស្សជាអ្នកបញ្ចេញគំនិត យោបល់ និងស្វ័យសិក្សាដោយខ្លួនឯង ជាងផ្អែកលើគ្រូបង្រៀនដោយដាក់ចេញជាគោលវិធីសិក្សាតាមបែបសិស្សជ្ឈមណ្ឌល។ គ្រូគ្រាន់តែជាអ្នកដឹកនាំត្រួតពិនិត្យតាមដាន និងវាយតម្លៃ ណែនាំ និងត្រួសត្រាយផ្លូវឲ្យសិស្សប៉ុណ្ណោះ ដើម្បីឲ្យសិស្សចេះសិក្សា

ស្រាវជ្រាវ ស្វែងយល់ទាំងចំណេះដឹង ចំណេះធ្វើ ព្រមទាំងបទពិសោធន៍ដែលប្រកបដោយ ភាពថ្លៃថ្នូរ វិជ្ជាជីវៈ សីលធម៌ គុណធម៌ និងវិន័យ។ ក៏ប៉ុន្តែការអប់រំសិស្សតាមវិធីសិស្សមជ្ឈមណ្ឌលនេះត្រូវប្រឈមបញ្ហាមួយចំនួនដូចជា ការកង្វះខាតសម្ភារ និងជានជានដែលធ្វើឲ្យការអនុវត្តមិនទាន់មានប្រសិទ្ធភាពខ្ពស់។ យោងតាមលទ្ធផល និងការសន្និដ្ឋាននៃការសិក្សាស្រាវជ្រាវនេះ ដើម្បីឲ្យការអនុវត្តគោលវិធីនេះមានដំណើរការល្អ និងទទួលបានប្រសិទ្ធភាពក៏មានអនុសាសន៍ចំនួនៈ

**១. ក្រសួងអប់រំ យុវជន និងកីឡា**

- ជួយសម្រួលដោយផ្តល់សម្ភារឧបទេសដល់គ្រូបម្រើឲ្យការបង្រៀន និងការរៀនរបស់សិស្សព្រោះថាបើខ្វះខាតសម្ភារនោះដំណើរការនៃការបង្រៀន ក៏មិនអាចប្រព្រឹត្តទៅបានល្អដែរ។
- បណ្តុះបណ្តាលទាំងគ្រូ និងសិស្សបង្គោលដើម្បីអាចជាជំនួយក្នុងការជួយបង្រៀនដល់សិស្សក្នុងថ្នាក់ និងសាលារៀនទាំងមូល ព្រោះថាសិស្សបង្គោលអាចដឹកនាំសិស្សដទៃទៀតធ្វើស្វ័យសិក្សា និងការស្រាវជ្រាវដើម្បីបង្កើនចំណេះដឹងបាន។
- ផ្សព្វផ្សាយពីសារៈសំខាន់ នៃការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសឱ្យបានទូលំទូលាយ។
- បើកវគ្គបំប៉នស្តីពីវិធីសាស្ត្របង្រៀនតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌលដោយមានការចូលរួមឲ្យបានច្រើនពីគ្រូបង្រៀនភាសាអង់គ្លេស ។

**២. នាយកសាលា**

- ជួយសម្របសម្រួលដល់ការរៀបចំថ្នាក់រៀនឲ្យបានសមស្រប ដើម្បីជួយបង្កលក្ខណៈងាយស្រួលដល់ការបង្រៀន និងការរៀនរបស់សិស្ស និងការផ្តល់កន្លែងសមរម្យសម្រាប់សិស្សអាចធ្វើស្វ័យសិក្សាជាក្រុម និងជាបុគ្គលបាន
- ជួយជំរុញនិងការលើកទឹកចិត្តសិស្សឲ្យខិតខំប្រឹងប្រែងរៀនសូត្រស្រាវជ្រាវ និងចេះធ្វើការងារជាក្រុម
- ត្រូវធ្វើអធិការកិច្ចលើគ្រូបង្រៀនឲ្យបានច្រើន
- ធ្វើស្វ័យវាយតម្លៃនិងកែលម្អទៅលើគ្រូបង្រៀនជាប្រព័ន្ធ

- ចូលរួមក្នុងការប្រជុំបច្ចេកទេសជាមួយប្រធានក្រុមបច្ចេកទេសភាសាអង់គ្លេសដើម្បីពិនិត្យឡើងវិញ និងកែលម្អវិធីសាស្ត្របង្រៀន។

- លើកទឹកចិត្តដល់គ្រូបង្រៀនដែលមានស្នាដៃធ្វើការងារល្អ។

**៣. គ្រូបង្រៀន**

- រាល់ការអនុវត្តគួរចេះលៃលកឲ្យសមស្របតាមតារាងផែនការពេលវេលាដើម្បីជៀសវាងការអនុវត្តមិនបានតាមផែនការ

- ធ្វើការវាយតម្លៃលើការសិក្សា និងផ្តល់មតិកែតម្រូវរាល់កិច្ចការដែលបានវាយតម្លៃ ព្រោះថាការវាយតម្លៃ និងមតិកែតម្រូវនេះ អាចជាផ្លូវកែតម្រូវសិស្សស្វែងយល់ពីកំហុសរបស់ខ្លួន និងអភិវឌ្ឍខ្លួនឲ្យរឹងមាំ។

**៤. ចំពោះការស្រាវជ្រាវបន្ត**

ដោយការស្រាវជ្រាវនេះបានសិក្សាផ្តោតតែទៅលើទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រង គ្រូបង្រៀន និងសិស្សលទ្ធផលស្រាវជ្រាវអាចបង្ហាញបានត្រឹមលក្ខណៈទូទៅ ពុំបានបង្ហាញពីប្រសិទ្ធភាពនៃការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលទេ។ គួរតែពង្រីកវិសាលភាពនៃការស្រាវជ្រាវឱ្យកាន់តែធំ និងបន្ថែមនូវភាគសំណាកដើម្បីធានាបាននូវ ព័ត៌មានជាក់លាក់ជាងនេះ។ ដូច្នេះអ្នកសិក្សាស្រាវជ្រាវក្រោយៗទៀតអាចពិនិត្យមើលថា តើការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលមានឥទ្ធិពលយ៉ាងដូចម្តេចលើលទ្ធផលសិក្សារបស់សិស្ស?

# ឯកសារយោង

# ឯកសារយោង

- ក្រសួងអប់រំ យុវជន និងកីឡា (ខែតុលា ២០១២): គោលនយោបាយធនធានមនុស្សក្នុងវិស័យអប់រំ។

- ក្រសួងអប់រំ យុវជន និងកីឡា (ខែមីនា ២០១៤): ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨។

- ក្រសួងអប់រំ យុវជន និងកីឡា (២០១៥): វិស័យអប់រំឆ្នាំ២០៣០: សេចក្តីប្រកាសទីក្រុងIncheon និងក្របខណ្ឌសម្រាប់សកម្មភាព ឆ្ពោះទៅរកការអប់រំមានគុណភាព បរិយាប័ន្ន សមធម៌ និងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

- ក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋានរដ្ឋបាល (២០១៥): វគ្គបំប៉នស្តីពី" ការគ្រប់គ្រងរដ្ឋបាលអប់រំ"

- ក្រសួងអប់រំ យុវជន និងកីឡា (ខែមករា ឆ្នាំ ២០១៦): ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស។

- ក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ (២០១៧): គរុកោសល្យ

- ក្រសួងអប់រំ យុវជន និងកីឡា (ខែមីនា ២០១៨): សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា២០១៦-២០១៧ និងទិសដៅឆ្នាំសិក្សា២០១៧-២០១៨

- លោក អ៊ឹម កុច (ភ្នំពេញ១៩៩៩): ទ្រឹស្តីរបស់ចិត្តវិទ្យាមនុស្សនិយម និងគោលវិធីសិស្សមជ្ឈមណ្ឌល។

- លោក មាយ សារី (២០០៤): ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលរបស់គ្រូនៅសាលាមធ្យមសិក្សាបឋមភូមិ (រាជបណ្ឌិតសភាកម្ពុជា)។

- បណ្ឌិត ចាន់ រដ្ឋសុផា (ខែធ្នូ ២០០៤): គរុកោសល្យ

- នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ (២០១៧): សៀវភៅគរុកោសល្យឆ្នាំ ២០១៧

- បណ្ឌិត ហង់ ជួនណារ៉ុន (២០១៦): កំណែទម្រង់វិស័យអប់រំនៅកម្ពុជា" មាគ៌ាឆ្ពោះទៅរកសង្គមពុទ្ធិ និងវិបុលភាព"

- បណ្ឌិត ចៅ លិន (២០១១): វិធីសាស្ត្របង្រៀនដើម្បីលើកកម្ពស់គុណភាពអប់រំ

- ឡោ ធវណ្ណា (២០១៧): សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា២០១៥-២០១៦ គម្រោងសាលារៀនជំនាន់ថ្មី ថ្ងៃទី ២១ ខែ មីនា ឆ្នាំ២០១៧

- ជិន ចាន់វន្នី ៖ ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលរបស់គ្រូវិទ្យាល័យ ករណីសិក្សាខេត្តកំពង់ឆ្នាំង និក្ខេបបទថ្នាក់អនុបណ្ឌិតជំនាន់ទី៤នៃ វិទ្យាស្ថានជាតិអប់រំ, ២០១៧

-បណ្ឌិត ង៉ាន់ ស៊ុនដេត (ខែមករា ឆ្នាំ២០១៨) ៖ វិធីសាស្ត្របង្រៀននៅថ្នាក់ឧត្តមសិក្សា ករណីសិក្សាលើការបង្រៀនរបស់សាស្ត្រាចារ្យនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

- ហឿល វដ្ឋា ៖ ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនគណិតវិទ្យានៅមធ្យមសិក្សាទុតិយភូមិ ករណីសិក្សាខេត្តបន្ទាយមានជ័យ និក្ខេបបទថ្នាក់អនុបណ្ឌិតជំនាន់ទី៥នៃ វិទ្យាស្ថានជាតិអប់រំ, ២០១៨

- Chiphiko , E., & Shawa, L. B. ( 2014 ) . Implementing Learner-Centred Approaches to Instruction in Primary School in Malawi , Mediterranean Journal of Social Sciences, 5(23), 967.

- Urwick, J and Lunaidu, S.U, (1991). The Effects of School physical facilities on the processes of Education: a qualitative study of Nigerian primary schools. International Journal of Education Development11 (1)

- Thiyaku, Dr. K.2011. Methods of Teaching Mathematics. Central University of Tamilnadu, Thiruvarur,5 20.

- Student-Centred Learning'. In: Instructional Science, 32:3, pp. 253-268

- Maclellan, E. and Soden, R. (2007) 'The Significance of Knowledge in Learning: A Psychologically Informed Analysis of Higher Education Students' Perceptions'. In: International Journal for the Scholarship of Teaching & Learning, 1:1, pp. 1-18

- Machemer, P.L. and Crawford, P. (2007) 'Student Perceptions of Active Learning in a Large Cross-Disciplinary Classroom'. In: Active Learning in Higher Education, 8:1, pp.9-30

- Stoffle, C.J. and Cuillier, C. (2010) 'Student-Centred Service and Support: A Case Study of Arizona Libraries Administration, 50, pp.117-134

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
វិទ្យាស្ថានជាតិអប់រំ
លេខ.......✓.......វជអ

## បណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧
## កាលបរិច្ឆេទទទួលនិក្ខេបបទស្រាវជ្រាវ

| ជំពូក | ចំណងជើង | កាលបរិច្ឆេទ | ថ្ងៃកំណត់ |
|---|---|---|---|
| ១ | សេចក្ដីផ្ដើម | ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២០ | ថ្ងៃអាទិត្យ |
| ២ | រំលឹកទ្រឹស្ដី | ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២០ | ថ្ងៃអាទិត្យ |
| ៣ | វិធីសាស្ត្រស្រាវជ្រាវ | ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២០ | ថ្ងៃអាទិត្យ |
| ៤ | វិភាគស៊ីជម្រៅលើលទ្ធផលរបកគំហើញ និងការ ពិភាក្សា | ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២០ | ថ្ងៃអាទិត្យ |
| ៥ | សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍ | ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២០ | ថ្ងៃអាទិត្យ |

កំណត់សម្គាល់:

- ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២០ ទទួលនិក្ខេបបទ នៅគណៈកម្មការប្រតិបត្តិនៃការបណ្ដុះបណ្ដាល ថ្នាក់ក្រោយឧត្ដម នៅវិទ្យាស្ថានជាតិអប់រំ។
- ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ **បទបង្ហាញសាកល្បង**ការពារការសរសេរនិក្ខេបបទ។
- ថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ ពិធីការពារការនិក្ខេបបទរៀបចំដោយ គណៈកម្មការប្រតិបត្តិនៃការបណ្ដុះបណ្ដាលថ្នាក់ក្រោយឧត្ដមនៅវិទ្យាស្ថានជាតិអប់រំ។

រាល់ចម្ងល់ពីការសរសេរនិក្ខេបបទស្រាវជ្រាវសូមទាក់ទងគណៈកម្មការប្រតិបត្តិនៃការបណ្ដុះបណ្ដាលថ្នាក់ក្រោយឧត្ដមសម្រាប់កម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ផ្នែក គ្រប់គ្រងអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា។ លោក បណ្ឌិត នូវ រ៉ា នាយករង វិទ្យាស្ថានជាតិអប់រំ និងលោក ចាប រតនា អនុប្រធានដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការនៃវិទ្យាស្ថានជាតិអប់រំ ។

ថ្ងៃ សុក្រ ០៤ [illegible] ខែ [illegible] ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ [illegible] ឆ្នាំ២០២០
**នាយកវិទ្យាស្ថានជាតិអប់រំ**

**បណ្ឌិត.សៀង សុវណ្ណា**

## ឧបសម្ព័ន្ធទី ២៖ លិខិតអនុញ្ញាតរបស់វិទ្យាស្ថានជាតិអប់រំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ : ០៩៥ វជអ.

**លិខិតបង្គាប់ការ**

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០

បុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំ ដូចមានរាយនាមខាងក្រោមត្រូវបានចាត់តាំងជាគ្រូដឹកនាំបង្គោល និងគ្រូដឹកនាំរងរបស់និស្សិត **ឌិន ដួង** ក្នុងការសរសេរនិក្ខេបបទបញ្ចប់វគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៅវិទ្យាស្ថានជាតិអប់រំ៖

១-គ្រូដឹកនាំបង្គោល

លោកបណ្ឌិត នួវ វ៉ា

២-គ្រូដឹកនាំរង

លោក ចាប រតនា

ឯកឧត្តម និងលោកដូចមានរាយនាមខាងលើត្រូវអនុវត្តភារកិច្ចតាមការចាត់តាំង ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ៨រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិនា ឆ្នាំ២០២០
**ជ.នាយកវិទ្យាស្ថានជាតិអប់រំ**
**នាយករង**

បណ្ឌិត.នួច_ទីរ៉ា

**កន្លែងទទួល៖**
- -ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ
- -សាមីខ្លួន "ដើម្បីអនុវត្ត"
- -កាលប្បវត្តិ
- -ឯកសារវិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តមភ្នំពេញ កម្ពុជា ទូរស័ព្ទ៖ (៨៥៥-២៣) ២១៥/៥៨៤ គេហទំព័រ៖ www.nie.edu.kh

## ឧបសម្ព័ន្ធទី៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរអប់រំយុវជន និងកីឡាខេត្តតាកែវ
ចូល លេខ 365 ម៉ោង
ថ្ងៃទី 17 ខែ 07 ឆ្នាំ 2020
បញ្ជូនមក

វិទ្យាស្ថានជាតិអប់រំ
លេខៈ ១៦៦ វជអ. ឥក

គោរពជូន

លោកប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្តតាកែវ

20/7/2020

**កម្មវត្ថុៈ** សំណើសុំអនុញ្ញាតឱ្យលោក **ឌិន ដួង** ចុះកម្មសិក្សាស្រាវជ្រាវ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៅវិទ្យាល័យគោលដៅនានាក្នុងស្រុកទ្រាំង ខេត្តតាកែវ។

**យោងៈ** ផែនការបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកប្រធានមេត្តាជ្រាបថា លោក **ឌិន ដួង** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំពុងទទួលការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ មានគម្រោងចុះស្រាវជ្រាវលើប្រធានបទស្តីពី«**ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ(ថ្នាក់ទី១១)ក្នុងខេត្តតាកែវ**» ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សា។ លោក **ឌិន ដួង** នឹងសម្ភាសន៍តាមប្រព័ន្ធ ONLINE ពីគណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ដែលកំពុងសិក្សានៅសាលា វិទ្យាល័យគោលដៅ ក្នុងខេត្តតាកែវ ដែលប្រព្រឹត្តទៅចាប់**ពីថ្ងៃទី១៦ ខែកក្កដា ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០**។

អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាជួយសម្រួលដោយក្តីអនុគ្រោះ។

សូមលោកប្រធានទទួលនូវការគោរពរាប់អានដ៏ស្មោះពីខ្ញុំ

ថ្ងៃពុធ ១០រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០
**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**ឧបសម្ព័ន្ធទី៤**

## កម្រងសំណួរ

### សម្រាប់ គណៈគ្រប់គ្រងសាលា សម្ភាសនាយក/នាយិកា/នាយករង /នាយិការង

**សូមគោរពជូនៈ លោកនាយក/នាយិកា/នាយករងសាលា**

ខ្ញុំបាទឈ្មោះ **ឌិន ដួង** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំ នឹងធ្វើការសិក្សាស្រាវជ្រាវបញ្ចប់ឆ្នាំសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ក្រោមប្រធានបទ **«ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន ភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១១) ក្នុងខេត្តតាកែវ»** ខ្ញុំបាទសូមគោរពអញ្ជើញលោកនាយក/នាយិកាសាលា ដើម្បីចូលរួមក្នុងការផ្តល់ចម្លើយលើកម្រងសំណួរការស្រាវជ្រាវខាងក្រោម ក្នុងគោលបំណងសិក្សាស្វែងយល់ពីស្ថានភាពក្នុងការជួយជម្រុញការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនអង់គ្លេសរបស់លោកគ្រូ-អ្នកគ្រូនៅកម្រិតមធ្យមសិក្សាទុតិយភូមិ (បង្រៀនថ្នាក់ទី១១) ក្នុងខេត្តតាកែវ។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងខ្ពង់ខ្ពស់ចំពោះកិច្ចសហការ និងការចំណាយពេលវេលាដ៏មានតម្លៃរបស់លោកនាយក/នាយិកា/នាយករងសាលាក្នុងការអនុញ្ញាតឱ្យខ្ញុំបាទបានសម្ភាសដោយផ្ទាល់ដើម្បីធ្វើការប្រមូលយកព័ត៌មាន។

**សេចក្តីណែនាំ**

១. កម្រងសំណួរការស្រាវជ្រាវចែកចេញជា ២ផ្នែក ដូចខាងក្រោមៈ

ផ្នែកទី១: ព័ត៌មានអំពីស្ថានភាពទូទៅរបស់លោកនាយក/នាយិកាសាលា

ផ្នែកទី២: កត្តាជួយជំរុញការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនអង់គ្លេសរបស់លោកគ្រូអ្នកគ្រូនៅតាមវិទ្យាល័យ

២. សូមអានសេចក្តីណែនាំពីការឆ្លើយកម្រងសំណួរគ្រប់ផ្នែកនីមួយៗ ដោយការយកចិត្តទុកដាក់។ សូមមេត្តាជួយផ្តល់ ចម្លើយតាមរយៈការសម្ភាសដោយផ្ទាល់ឱ្យបានគ្រប់សំណួរតាមការពិតជាក់ស្តែង។

ដូច្នេះ សូមលោកនាយក/នាយិកា/នាយករងសាលាផ្តល់ព័ត៌មានពិតដល់ខ្ញុំបាទដើម្បីឱ្យការស្រាវជ្រាវនេះអាចទទួលយកជាការបាន។ ព័ត៌មានទាំងអស់នេះ មានសារៈសំខាន់ណាស់សម្រាប់ការសិក្សាស្រាវជ្រាវនៅពេលបច្ចុប្បន្ន និងពេលអនាគត។ ខ្ញុំបាទសូមធានាអះអាងថានឹងរក្សាការសម្ងាត់ចំពោះរាល់ព័ត៌មានដែលបានផ្តល់ឱ្យហើយព័ត៌មានទាំងអស់នេះត្រូវបានយកទៅប្រើប្រាស់ក្នុងគោលបំណងនៃការស្រាវជ្រាវតែប៉ុណ្ណោះ ហើយពុំមានផលប៉ះពាល់អ្វីទាំងអស់ដល់វិទ្យាល័យ និងលោកនាយក/នាយិកា/នាយករងសាលាឡើយ។

**ឌិន ដួង**

និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ

**ផ្នែកទី១** : ព័ត៌មានផ្ទាល់ខ្លួនអំពីស្ថានភាពទូទៅរបស់លោកនាយក/នាយិកា/នាយករងសាលា

**សេចក្ដីណែនាំ:** សូមមេត្តាគូសសញ្ញា ✓ ក្នុងប្រអប់ □ ដែលត្រូវជាមួយស្ថានភាពទូទៅរបស់លោកនាយក/នាយិកាសាលា

ឈ្មោះវិទ្យាល័យ....................................នៅឃុំ/សង្កាត់.........................ក្រុង/ស្រុក.......................

១. ភេទ

□ (1). ប្រុស □ (2). ស្រី

២. កម្រិតវប្បធម៌

□ (1). ទាបជាងបរិញ្ញាបត្រ □ (2). បរិញ្ញាបត្រ □(3). ចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់ឡើង

៣. បទពិសោធន៍ការងារៈ ជានាយក/នាយករងសាលា ................. ឆ្នាំ

ជាគ្រូបង្រៀន ................. ឆ្នាំ

## I. ការត្រៀមលក្ខណៈមុនពេលបង្រៀន

### ក. សម្ភារឧបទេស

៤. តើការបង្រៀន និងរៀនដោយប្រើប្រាស់សម្ភារឧបទេសមានស្ថានភាពដូចម្ដេច?

......................................................................................................................................

៥. តើការប្រើប្រាស់សម្ភារឧបទេសបានជួយអ្វីខ្លះដល់ការរៀនសូត្ររបស់សិស្ស និងការបង្រៀនរបស់គ្រូ?

......................................................................................................................................

៦. តើលោកគ្រូ-អ្នកគ្រូភាសាអង់គ្លេសបង្រៀនថ្នាក់ទី១១ គាត់បានទិញសម្ភារអ្វីខ្លះ?

......................................................................................................................................

៧. តើលោកលោកស្រី/ត្រួតពិនិត្យចំពោះការរៀបចំសម្ភារឧបទេសដែលមានប្រសិទ្ធភាព និងកិច្ចតែងការបង្រៀនភាសាអង់គ្លេសរបស់គ្រូប្រចាំថ្ងៃដែរឬទេ?

□ក.មិនដែលសោះ □ខ.ធ្វើម្ដងម្កាល □គ.ញឹកញាប់ □ឃ.ញឹកញាប់ខ្លាំង □ង.ធ្វើជាប្រចាំ

**ខ. កិច្ចតែងការបង្រៀន**

៨. តើលោកគ្រូ-អ្នកគ្រូសាលារបស់លោក/លោកស្រីមានកិច្ចតែងការបង្រៀនដែរឬទេក្នុងពេលបង្រៀនសិស្ស?

☐ មាន ( .......... កិច្ចតែងការបង្រៀន ) ☐ មិនមែន

៩. តើលោក/លោកស្រីធ្លាប់បានត្រួតពិនិត្យឬចុះទិដ្ឋការលើកិច្ចតែងការបង្រៀនលើមុខវិជ្ជាប៉ុន្មានដង ហើយក្នុងឆ្នាំសិក្សា ២០១៩ - ២០២០ នេះ?

☐ 0 ដង ☐ ១ ដង ☐ ២ ដង ☐ ៣ ដងឡើងទៅ

**II. ពេលបង្រៀន**

**ក. អធិការកិច្ច**

១០. តើលោក/លោកស្រីយល់យ៉ាងដូចម្ដេចចំពោះស្ថានភាពនៃការចុះអធិការកិច្ចមើលការបង្រៀន និងការរៀនរបស់សិស្ស?

...................................................................................................................................

១១. តើលោក/លោកស្រីយល់ថាការចុះអធិការកិច្ចបានជួយអ្វីខ្លះដល់គ្រូ និងសិស្ស?

...................................................................................................................................

១២.តើលោក/លោកស្រីយល់ថាវិធីសាស្ត្របង្រៀនដែលគាត់ប្រើប្រាស់នូវមានចំណុចខ្វះខាតដែរឬទេ?

☐ មានចំណុចខ្វះខាត ☐ គ្មានចំណុចខ្វះខាត

បើមានចំណុចខ្វះខាត តើមានចំណុចអ្វីខ្លះ?..........................................................................

**ខ. សកម្មភាពពេលកំពុងបង្រៀន**

១៣.តើនៅក្នុងថ្នាក់រៀនរបស់សាលាមានសិស្សថ្នាក់ទី១១ ចំនួនប៉ុន្មាននាក់ក្នុងមួយថ្នាក់ៗ?

...................................................................................................................................

១៤. តាមយោបល់របស់លោក-លោកស្រី តើលោកគ្រូ-អ្នកគ្រូ បង្រៀនគួរកែលម្អនៅត្រង់ចំណុចណាខ្លះ ដើម្បីឱ្យសិស្ស ងាយយល់ខ្លឹមសារមេរៀន?

...................................................................................................................................

១៥.តើលោក/លោកស្រីត្រូវធ្វើដូចម្តេចដើម្បីជួយជម្រុញលោកគ្រូ/អ្នកគ្រូឱ្យអនុវត្តគោលវិធីសិស្ស មជ្ឈមណ្ឌលក្នុងការ បង្រៀន និងរៀនភាសាអង់គ្លេសនៅថ្នាក់ទី១១ កាន់តែទទួលបានប្រសិទ្ធភាពខ្ពស់?

..........................................................................................................................................

១៦. តើលោក/លោកស្រីយល់ថាការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅថ្នាក់ទី១១ មានគុណសម្បត្តិ និងគុណវិបត្តិយ៉ាងដូចម្តេចខ្លះ?

គុណសម្បត្តិ

..........................................................................................................................................

គុណវិបត្តិ

..........................................................................................................................................

១៧.តើលោក/លោកស្រីមានសំណូមពរអ្វីខ្លះ ដើម្បីអោយស្ថានភាពនៃការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅថ្នាក់ទី១១ នៅក្នុងសាលារបស់លោក/លោកស្រីកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

## ឧបសម្ព័ន្ធទី៥

## កម្រងសំណួរសម្រាប់ លោកគ្រូ - អ្នកគ្រូ (បំពេញ និង សង្កេតថ្នាក់)

**សូមគោរពជូន ៖ លោកគ្រូ - អ្នកគ្រូ**

ខ្ញុំបាទឈ្មោះ **ឌិន ដួង** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំ នឹងធ្វើការសិក្សា ស្រាវជ្រាវបញ្ចប់ឆ្នាំសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ក្រោមប្រធានបទ «**ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន ភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១១) ក្នុងខេត្តតាកែវ**»ខ្ញុំបាទសូមគោរពអញ្ជើញលោកនាយក/នាយិកាសាលា ដើម្បីចូលរួមក្នុងការផ្តល់ចម្លើយលើកម្រងសំណួរការស្រាវជ្រាវខាងក្រោម ក្នុងគោលបំណងសិក្សាស្វែងយល់ពីស្ថានភាពក្នុងការជួយជម្រុញការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសរបស់លោកគ្រូ-អ្នកគ្រូនៅកម្រិតមធ្យមសិក្សាទុតិយភូមិ (បង្រៀនថ្នាក់ទី១១) ក្នុងខេត្តតាកែវ។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងខ្ពង់ខ្ពស់ចំពោះកិច្ចសហការ និងការចំណាយពេលវេលាដ៏មានតម្លៃរបស់លោកគ្រូ-អ្នកគ្រូក្នុងការឆ្លើយនឹងកម្រងសំណួររបស់ខ្ញុំបាទ។

### សេចក្តីណែនាំ

**១. កម្រងសំណួរការស្រាវជ្រាវចែកចេញជា ២ផ្នែក ដូចខាងក្រោមៈ**

ផ្នែកទី១ : ព័ត៌មានអំពីស្ថានភាពទូទៅរបស់លោកនាយក/នាយិកាសាលា

ផ្នែកទី២ : ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនអង់គ្លេសរបស់លោកគ្រូអ្នកគ្រូ នៅតាមវិទ្យាល័យ

**២. សូមអានសេចក្តីណែនាំពីការឆ្លើយកម្រងសំណួរគ្រប់ផ្នែកនីមួយៗ ដោយការយកចិត្តទុកដាក់។ សូមមេត្តាជួយផ្តល់ ចម្លើយតាមរយៈការសម្ភាសដោយផ្ទាល់ឱ្យបានគ្រប់សំណួរតាមការពិតជាក់ស្តែង។**

ដូច្នេះ សូមលោកគ្រូ-អ្នកគ្រូ មេត្តាផ្តល់ព័ត៌មានពិតដល់ខ្ញុំបាទដើម្បីឱ្យការស្រាវជ្រាវនេះអាចទទួលយកជាការបាន។ ព័ត៌មានទាំងអស់នេះមានសារៈសំខាន់ណាស់សម្រាប់ការសិក្សាស្រាវជ្រាវនៅពេលបច្ចុប្បន្ននិងពេលអនាគត។

ខ្ញុំបាទ សូមធានាអះអាងថានឹងរក្សាការសម្ងាត់ចំពោះរាល់ព័ត៌មានដែលបានផ្តល់ឱ្យហើយព័ត៌មានទាំងអស់នេះ ត្រូវបានយកទៅប្រើប្រាស់ក្នុងគោលបំណងនៃការស្រាវជ្រាវតែប៉ុណ្ណោះ ហើយពុំមានផលប៉ះពាល់អ្វីទាំងអស់ដល់ វិទ្យាល័យ និងលោកគ្រូ-អ្នកគ្រូខ្លួនឯងឡើយ។ ជាថ្មីម្តងទៀត សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកគ្រូ-អ្នកគ្រូដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបំពេញកម្រងសំណួរនេះ។

**ឌិន ជួប**

និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ

**ផ្នែកទី១** : ព័ត៌មានអំពីស្ថានភាពទូទៅរបស់លោកគ្រូ- អ្នកគ្រូ

**សេចក្តីណែនាំ:** សូមមេត្តាគូសសញ្ញា ✓ ក្នុងប្រអប់ □ ដែលត្រូវជាមួយស្ថានភាពទូទៅរបស់លោកគ្រូ-អ្នកគ្រូ

ឈ្មោះវិទ្យាល័យ...........................នៅឃុំ/សង្កាត់............................ក្រុង/ស្រុក...........................

១. ភេទ

□ (1). ប្រុស □ (2). ស្រី

២. អាយុ...............ឆ្នាំ

៣. កម្រិតវប្បធម៌

□ (1). ទាបជាងបរិញ្ញាបត្រ □ (2). បរិញ្ញាបត្រ □ (3). ចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់ឡើង

៤. បទពិសោធន៍បង្រៀន

□ (1). តិចជាង ៣ ឆ្នាំ □ (2). ពី ៣ - ៥ ឆ្នាំ □ (3). លើសពី ៦ ឆ្នាំ

**ផ្នែកទី២** : ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសរបស់លោកគ្រូ-អ្នកគ្រូនៅ

សេចក្តីណែនាំ

ក្នុងផ្នែកទី២នេះ មានប្រយោគចំនួន **៥៣** សូមលោកគ្រូ- អ្នកគ្រូ មេត្តាពិចារណាខ្លឹមសារគោលគំនិតដូចខាងក្រោម ហើយគូសជ្រើសរើសយកចម្លើយតែមួយគត់ដោយគូសសញ្ញា ✓ ក្នុងប្រអប់ □ ដែលត្រូវតាមការពិតជាក់ស្តែង និងត្រូវតាមស្ថានភាពនៃការអនុវត្តរបស់លោកគ្រូអ្នកគ្រូត្រឹមតែប្រអប់មួយតែប៉ុណ្ណោះដោយៈ

សម្គាល់ការវាយតម្លៃ**ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១១)**

1.អត់សោះៈ មានន័យថាការអនុវត្តតាមខ្លឹមសារគោលគំនិតនោះអត់ មិនដែលអនុវត្តទាល់តែសោះ

2. តិចតួចៈ មានន័យថា ការអនុវត្តតាមខ្លឹមសារគោលគំនិតនោះ **តិច** ឬ អនុវត្តម្តងម្កាល

3. មធ្យម៖ មានន័យថា ការអនុវត្តតាមខ្លឹមសារគោលគំនិតនោះ **មធ្យម** ឬ អនុវត្តខ្លះ មិនអនុវត្តន៍ខ្លះ

4. ច្រើន៖ មានន័យថា ការអនុវត្តតាមខ្លឹមសារគោលគំនិតនោះ **ច្រើន** ឬស្ទើរគ្រប់ពេល

5. ច្រើនបំផុត៖ មានន័យថា ការអនុវត្តតាមខ្លឹមសារគោលគំនិតនោះ **ច្រើនបំផុត** ឬជាប្រចាំ គ្រប់ពេល

| ល.រ | ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១១) ក្នុងខេត្តតាកែវ | កម្រិតនៃការអនុវត្ត | | | | |
|---|---|---|---|---|---|---|
| | | 5 | 4 | 3 | 2 | 1 |
| | | ច្រើនបំផុត | ច្រើន | មធ្យម | តិច | អត់ |
| | **១. ការត្រៀមលក្ខណៈមុនពេលបង្រៀន** | | | | | |
| ១ | បានត្រៀមលក្ខណៈរួចរាល់ក្នុងការផ្តល់ចំណេះដឹងប្រឹក្សាយោបល់ ពន្យល់បកស្រាយណែនាំ និងឯកសារផ្សេងៗដល់សិស្ស | | | | | |
| ២ | បានធ្វើកិច្ចតែងការបង្រៀនដែលទាក់ទងទៅនឹងវត្ថុបំណងមេរៀន និងខ្លឹមសារមេរៀន | | | | | |
| ៣ | បានរៀបចំថ្នាក់រៀនដែលសមស្របដល់ការបង្រៀន | | | | | |
| ៤ | បានត្រៀមសម្ភារឧបទេសទាំងគ្រូ ទាំងសិស្សសម្រាប់ការបង្រៀន | | | | | |
| ៥ | បានត្រៀមលំហាត់សម្រាប់ធ្វើតេស្តសិស្សតាមវត្ថុបំណងមេរៀនតាមក្រុមនីមួយៗ | | | | | |
| ៦ | បានត្រៀមពីវិធីសាស្ត្រទំនាក់ទំនងដែលល្អជាមួយសិស្ស | | | | | |
| ៧ | បានរៀបចំបរិស្ថានថ្នាក់ និងបន្ទប់រៀនប្រកបដោយបរិយាកាសអំណោយផលដល់ការបង្រៀន និងរៀន | | | | | |
| ៨ | បានត្រៀមពីវិធីសាស្ត្រក្នុងការបង្ហាញពីវត្ថុបំណងក្នុងខ្លឹមសារមេរៀន | | | | | |
| ៩ | បានត្រៀមរួចជាស្រេច ក្នុងករណីកើតមានបញ្ហាខ្លឹមសារមេរៀន | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | ដែលមិនសមស្របជាមួយវ័យ និងការគិត | | | | | |
| ១០ | បានត្រៀមលំហាត់ដើម្បីអភិវឌ្ឍសមត្ថភាពសិស្សតាមវត្ថុបំណងមេរៀនដោយធ្វើការស្រាវជ្រាវដោយខ្លួនឯង | | | | | |
| **២. លក្ខណៈទូទៅនៃការបង្រៀន** | | | | | | |
| ១១ | បានធ្វើឱ្យសិស្សចាប់អារម្មណ៍មុនពេលធ្វើសកម្មភាពបង្រៀន | | | | | |
| ១២ | បានលើកកម្ពស់ជម្រុញសិស្ស ឱ្យទទួលបានចំណេះដឹងបទពិសោធន៍ពិតប្រាកដដោយខ្លួនឯង | | | | | |
| ១៣ | បានប្រើសម្ភារឧបទេសក្នុងការបង្រៀន និងរៀនដើម្បីជម្រុញសិស្សឱ្យទទួលបានចំណេះដឹង | | | | | |
| ១៤ | បានជួយជម្រុញសិស្សឱ្យហ្វឹកហាត់ធ្វើសកម្មភាពរៀនដោយខ្លួនឯងច្រើនជាងស្តាប់គ្រូពន្យល់ | | | | | |
| ១៥ | បានជួយប្រឹក្សាយោបល់ដែរឬទេនៅពេលដែលសិស្សត្រូវការឱ្យជួយ | | | | | |
| ១៦ | បានលើកស្ទួយ និងផ្តល់កម្លាំងចិត្តឱ្យសិស្សទទួលបានចំណេះដឹងពី ការស្រាវជ្រាវដោយខ្លួនឯង | | | | | |
| ១៧ | បានបង្កើតទំនាក់ទំនងរវាងគ្រូជាមួយសិស្ស និងសិស្ស-សិស្ស | | | | | |
| ១៨ | បានបង្រៀនពីចំណេះដឹងដែលទាក់ទងទៅនឹងការប្រកបរបរចិញ្ចឹម ជីវិតប្រចាំថ្ងៃ | | | | | |
| ១៩ | បានប្រើវិធីសាស្ត្រ និងបច្ចេកទេសក្នុងការបង្រៀននិងរៀនបានកម្រិត ណាដើម្បីឱ្យសិស្សដែលរៀនទទួលបានចំណេះដឹង | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ២០ | បានបង្កើតសកម្មភាពដែលជម្រុញសិស្សឱ្យហ្វឹកហាត់ការគិតការអនុវត្ត ការដោះស្រាយបញ្ហា និងធ្វើខ្លួនឯងឱ្យរស់នៅប្រកបដោយសេចក្ដីថ្លៃថ្នូរ | | | | | |
| | **៣.វាយតម្លៃ** | | | | | |
| ២១ | បានវាយតម្លៃសិស្សបន្តបន្ទាប់ក្រោយពីចប់ជំហានទី៣ តាមរយៈការឆ្លើយនឹងសំណួរ ធ្វើលំហាត់ពិភាក្សាតាមក្រុម | | | | | |
| ២២ | បានវាយតម្លៃសិស្សបន្តបន្ទាប់ក្រោយពីចប់ជំហានទី៤ តាមរយៈការឆ្លើយនឹងសំណួរធ្វើលំហាត់ពិភាក្សាតាមក្រុម | | | | | |

៥. តើគ្រូបង្រៀនអាចអនុវត្តសកម្មភាពខាងក្រោមបានកម្រិតណា? ( ដំណើរការបង្រៀន )

| | **១. សកម្មភាពគ្រូ** | | | | | |
|---|---|---|---|---|---|---|
| ១ | គ្រូប្រើផ្ទាំងរូបភាពរំឭកមេរៀនលើកមុន | | | | | |
| ២ | គ្រូធ្វើលំហាត់គំរូឱ្យសិស្សមើល | | | | | |
| ៣ | គ្រូណែនាំសិស្សឱ្យធ្វើការងារតាមក្រុម | | | | | |
| ៤ | គ្រូពន្យល់ធ្វើអត្ថាធិប្បាយ និងពណ៌នា | | | | | |
| ៥ | គ្រូចោទបញ្ហាៗ ឬដោះស្រាយតែម្នាក់ឯង | | | | | |
| ៦ | គ្រូគូរ សរសេរ ឬស្រាយបំភ្លឺចម្លើយលើក្ដារខៀន | | | | | |
| ៧ | គ្រូមិនអើពើចំពោះតួនាទីរបស់សិស្ស | | | | | |
| ៨ | គ្រូយកចិត្តទុកដាក់ទៅលើតួនាទិរបស់សិស្ស | | | | | |
| ៩ | គ្រូប្រើវិធីឱ្យសិស្សចងចាំខ្លឹមសារមេរៀន | | | | | |
| ១០ | គ្រូជួយជម្រុញឱ្យសិស្សធ្វើការស្រាវជ្រាវដោយខ្លួនឯង | | | | | |
| ១១ | គ្រូលើកទឹកចិត្តឬស្ដីបន្ទោសសិស្សពីកត្តាក្រៅខ្លួន | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ១២ | គ្រូបំផុសគំនិតសិស្សឱ្យចង់រៀនយកស្នាដៃ | | | | | |
| ១៣ | គ្រូសង្កត់ធ្ងន់លើការងារក្រុមតូចឬធំ | | | | | |
| ១៤ | គ្រូសង្កត់ធ្ងន់លើសកម្មភាពសិស្សម្នាក់ៗ | | | | | |
| ១៥ | គ្រូជំរុញសិស្សឱ្យកសាងបទពិសោធន៍ថ្មីៗ | | | | | |
| ១៦ | គ្រូផ្តល់បទពិសោធន៍ថ្មីតិចតួចណាស់ | | | | | |
| ១៧ | គ្រូសង្កត់ធ្ងន់ទៅលើការយល់ដឹងលើមុខវិជ្ជា | | | | | |
| ១៨ | គ្រូបញ្ជ្រាបសីលធម៌លើមុខវិជ្ជាសិក្សា | | | | | |
| ១៩ | គ្រូទម្លាប់សិស្សឱ្យក្លាហានក្នុងការនិយាយ | | | | | |
| ២០ | គ្រូសរសេររូបមន្ត ខ្លឹមសារសំខាន់ៗនៃមេរៀន | | | | | |
| | **២. សកម្មភាពសិស្ស** | | | | | |
| ១ | សិស្សធ្វើលំហាត់តាមក្រុម ឬជាដៃគូ | | | | | |
| ២ | សិស្សពិភាក្សាដោះស្រាយបញ្ហាតាមក្រុម | | | | | |
| ៣ | សិស្សឡើងសរសេរចម្លើយតាមក្រុមខ្លួន | | | | | |
| ៤ | សិស្សស្តាប់ កត់ត្រា ឆ្លើយ ឬថាតាមគ្រូ | | | | | |
| ៥ | សិស្សពិភាក្សាជាក្រុមយកយោបល់ឯកភាព | | | | | |
| ៧ | សិស្សបានត្រៀមខ្លឹមសារមេរៀនសម្រាប់ឆ្លើយ | | | | | |
| ៨ | សិស្សទទួលចំណេះដឹងតាមការផ្ទេរចំណេះដឹងរបស់គ្រូ | | | | | |
| ៩ | សិស្សយល់ដឹងដោយធ្វើសកម្មភាពរៀនដោយខ្លួនឯង | | | | | |
| ១០ | សិស្សចេះអនុវត្តបានដោយមានអ្នកជួយ ( សិស្ស មិត្តភក្តិ ) | | | | | |
| ១១ | សិស្សជាអ្នកស្វែងយល់ ឡើងសរសេររូបមន្ត ខ្លឹមសារ សំខាន់ៗ និងដោះស្រាយលំហាត់ | | | | | |

**ឧបសម្ព័ន្ធទី៦**

## កម្រងសំណួរសម្រាប់ សិស្សថ្នាក់ទី១១

ខ្ញុំបាទឈ្មោះ **ឌិន ដួង** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំ នឹងធ្វើការសិក្សា ស្រាវជ្រាវបញ្ចប់ឆ្នាំសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ក្រោមប្រធានបទ **«ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន ភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១១) ក្នុងខេត្តតាកែវ»** ខ្ញុំបាទសូមគោរពអញ្ជើញលោកនាយក/នាយិកាសាលា ដើម្បីចូលរួមក្នុងការផ្ដល់ចម្លើយលើកម្រងសំណួរការស្រាវជ្រាវខាងក្រោម ក្នុងគោលបំណងសិក្សាស្វែងយល់ពីស្ថានភាពក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសរបស់លោកគ្រូ-អ្នកគ្រូនៅកម្រិតមធ្យមសិក្សាទុតិយភូមិ (បង្រៀនថ្នាក់ទី១១) ក្នុងខេត្តតាកែវ។

**សេចក្ដីណែនាំ**

១. កម្រងសំណួរការស្រាវជ្រាវចែកចេញជា ២ផ្នែក ដូចខាងក្រោមៈ

ផ្នែកទី១ : ព័ត៌មានអំពីស្ថានភាពទូទៅរបស់លោកនាយក/នាយិកាសាលា

ផ្នែកទី២ : ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនអង់គ្លេសរបស់លោកគ្រូ-អ្នកគ្រូ នៅតាមវិទ្យាល័យ

២. សូមអានសេចក្ដីណែនាំពីការឆ្លើយកម្រងសំណួរគ្រប់ផ្នែកនីមួយៗ ដោយការយកចិត្តទុកដាក់។ សូមមេត្តាជួយផ្ដល់ ឆ្លើយឱ្យបានគ្រប់សំណួរតាមការពិតជាក់ស្ដែង និងត្រួតពិនិត្យភាពរៀបរយ មុននឹងប្រគល់ឱ្យអ្នកស្រាវជ្រាវវិញដោយមិន បាច់បញ្ចេញដាក់ឈ្មោះ និងនាមត្រកូលឡើយ។

ដូច្នេះ សូមប្អូនៗជាសិស្សសាលាផ្ដល់ព័ត៌មានពិតដល់លោកគ្រូដើម្បីឱ្យការស្រាវជ្រាវនេះអាចទទួលយកជាការបាន។ ព័ត៌មានទាំងអស់នេះមានសារៈសំខាន់ណាស់សម្រាប់ការសិក្សាស្រាវជ្រាវនៅពេលបច្ចុប្បន្ន និងពេលអនាគត។

លោកគ្រូ សូមធានាអះអាងថានឹងរក្សាការសម្ងាត់ចំពោះរាល់ព័ត៌មានដែលបានផ្ដល់ឱ្យហើយព័ត៌មានទាំងអស់នេះ ត្រូវបានយកទៅប្រើប្រាស់ក្នុងគោលបំណងនៃការស្រាវជ្រាវតែប៉ុណ្ណោះ ហើយពុំមានផលប៉ះពាល់អ្វីទាំងអស់ដល់វិទ្យាល័យ និងប្អូនៗជាសិស្សសាលាឡើយ។ ជាថ្មីម្ដងទៀត សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសិស្សានុសិស្សរៀននៅថ្នាក់ទី១១ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបំពេញកម្រងសំណួរនេះ។

**ឌិន ដួង**

និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ

**ផ្នែកទី១** : ព័ត៌មានអំពីស្ថានភាពទូទៅរបស់សិស្សរៀនថ្នាក់ទី១១

**សេចក្តីណែនាំ:** សូមមេត្តាគូសសញ្ញា ✓ក្នុងប្រអប់ □ ដែលត្រូវជាមួយស្ថានភាពទូទៅរបស់សិស្ស

ឈ្មោះវិទ្យាល័យ...........................នៅឃុំ/សង្កាត់..........................ក្រុង/ស្រុក.............................

១. ភេទ

□ (1). ប្រុស □ (2). ស្រី

២. អាយុ ...............ឆ្នាំ

**ផ្នែកទី២** : កត្តាជួយជំរុញការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស របស់លោកគ្រូ-អ្នកគ្រូនៅតាមវិទ្យាល័យ

## I. ការត្រៀមលក្ខណៈមុនពេលបង្រៀន

### ក. សម្ភារឧបទេស

៣. តើលោកគ្រូ- អ្នកគ្រូសាលារបស់ប្អូនៗធ្លាប់បានចែកក្រដាសកាតុង ហ្វឹត បានប៉ុន្មានដងហើយ ក្នុងឆ្នាំសិក្សា២០១៩-២០២០ នេះ?

□ (1). 0ដង □ (2). ១ដង □ (3). ២ ដង □ (4). ៣ដងឡើងទៅ

៤. តើសម្ភារទាំងនោះគាត់បានចែកឱ្យប្អូនក្នុងគោលបំណងយកទៅប្រើប្រាស់សម្រាប់ធ្វើអ្វីខ្លះ?

.....................................................................................................................................

៥.តើប្អូនៗយល់ថា សម្ភារឧបទេសទាំងនោះបានជួយអ្វីខ្លះដល់ប្អូនៗក្នុងការសិក្សារៀនសូត្រ?

.....................................................................................................................................

ពេលបង្រៀន

### ក. ការបង្ហាញពីវត្ថុបំណងមេរៀន

៦. មុនពេលចាប់ផ្តើមមេរៀនថ្មី តើគ្រូរបស់ប្អូនៗបានប្រាប់ពីវត្ថុបំណងមេរៀនដែរឬទេ?

□ (1). បានប្រាប់ □ (2). មិនបានប្រាប់

៧.តើគ្រូបង្រៀនរបស់ប្អូនៗបង្រៀនប្អូនៗឱ្យយល់ខ្លឹមសារមេរៀននិងអាចអនុវត្តលំហាត់បានកម្រិតណា?

□ (1). តិចតួច □ (2). តិច □ (3). មធ្យម □ (4). ច្រើន

□ (5). ច្រើនបំផុត

## ខ. សកម្មភាពពេលកំពុងបង្រៀន

៨.តើគ្រូបង្រៀនរបស់ប្អូនៗបានបែងចែកសិស្សតាមក្រុមសម្រាប់ពិភាក្សា ញឹកញាប់កម្រិតណា?

□ (1). មិនដែល □ (2). តិចតួច □ (3). មធ្យម □ (4). ញឹកញាប់ □ គ្រប់ពេល

៩.តើក្នុងក្រុមនីមួយៗមានសមាជិកប៉ុន្មាននាក់?

□ (1). ៣-៤នាក់ □ (2). ៥-៦នាក់ □ (3). ៧-៨នាក់ □ (4). ៩-១០នាក់

□ (5).១១-១២នាក់

១០.តើគ្រូបង្រៀនរបស់ប្អូនៗគាត់បានដាក់បញ្ហាអ្វីខ្លះឱ្យប្អូនពិភាក្សាដោះស្រាយតាមក្រុម?

..........................................................................................................................................

១១.ក្នុងសកម្មភាពសិស្សកំពុងពិភាក្សាដោះស្រាយតាមក្រុម តើគ្រូបង្រៀនរបស់ប្អូនៗបានធ្វើអ្វីខ្លះ:?

..........................................................................................................................................

១២. តើគ្រូបង្រៀនរបស់ប្អូនៗអនុវត្តសកម្មភាពខាងក្រោមបានកម្រិតណា?

| ល.រ | ការអនុវត្តសកម្មភាពបង្រៀន និងរៀនភាសាអង់គ្លេស ថ្នាក់ទី១១ (សកម្មភាពគ្រូ និង សកម្មភាពសិស្ស | កម្រិតនៃការអនុវត្ត | | | | |
|---|---|---|---|---|---|---|
| | | 5 | 4 | 3 | 2 | 1 |
| | | ច្រើនបំផុត | ច្រើន | មធ្យម | តិច | អត់ដែលសោះ |
| **១. សកម្មភាពគ្រូ** | | | | | | |
| ១ | គ្រូប្រើផ្ទាំងរូបភាពរំឭកមេរៀនលើកមុន | | | | | |
| ២ | គ្រូធ្វើលំហាត់គំរូឱ្យសិស្សមើល | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៣ | គ្រូណែនាំសិស្សឱ្យធ្វើការងារតាមក្រុម | | | | | |
| ៤ | គ្រូពន្យល់ធ្វើអត្ថាធិប្បាយ និងពណ៌នា | | | | | |
| ៥ | គ្រូចោទបញ្ហាៗ ឬដោះស្រាយតែម្នាក់ឯង | | | | | |
| ៦ | គ្រូគូរ សរសេរ ឬស្រាយបំភ្លឺចម្លើយលើក្ដារខៀន | | | | | |
| ៧ | គ្រូមិនអើពើចំពោះតួនាទីរបស់សិស្ស | | | | | |
| ៨ | គ្រូយកចិត្តទុកដាក់ទៅលើតួនាទីរបស់សិស្ស | | | | | |
| ៩ | គ្រូប្រើវិធីឱ្យសិស្សចងចាំខ្លឹមសារមេរៀន | | | | | |
| ១០ | គ្រូជួយជំរុញឱ្យសិស្សធ្វើការស្រាវជ្រាវដោយខ្លួនឯង | | | | | |
| ១១ | គ្រូលើកទឹកចិត្តឬស្ដីបន្ទោសសិស្សពីកត្តាក្រៅខ្លួន | | | | | |
| ១២ | គ្រូបំផុសគំនិតសិស្សឱ្យចង់រៀនយកស្នាដៃ | | | | | |
| ១៣ | គ្រូសង្កត់ធ្ងន់លើការងារក្រុមតូចឬធំ | | | | | |
| ១៤ | គ្រូសង្កត់ធ្ងន់លើសកម្មភាពសិស្សម្នាក់ៗ | | | | | |
| ១៥ | គ្រូជំរុញសិស្សឱ្យកសាងបទពិសោធន៍ថ្មីៗ | | | | | |
| ១៦ | គ្រូផ្ដល់បទពិសោធន៍ថ្មីតិចតួចណាស់ | | | | | |
| ១៧ | គ្រូសង្កត់ធ្ងន់ទៅលើការយល់ដឹងលើមុខវិជ្ជា | | | | | |
| ១៨ | គ្រូបញ្ជ្រាបសីលធម៌លើមុខវិជ្ជាសិស្ស | | | | | |
| ១៩ | គ្រូទម្លាប់សិស្សឱ្យក្លាហានក្នុងការនិយាយ | | | | | |
| ២០ | គ្រូសរសេររូបមន្ត ខ្លឹមសារសំខាន់ៗមេរៀន | | | | | |
| **២. សកម្មភាពសិស្ស** | | | | | | |
| ១ | សិស្សធ្វើលំហាត់តាមក្រុម ឬជាដៃគូ | | | | | |
| ២ | សិស្សពិភាក្សាដោះស្រាយបញ្ហាតាមក្រុម | | | | | |
| ៣ | សិស្សឡើងសរសេរចម្លើយតាមក្រុមខ្លួន | | | | | |
| ៤ | សិស្សស្ដាប់ កត់ត្រា ឆ្លើយ ឬថាតាមគ្រូ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៥ | សិស្សពិភាក្សាជាក្រុមយកយោបល់ឯកភាព | | | | | |
| ៦ | សិស្សមិនបានត្រៀមខ្លឹមសារជាមុនទេ | | | | | |
| ៧ | សិស្សបានត្រៀមខ្លឹមសារមេរៀមសម្រាប់ឆ្លើយ | | | | | |
| ៨ | សិស្សទទួលចំណេះដឹងតាមការផ្ទេរចំណេះដឹងរបស់គ្រូ | | | | | |
| ៩ | សិស្សយល់ដឹងដោយធ្វើសកម្មភាពរៀនដោយខ្លួនឯង | | | | | |
| ១០ | សិស្សចេះអនុវត្តបានដោយមានអ្នកជួយ (សិស្ស មិត្តភក្តិ) | | | | | |
| ១១ | សិស្សជាអ្នកស្វែងយល់ ឡើងសរសេររូបមន្ត ខ្លឹមសារសំខាន់ៗ និងដោះស្រាយលំហាត់ | | | | | |

១៣.តាមយោបល់របស់ប្អូនៗ តើគ្រូបង្រៀនរបស់ប្អូនៗគួរកែលម្អនៅត្រង់ចំណុចណាខ្លះ ដើម្បីឱ្យប្អូនៗដែលជាសិស្សានុសិស្ស ងាយយល់ខ្លឹមសារមេរៀន? ឆាប់យល់រូបមន្ត ឆាប់ចាំខ្លឹមសារមេរៀន? អាចអនុវត្តលំហាត់បាន?

..............................................................................................................................................

១៤.**សំណូមពរផ្សេងៗ៖** (សម្ភារឧបទេស ហ្វឺត ក្រដាសតាកុង ផ្ទាំងរូបភាព ស្លាយ)

..............................................................................................................................................

## ឧបសម្ព័ន្ធទី៧

### ១-គណៈកម្មការមេប្រយោគ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ :......./.......វជអ.

**បំណែងចែកគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ**
**ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧**
**ដែលប្រព្រឹត្តទៅពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០**
**នៅវិទ្យាស្ថានជាតិអប់រំ**

**គណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ**

| ក្រុមទី១ | | ក្រុទី២ | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | ១-ឯកឧត្តមបណ្ឌិត | ម៉ុក សារុំម |
| ២- ឯកឧត្តម | នៀ សុផន | ២-លោកបណ្ឌិត | នួវ រ៉ាំ |
| ៣-លោក | ឌី បុណ្ណា | ៣-លោកស្រី | ប៊ុន សុផានី |
| ៤-លោក | ថៃ ហេង | ៤-លោក | ចាប រតនា |
| ៥-លោក | ម៉ន មុនិន្ទ | ៥-លោកបណ្ឌិត | អាន វ៉ុប្រាវ |
| ៦-លោកបណ្ឌិត | នី វង្ហា | ៦-លោកស្រី | នូ ចន្ទី |
| ៧-លោកបណ្ឌិត | ឈាង សង្ហាត | ៧-លោក | សៀង វាសនា |

**គណៈកម្មការគណ្ដាល និងរៀបចំ**

| ក្រុមទី១ | | ក្រុមទី២ | |
|---|---|---|---|
| ៨-លោក | លឹម វ៉ាន់ | ៨-លោក | ឡេង បុរី |
| ៩-លោក | លន លីណា | ៩-លោកស្រី | ហង់ ស្រីម៉ាច |
| ១០-លោក | ឡុច ចាន់ថន | ១០-លោក | ហ៊ឹង សារៈបុត្រ |
| ១១-លោកស្រី | ទ្រី រីណា | ១១-លោក | ម៉ែន សុខសុន្ទី |

ថ្ងៃពុធ ៥កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០
**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ៖ (៨៥៥-២៣) ២១៥/៥៨៨ គេហទំព័រ៖ www.nie.edu.kh

## ២-គណៈកម្មការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខៈ ៥៣៧៧ អយក.ខ្ម

(ការសម្ងាត់)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។

-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារសារណា** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯ.ឧបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | អនុប្រធាន |
| ៣- ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៤-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោកបណ្ឌិត | នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកបណ្ឌិត | នី រង្សោ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោកបណ្ឌិត | អាន រ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារសារណា របស់និស្សិតពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៣ កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

"ដើម្បីជ្រាបជាព័ត៌មាន"

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ

"ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ -ឯកសារ វជអ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh